**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌ
# របស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក. ឈៀង វឌ្ឍច័ន្ទ**

**ក. ឡេង គឹមអេង**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ម ចាន់ណែត**



ថ្នាក់បរិញ្ញាប័ត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ឲ្យឲ្យឲ្យ

នាងខ្ញុំយើងខ្ញុំទាំងពីរ **ឈ្មោះ ឈៀង វង្សច័ន្ទ** និង **ឡេង គឹមអេង** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមអនុញ្ញាតលំឱនកាយសម្តែងនូវគារវកិច្ចគោរពដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះ ៖

លោកឪពុក និងអ្នកម្តាយ ដែលលោកទាំងទ្វេបានផ្តល់កំណើតដល់រូបកូន ព្រមទាំងប្រឹងប្រែងយ៉ាងធ្ងន់ផ្តាច់ពេញមួយជីវិតចិញ្ចឹមបីបាច់ថែរក្សាការពារអប់រំទូន្មានប្រៀនប្រដៅរូបកូនប្រកប ដោយទឹកចិត្តព្រហ្មវិហារធម៌គ្មានទីបំផុត និងជារៀងរហូតមក។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានខិតខំយ៉ាងប្តូរ ផ្តាច់គ្រប់កាលៈទេសៈសង្គមទាំងអស់ក្នុងការប្រឹងប្រែងបង្រួបបង្រួមជាតិ ដោយធ្វើឱ្យមានការឯកភាពជាតិ សន្តិសុខ សន្តិភាពរក្សាបាននូវស្ថិរភាពនយោបាយជានិច្ចនិរន្តរ៍ ដែលជាកត្តាចាំបាច់ក្នុងការជម្រុញឱ្យមានការអភិវឌ្ឍន៍ប្រទេសជាតិឱ្យបានលូតលាស់រីកចម្រើនលើគ្រប់វិស័យ ប្រកបដោយនិរន្តរ៍ភាព។

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំទាំងកម្លាំងកាយ និងចិត្ត ចូលរួមលើកស្ទួយដល់ការបណ្តុំបណ្តាលធនធានមនុស្សឲ្យមាននូវមូលធនបញ្ញាយ៉ាងច្បាស់លាស់ ជាពិសេសការបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីរ តាំងពីថ្នាក់ឆ្នាំមូលដ្ឋាន រហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ។

ជាពិសេសទៅទៀត យើងខ្ញុំទាំងពីរ សូមអនុញ្ញាតគោរព និងសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតអស់ពីដួងចិត្ត ជូនចំពោះ **លោក ម៉ម ចាន់ណៃត** ដែលជាសាស្ត្រចារ្យដឹកនាំ អត្ថបទរបាយការណ៍របស់យើងខ្ញុំទាំងពីរ ដោយលោកបានខិតខំអស់ទាំងកំលាំងកាយ និងចិត្ត ចំណាយទាំងពេលវេលាដ៏មានតម្លៃធ្វើការពន្យល់ ណែនាំ បង្ហាញនូវគន្លឹះសំខាន់ៗ និងលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរ រហូតដល់សម្រេចបញ្ចប់ជាស្ថាពរនូវអត្ថបទរបាយការណ៍នេះ ប្រកបដោយ លទ្ធផល និងខ្លឹមសារជាវិជ្ជមាន។

ជាកិច្ចបញ្ចប់ យើងខ្ញុំទាំងពីរ សូមលំឱនកាយលើកដៃប្រណមបួងសួងជូនដល់ សម្តេច និងលោកជំទាវ ព្រមទាំងលោក ឪពុក និងអ្នកម្តាយ ដ៏មានគុណទាំងពីរ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុៈ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

**៙៙៙**

ក្រោយពីបានសិក្សាអស់ពេល៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កន្លងមក គឺជារយៈពេលមួយដែលយើងខ្ញុំទាំងពីរ បានខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ និងការប្រឹងប្រែងស្តាប់សាស្ត្រចារ្យពន្យល់ ដោយយកចិត្តទុកដាក់ ដើម្បីជាទន់ក្នុងការសរសេរសាណាឱ្យបានល្អប្រសើរឡើង។

បន្ទាប់ពីបានសិក្សា មុខវិជ្ជាជាច្រើន នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ យើងខ្ញុំទាំងពីរយល់ឃើញថា មានមុខវិជ្ជាច្រើនណាស់ដែលសុទ្ធសឹងតែមានប្រយោជន៍ និងសំខាន់សម្រាប់សិស្សានុសិស្ស។ នៅក្នុងឱកាសនេះ យើងសូមសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលនិយាយអំពី **ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ** យកមកសរសេរសារណា បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយចង់ឱ្យដឹងច្បាស់អំពីការចេញនិងអនុវត្តដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ។

ស្នាដៃនេះ នឹងចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ ដូចជាលើកស្ទួយវិស័យយុត្តិធម៌ តាមរយៈខ្លឹមសារនៃប្រធានបទ ដែលបង្ហាញជនរួមជាតិ និងសាធារណៈមតិទូទៅអំពីគោលបំណង។

ប្រធានបទរបស់យើងខ្ញុំ គឺផ្តោតទៅលើ **ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ** ក្នុងក្របខណ្ឌក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ដែលបានផ្តល់នូវសិទ្ធិស្របច្បាប់ចំពោះចៅក្រមស៊ើបសួរនៅក្នុងដីកានីមួយៗ ដើម្បីបញ្ជាជាលាយលក្ខណ៍អក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ច ដែលបង្គាប់ឱ្យចាត់ការនូវអំពើណាម្យ៉ាង ជាពិសេស បញ្ជាដែលបង្គាប់ឱ្យចាប់ខ្លួន ជនណាម្នាក់ឬច្រើននាក់ ដែលចេញដោយតុលាការ អង្គការ ឬ មន្ត្រីផ្លូវការណាម្នាក់។

យើងខ្ញុំសូមសំណូមពរឱ្យ ជនរួមជាតិទាំងអស់ពិសេសស្ថាប័នតុលាការស្ថាប័ននគរបាលយុត្តិធម៌ និងស្ថាប័នអនុវត្តច្បាប់នានាផ្តល់ការគាំទ្រ ជាពិសេស ចៅក្រមស៊ើបសួរ ដោយចូលរួមអនុវត្តយ៉ាងសកម្មនូវតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីឱ្យទៅជាចលនារួមដ៏ខ្លាំងក្លា សំដៅសម្រេចឱ្យបាននូវជោគជ័យជាផ្លែផ្កា សម្រាប់ជាឧត្តមប្រយោជន៍របស់ប្រទេសកម្ពុជាលើវិស័យយុត្តិធម៌។

ដោយសារតែសៀវភៅនេះ គឺជាស្នាដៃដំបូងរបស់យើងខ្ញុំ ហេតុនេះយើងជឿជាក់ថា ពិតជាមានការខ្វះខាត និងមានកំហុសខ្លះៗជាក់ជាមិនខានឡើយ។ ដូច្នេះយើងខ្ញុំ រង់ចាំទទួលដោយក្តីសោមនស្ស នូវរាល់ការរិះគន់ ដើម្បីកែលំអក្នុងន័យស្ថាប័នចំពោះស្នាដៃមួយនេះគ្រប់ពេលវេលា។ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរព និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនជនរួមជាតិនៅគ្រប់ទិសទីដែលបានផ្តល់នូវជំនឿ និងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម**...............................................................................................១

## ជំពូកទី១

## ការចេញដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ

**ផ្នែកទី១៖ ការចេញដីកាក្នុងករណីឃុំខ្លួនជនត្រូវចោទ**.........................................៤

**កថាខណ្ឌ ១៖ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន**..............................................៤

១.១. អត្ថន័យនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន..............................................៤

១.២. លក្ខខណ្ឌនៃការចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន.................................៥

១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចឱ្យឃុំបណ្ដោះអាសន្ន....................................៧

១.៤. នីតិវិធីដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន........................................................៧

១.៥. អានុភាពនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន................................................៨

១.៦. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន.................................១០

**កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យឃុំខ្លួន**...................................................................១១

២.១. អត្ថន័យនៃដីកាបង្គាប់ឱ្យឃុំខ្លួន.......................................................................១១

២.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យឃុំខ្លួន.........................................................១១

២.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យឃុំខ្លួន.....................................................១២

២.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន...........................................................១២

២.៥. អានុភាពនៃដីកាបង្គាប់ឱ្យឃុំខ្លួន.......................................................................១៣

**ផ្នែកទី២៖ ការចេញដីកាក្នុងករណីមិនឃុំខ្លួនជនត្រូវចោទ**..................................១៣

**កថាខណ្ឌ១៖ ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន**............................................១៣

១.១. អត្ថន័យនៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន..............................................១៣

១.២. លក្ខខណ្ឌនៃការចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន................................១៣

១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន............................១៤

១.៤. នីតិវិធីនៃការអនុវត្តដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន.................................១៤

១.៥. អានុភាពនៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន............................................១៥

១.៦. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន..............................១៥

**កថាខណ្ឌ២៖ ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**...............................................................................................១៦

២.១. អត្ថន័យនៃដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ....១៦

២.២. លក្ខខណ្ឌនៃដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ.១៦

២.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវ

តុលាការ.......................................................................................................................១៧
២.៤. នីតិវិធីនៃការអនុវត្តដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
....................................................................................................................................... ១៨
២.៥. អានុភាពនៃដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ...១៩
២.៦. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវ
តុលាការ.......................................................................................................................២០
**កថាខណ្ឌ៣៖ ដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវ
តុលាការ**.....................................................................................................២២
៣.១. អត្ថន័យនៃដីកាសម្រេចកែប្រែ ឬ បញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ..........២២
៣.២.លក្ខខណ្ឌនៃដីកាសម្រេចកែប្រែឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ ...........២២
៣.៣.អានុភាពនៃការដីកាដីកាសម្រេចកែប្រែឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូតុលាការ..២៣
**ផ្នែកទី៣៖ ការចេញដីកាក្នុងករណីដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន** .................២៤
**កថាខណ្ឌ១៖ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន**..............................២៤
១.១. អត្ថន័យនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន.......................................២៤
១.២. លក្ខខណ្ឌនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន.......................................២៥
១.៣. និទ្ទេសនៃដីការសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន........................................២៥
១.៤. នីតិវិធីនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន .........................................២៦
១.៥. អានុភាពនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ........................................២៨
**កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន**...................................២៨
២.១. អត្ថន័យនៃដីកាបង្គាប់ដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន .........................................២៨
២.២. លក្ខខណ្ឌនៃដីកាបង្គាប់ដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន.........................................២៨
២.៣. នីតិវិធីនៃដីកាបង្គាប់ដោះលែងឱ្យក្រៅឃុំបណ្ដោះអាសន្ន ................................................២៩
២.៤. អានុភាពនៃដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន .........................................២៩
**ផ្នែកទី៤៖ ការចេញដីកាក្នុងករណីមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន** ....២៩
**កថាខណ្ឌ ១៖ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន** .............២៩
១.១. អត្ថន័យនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន............................២៩
១.២. លក្ខខណ្ឌនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន..........................២៩
១.៣. និទ្ទេសនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន.............................៣០
១.៤. នីតិវិធីនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ...........................៣០
១.៥. អានុភាពនៃដីកាបង្គាប់ដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នបណ្ដោះអាសន្ន ..................៣២
**ផ្នែកទី៥៖ ការចេញដីកាក្នុងករណីមានសាងតាជាតិជនត្រូវចោទ**.................................៣៤
**កថាខណ្ឌ១៖ ដីកាបង្គាប់ឱ្យចូលខ្លួន**.........................................................................៣៤
១.១. អត្ថន័យនៃដីកាបង្គាប់ឱ្យចូលខ្លួន..........................................................................៣៤

១.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួនខ្លួន ........................................................ ៣៤
១.៣. និទ្ទេសដែលត្រូវចុះដីកាបង្គាប់ឱ្យចូលខ្លួន ........................................................ ៣៦
១.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន ........................................................ ៣៦
១.៥. អានុភាពនៃដីកាបង្គាប់ឱ្យចូលខ្លួន ........................................................ ៣៧
**កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យនាំខ្លួន** ........................................................ ៣៨
២.១. អត្ថន័យដីកាបង្គាប់ឱ្យនាំខ្លួន ........................................................ ៣៨
២.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួន ........................................................ ៣៨
២.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យនាំខ្លួន ........................................................ ៣៩
២.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ........................................................ ៤០
២.៥. អានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួន ........................................................ ៤២
**កថាខណ្ឌ៣៖ ដីកាបង្គាប់ឱ្យចាប់ខ្លួន** ........................................................ ៤២
៣.១. អត្ថន័យដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................ ៤២
៣.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................ ៤២
៣.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................ ៤៣
៣.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................ ៤៣
៣.៥. អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួន ........................................................ ៤៥
**ផ្នែកទី៦៖ ការចេញដីកាក្នុងករណីមិនមានសាវតាជាតិរបស់ជនត្រូវចោទ** ........................................................ ៤៥
**កថាខណ្ឌ១៖ ដីកាចាត់ឱ្យស៊ើបសួរជំនួស** ........................................................ ៤៥
១.១. អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស ........................................................ ៤៥
១.២. លក្ខខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស ........................................................ ៤៦
១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស ........................................................ ៤៦
១.៤. អានុភាពនៃដីកាចាត់ឱ្យស៊ើបសួរជំនួស ........................................................ ៤៧

## ជំពូកទី២
## ការចេញដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរចំពោះកិច្ចនៃនីតិវិធីដោយឡែក

**ផ្នែកទី១៖ ការចេញដីកាក្នុងកិច្ចស៊ើបសួរស្វែងរកការពិត** ........................................................ ៤៩
**កថាខណ្ឌ១៖ ដីកាបង្គាប់ឱ្យឆែកឆេរ** ........................................................ ៤៩
១.១. អត្ថន័យនៃដីកាបង្គាប់ឱ្យឆែកឆេរ ........................................................ ៤៩
១.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យឆែកឆេរ ........................................................ ៤៩
១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យឆែកឆេរ ........................................................ ៤៩
១.៤. អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួនឆែកឆេរ ........................................................ ៤៩

**កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ** ........................................ ៥៣
២.១. អត្ថន័យនៃដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ........................................៥៣
២.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យផែកឆេរ ........................................៥៣
២.៣. អានុភាពនៃដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ........................................៥៣
**កថាខណ្ឌ៣៖ ដីកាបង្គាប់ឱ្យចាប់ និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍**.... ៥៥
៣.១. អត្ថន័យនៃដីកាបង្គាប់ឱ្យចាប់និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍ .......... ៥៥
៣.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យចាត់និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍.......... ៥៥
៣.៣. នីតិវិធីនៃដីកាបង្គាប់ឱ្យចាប់និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍.......... ៥៥
៣.៤. អានុភាពនៃដីកាបង្គាប់ឱ្យចាប់និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍.......... ៥៦
**កថាខណ្ឌ៤៖ ដីកាសម្រេចបើកការស៊ើបសួរ**........................................ ៥៦
៤.១. អត្ថន័យនៃដីកាសម្រេចបើកការស៊ើបសួរ ........................................ ៥៦
៤.២. លក្ខខណ្ឌនៃដីកាសម្រេចបើកការស៊ើបសួរ........................................ ៥៦
៤.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចបើកការស៊ើបសួរ ........................................៥៧
៤.៤. នីតិវិធីនៃដីកាសម្រេចបើកការស៊ើបសួរ ........................................ ៥៨
៤.៥. អានុភាពនៃដីកាសម្រេចបើកការស៊ើបសួរ ........................................ ៥៨
**ផ្នែកទី២៖ ការចេញដីកាក្នុងការបំពេញកិច្ចស៊ើបសួរ**
**កថាខណ្ឌ១៖ ដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ**.................... ៦០
១.១. អត្ថន័យនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ.................... ៦០
១.២. លក្ខខណ្ឌនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ.................... ៦០
១.៣. និទ្ទេសនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ.................... ៦០
១.៤. នីតិវិធីការសម្រេចប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញ .................... ៦១
១.៥. អានុភាពនៃការប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ.................... ៦១
១.៦. សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ ........................................ ៦១
**កថាខណ្ឌ២៖ ដីកាដំណោះស្រាយ** ........................................ ៦១
២.១. និយមន័យដីកាដំណោះស្រាយ........................................ ៦១
២.២. លក្ខខណ្ឌនៃដីកាដំណោះស្រាយ ........................................ ៦១
២.៣. និទ្ទេសនៃដីកាដំណោះស្រាយ ........................................៦២
២.៤. អានុភាពនៃដីកាដំណោះស្រាយ ........................................៦២

**កថាខណ្ឌ៣៖ ដីកាបញ្ជូនលិខិត** ........ ៦៤
៣.១. អត្ថន័យនៃដីកាបញ្ជូនលិខិត ........ ៦៤
៣.២. លក្ខខណ្ឌនៃដីកាបញ្ជូនលិខិត ........ ៦៥
៣.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបញ្ជូនលិខិត ........ ៦៦
៣.៤. អានុភាពនៃដីកាបញ្ជូនលិខិត ........ ៦៦
**កថាខណ្ឌ៤៖ ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង** ........ ៦៦
៤.១. អត្ថន័យនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង ........ ៦៦
៤.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង ........ ៦៦
៤.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង ........ ៦៧
៤.៤. នីតិវិធីនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង ........ ៦៧
៤.៥. អានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង ........ ៦៧
**កថាខណ្ឌ៥៖ ដីកាចាត់តាំងអ្នកជំនាញ** ........ ៦៧
៥.១. អត្ថន័យនៃដីកាចាត់តាំងអ្នកជំនាញ ........ ៦៨
៥.២. លក្ខខណ្ឌនៃដីកាចាត់តាំងអ្នកជំនាញ ........ ៦៨
៥.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាចាត់តាំងអ្នកជំនាញ ........ ៦៩
៥.៤. នីតិវិធីនៃដីកាចាត់តាំងអ្នកជំនាញ ........ ៦៩
៥.៥. អានុភាពនៃដីកាចាត់អ្នកជំនាញ ........ ៦៩
**កថាខណ្ឌ៦៖ ដីកាសម្រេចបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ** ........ ៧០
៦.១. អត្ថន័យនៃដីកាសម្រេចបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ........ ៧០
៦.២. លក្ខខណ្ឌនៃដីកាសម្រេចបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ........ ៧០
៦.៣. នីតិវិធីនៃដីកាសម្រេចបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ........ ៧១
៦.៤. អានុភាពនៃដីកាសម្រេចបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ........ ៧២
**កថាខណ្ឌ៧៖ ដីកាសម្រេចឱ្យបង់ប្រាក់តម្កល់ទុក** ........ ៧២
៧.១. អត្ថន័យនៃដីកាសម្រេចឱ្យបង់ប្រាក់តម្កល់ទុក ........ ៧២
៧.២. លក្ខខណ្ឌនៃដីកាសម្រេចឱ្យបង់ប្រាក់តម្កល់ទុក ........ ៧២
៧.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចឱ្យបង់ប្រាក់តម្កល់ទុក ........ ៧២
៧.៤. នីតិវិធីនៃដីកាសម្រេចឱ្យបង់ប្រាក់តម្កល់ទុក ........ ៧៣
៧.៥. អានុភាពនៃដីកាសម្រេចឱ្យបង់ប្រាក់តម្កល់ទុក ........ ៧៣

**សេចក្ដីសន្និដ្ឋាន**.................................................................................................... ៧៤
**អនុសាសន៍**.................................................................................................... ៧៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ដោយបានឆ្លងកាត់ការសិក្សានៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ (ច្បាប់)ឆ្នាំទី៣ ដែលបានផ្ដោតទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌតាមកម្មវិធី សិក្សារបស់សាកលវិទ្យាល័យ បានទទួលនូវចំណេះដឹង និងគំនិតបន្តិចបន្តួចទៅលើមូលដ្ឋាន នៃនីតិវិធីព្រហ្មទណ្ឌសម្រាប់ធ្វើការស្រាវជ្រាវបន្ថែមក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដែលបានផ្ដោតសំខាន់តែទៅលើគោលការណ៍ទូទៅ និងវិធានការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ។ ជាពិសេស ចៅក្រមស៊ើបសួរមានសិទ្ធិបើកការស៊ើបសួរ និងស្រាវជ្រាវរកបទល្មើសព្រហ្មទណ្ឌ តាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបរបស់ព្រះរាជអាជ្ញា រហូតដល់ការបញ្ចប់កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរតាមរយៈដីកាដំណោះស្រាយផងដែរ។

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ដំណាក់កាល នៃការវិនិច្ឆ័យបទល្មើសដល់ជនល្មើសត្រូវឆ្លងកាត់នូវដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ដែល កសាងសំណុំរឿងបន្តមកដល់ដំណាក់កាលរបស់អយ្យការអមសាលាដំបូងខេត្ត/រាជធានី ដើម្បីចំណាត់ការបន្តរហូតមកដល់ដំណាក់កាលចៅក្រមស៊ើបសួរ និងចុងក្រោយ គឺដំណាក់កាលជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ។

នីតិវិធីនេះ គឺជាតួនាទីរបស់ចៅក្រមនៃដំណាក់កាលស៊ើបសួរ និងជាដំណាក់កាលមួយនៅចន្លោះដំណាក់កាលនៃការចោទប្រកាន់ដោយអយ្យការ និងដំណាក់កាលនៃការជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌ។ ជាទូទៅ ការស៊ើបសួរនេះ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ចៅក្រមមួយរូប ដែលគេឱ្យឈ្មោះថា ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរ មានករណីកិច្ចស៊ើបសួរទាំង ភស្ដុតាងដាក់បន្ទុក និងភស្ដុតាងដោះបន្ទុក ហើយអាចបំពេញកិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ សម្រាប់បង្ហាញឱ្យចៅក្រមស៊ើបសួរអាចបំពេញមុខងាររបស់ខ្លួន ហើយនៅដំណាក់កាលស៊ើបសួរនេះ នៅក្នុងការបំពេញកាតព្វកិច្ចចៅក្រមស៊ើបសួរមានការពាក់ព័ន្ធទៅនឹងដីកាជាច្រើន ដែលមានគោលដៅស្វែងរកការពិត និងមានការបិទសិទ្ធិសេរីភាពបុគ្គលមួយចំនួន នៅក្នុងរឿងក្ដីនីមួយៗ។

ដោយសង្កេតឃើញកត្តាទាំងនេះ ទើបធ្វើឱ្យក្រុមរបស់យើងខ្ញុំសម្រេចលើកយកប្រធានបទដែលស្ដីអំពី **ដីកាក្នុងរឿងក្ដីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ** មកសរសេរក្នុងរបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ដើម្បីឆ្លុះបញ្ចាំងនូវទិដ្ឋភាព និងការអនុវត្តជាក់ ស្ដែងរបស់ចៅក្រមស៊ើបសួរ។

ការចេញដីកាមួយៗ តម្រូវឱ្យចៅក្រមស៊ើបសួរមានការសិក្សាស្រាវជ្រាវទៅលើបទល្មើស ដែលសម្រេចយ៉ាងម៉ត់ចត់គប្បីត្រូវប្រើប្រាស់ដីកាប្រភេទអ្វី ដើម្បីកំណត់អោយបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះឱ្យមានសេរីភាព ឬមិនឱ្យមានសេរីភាព។ ដូចនេះហើយហេតុផលដ៏សំខាន់នៃការសិក្សាស្រាវជ្រាវនេះ បានផ្ដោតទៅលើចំណោទបញ្ហាសំខាន់ៗដូចខាងក្រោម៖

**១. តើដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ មានអ្វីខ្លះ?**

**២. តើដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ ចំពោះកិច្ចនីតិវិធីដោយឡែក មានអ្វីខ្លះ?**

ការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីអំពី **ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ** គឺធ្វើឡើងក្នុងគោលបំណងសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីទ្រឹស្តីគតិយុត្តិដោយផ្សារភ្ជាប់ នឹងការអនុវត្តជាក់ស្តែង នឹងដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរនៅក្នុងសាលាដំបូងរាជធានីភ្នំពេញ ម្យ៉ាងវិញទៀត អាចយល់ដឹងនូវការអនុវត្ត និងនីតិវិធីចេញដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញផងដែរ។

ការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងត្រឹមតែទ្រឹស្តីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងការអនុវត្តជាក់ស្តែងរបស់ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ តែប៉ុណ្ណោះ។

ការសិក្សាស្រាវជ្រាវនេះ លើប្រធានបទខាងលើនេះ គឺបានប្រើប្រាស់វិធីសាស្ត្រវិភាគគោលការណ៍ច្បាប់ និងទ្រឹស្តីតាមបែបពណ៌នា និងរិះរកវិធីពង្រឹង និងដោះស្រាយ ដើម្បីជាយុទ្ធសាស្ត្រនៅក្នុងការបង្កើនសក្តានុពលដល់អាជ្ញាធរមានសមត្ថកិច្ចអនុវត្តច្បាប់ ដើម្បីឱ្យធ្វើការកំណត់នូវបទល្មើសស្របទៅតាមច្បាប់។ បន្ថែមពីនេះទៅទៀត ដើម្បីសម្រេចបាននូវលទ្ធផលពីការសិក្សាស្រាវជ្រាវ ទោះលើប្រធានបទ ដែលស្តីអំពី ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរឱ្យទទួលបានជោគជ័យ របាយការណ៍នេះ បានអនុវត្តទៅតាមលំនាំវិធីសាស្ត្រវិភាគបែបលក្ខណៈវិទ្យាសាស្ត្រ និងមាននីតិវិធីសំខាន់ៗ មួយចំនួនទៀតដូចខាងក្រោម ៖

វិធីសាស្ត្រប្រមូលទិន្នន័យ ៖ ដោយបានស្វែងរកខ្លឹមសារៗ និងចាំបាច់នៃចំណុចគោលដែលទាក់ទងនឹងប្រធានបទ ជាពិសេសស្វែងរកឯកសារនានានៅតាមបណ្ណាល័យ និងនៅតាមស្ថាប័នមួយចំនួន។

តម្រូវការព័ត៌មាន ៖ កត្តាតម្រូវការព័ត៌មាននេះ គឺផ្អែកលើការសិក្សាស្រាវជ្រាវតាមរយៈការអាន ការវិភាគសារព័ត៌មាន ព្រឹត្តបត្រ ទស្សនាវដ្តី និង ឯកសារស្នាដៃរបស់អ្នកនិពន្ធមួយចំនួន ដែលមានទឡ្ហីករណ៍ជាក់ស្តែង និងមានលក្ខណៈវិទ្យាសាស្ត្រ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ដោយមានការជាប់ទាក់ទងទៅនឹងការកំណត់នូវដីកា។ ដោយឡែក គឺតាមរយៈសារព័ត៌មាន( អ៊ិនធើណេត ទូរទស្សន៍ វិទ្យុ កាសែត ) គ្រប់មជ្ឈដ្ឋានដែលមានការពាក់ព័ន្ធនឹងដីកា។

យើងខ្ញុំទាំងពីរនាក់ សង្ឃឹមថាការសិក្សាស្រាវជ្រាវដែលស្តីអំពី ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ នេះនឹងចូលរួមចំណែកក្នុងវិស័យយុត្តិធម៌និង កំណែទម្រង់ច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង។

**ប្រធានបទ ដីកាក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ** ត្រូវបានចែកជា ៖

- **សេចក្តីផ្តើម**
- **ជំពូកទី១ ដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ**

- **ជំពូកទី២ ដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ ចំពោះកិច្ចនីតិវិធីដោយឡែក**
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

# ជំពូកទី ១
# ការចេញដីកាផ្សេងៗ
# របស់ចៅក្រមស៊ើបសួរ

# ជំពូកទី១

# ការចេញដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ ក្នុងករណីមានវត្តមានជនត្រូវចោទ

## និយមន័យដីកា

ដីកា គឺជាបញ្ជាដែលលាយលក្ខណ៍អក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ច ដែលបង្គាប់ឱ្យចាត់ការនូវ អំពើណាម្យ៉ាងជាពិសេស បញ្ជាដែលបង្គាប់ឱ្យ ចាប់ខ្លួន ជនណាម្នាក់ ឬច្រើននាក់ ដែលចេញដោយតុលាការអង្គការ ឬមន្ត្រី ផ្លូវការណាម្នាក់។

## និយមន័យ ការស៊ើបសួរ

ការស៊ើបសួរ គឺជាសិទ្ធិក្នុងការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរដើម្បីការស្រាវជ្រាវចំពោះ អង្គហេតុនៃបទព្រហ្មទណ្ឌ ក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាដោយ អនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះកិច្ចស៊ើបសួរទាំងអស់ នេះត្រូវអនុវត្ត និងដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ពន្ធ័ ដែលបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្តើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ។ ការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះ បទឧក្រិដ្ឋ។ រីឯចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន ។

រាល់ការចូលរួមស្រាវជ្រាវរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ ក្នុងដំណាក់កាលស៊ើបសួរ ត្រូវតែរក្សាការសម្ងាត់។ ជាគោលការណ៍ ដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែស្វែងរកភស្តុតាង ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដើម្បីផ្តល់ភាពយុត្តិធម៌ជូនជនល្មើស និងជនរងគ្រោះ។ ចំពោះកិច្ចស្រាវជ្រាវនេះមានដូចជា កិច្ចស្រាវជ្រាវចំពោះអង្គហេតុ ដែលជាការស្រាវជ្រាវ ដើម្បីបញ្ជាក់ឱ្យឃើញថាមានអង្គហេតុដែលបង្កជាបទល្មើស ឬគ្មានបទល្មើសដូចដែលមានកំណត់ក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងម្យ៉ាងទៀត គឺជាកិច្ចស្រាវជ្រាវ ដែលទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ថាតើជនត្រូវចោទមានសមត្ថភាពទទួលខុសត្រូវ ព្រហ្មទណ្ឌដែរ ឬ យ៉ាងណា?

## ផ្នែកទី១៖ ការចេញដីកាក្នុងករណីឃុំខ្លួនជនត្រូវចោទ

### កថាខណ្ឌ១. ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន

#### ១.១ អត្ថន័យដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន

ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងការឃុំខ្លួន ជនត្រូវចោទបណ្តោះអាសន្ន ដើម្បីធានារក្សាកិច្ចស៊ើបសួររកការពិតនៃរឿងឱ្យបានល្អ។

ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នអាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ប៉ុន្តែមិនអាចជាកម្មវត្ថុនៃការយកទៅអនុវត្តឃុំខ្លួនផ្ទាល់តែម្តងនោះទេ។ វាអាចអនុវត្តក្នុងការឃុំខ្លួនជនដែលជាកម្មវត្ថុនៃការសម្រេចឃុំខ្លួនបណ្តោះ

អាសន្នបាន លុះត្រាតែចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួនមួយផ្សេងបន្ថែមទៀត។

### ១.២. លក្ខខណ្ឌនៃការចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន [1]។ ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់កំណត់ឱ្យផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ (មួយ) ឆ្នាំ [2]។ ផ្ទុយទៅវិញ ទោះបីជាបទមជ្ឈិម ក៏ដោយប៉ុន្តែ ប្រសិនបទល្មើសនោះមិនត្រូវបានកំណត់ (ទោសបញ្ញត្តិ)ឱ្យផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពីមួយឆ្នាំ នោះទេ ចៅក្រមស៊ើបសួរមិនអាចសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទបានឡើយ ។

**ឧទាហរណ៍៖ បទគំរាមកំហែង ( មាត្រា ២៣១ )** នៃក្រមព្រហ្មទណ្ឌ ២០០៩ ចែងថា អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់១០០.០០០(មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន)រៀល។

**ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងបានដោយយោងលើមូលហេតុចាំបាច់ដូចខាងក្រោម៖**[3]

#### ក. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី

នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបនៃការឃុំខ្លួន អាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។ តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសដែលខ្លួនត្រូវចោទទេ? តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើសនោះជាថ្មីទេ?

#### ខ. ដើម្បីរារាំង កុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត

ចៅក្រមស៊ើបសួរ ត្រូវពន្យល់អំពីរបៀបដែលការឃុំខ្លួនអាចរារាំង ដល់ការគាបសង្កត់សាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង ជនសមគំនិត។ តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថាជនត្រូវចោទអាចគាបសង្កត់សាក្សី ឬ ជនរងគ្រោះដែរ ឬទេ?

#### គ.ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ

ចៅក្រមស៊ើបសួរ ត្រូវពន្យល់អំពីរបៀបដែលការឃុំខ្លួន អាចរារាំងដល់ជនត្រូវចោទពីការធ្វើឱ្យខូចភស្តុតាង ឬតម្រុយជាសម្ភារៈ។ តើនៅតែមានភស្តុតាង ឬតម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរ ឬទេ?

---

[1] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ។

[2] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ។

[3] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ។

តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬ តម្រុយជាសម្ភារៈទេ?

**ឃ.ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី**

ចៅក្រមស៊ើបសួរ ត្រូវពន្យល់អំពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការតាមនីតិវិធី។ តើមានហេតុផលសម្រេចដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួននៅក្រៅប្រទេសដែរ ឬទេ?

**ង.ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ**

ចៅក្រមស៊ើបសួរ ត្រូវពន្យល់អំពីរបៀបសដែលការឃុំខ្លួន អាចការពារសន្តិសុខឱ្យជនត្រូវចោទ។ តើមានយោបល់ណាមួយដែលថាជាជនរងគ្រោះ ឬជនផ្សេងទៀតអាចបង្ករ គ្រោះថ្នាក់ដល់ជនត្រូវចោទ ឬទេ?

**ច.ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស**

ចៅក្រមស៊ើបសួរ ត្រូវពន្យល់អំពីរបៀបដែលការឃុំខ្លួន អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ណាមួយដែលបណ្តាលអោយមកពីបទល្មើសនេះ។

ចៅក្រមស៊ើបសួរ មុននឹងធ្វើការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ទៅលើជនត្រូវចោទ ចៅក្រមរូបនេះត្រូវតែមានមូលដ្ឋាន និងទឡ្ហីករណ៍រឹងមាំ ដើម្បីបង្ហាញឱ្យឃើញថាការដោះលែងជនត្រូវចោទពិតជាបានធ្វើឱ្យមានការរំខានយ៉ាងជាក់ស្តែងដល់សណ្តាប់ធ្នាប់សាធារណៈជាក់ស្តែងរបស់បុគ្គលដែលរួមមានបុគ្គលលក្ខណៈស្ថានភាពផ្លូវចិត្ត របស់បុគ្គលរួមទាំងពិសោធន៍ និងចំណេះដឹងខ្ពស់របស់ចៅក្រមផងដែរ។

**មូលហេតុខាងលើនេះជាលក្ខខណ្ឌចាំបាច់ ដែលអាចឱ្យចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទបាន។**

យ៉ាងណាមិញ មាត្រា ៣៩ កថាខណ្ឌ ចុងក្រោយនៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០៩ ចែងថា "តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤(ដប់បួនឆ្នាំ) ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ នេះមានន័យថា ចំពោះអនីតិជនដែលអាយុក្រោម ១៤ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួនឡើយ។ ហេតុនេះវិធានការនៃការសម្រេចឃុំខ្លួនរបស់ចៅក្រមស៊ើបសួរទៅលើអនីតិជនដែលមានអាយុស្ថិតក្នុងលក្ខខណ្ឌនេះ គឺមិនអាចធ្វើឡើងបានទេ។

ជាការឆ្លើយតបទៅនឹងបញ្ញត្តិខាងលើ មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានកំណត់បញ្ជាក់ផងដែល ថាអនីតិជនអាយុតិចជាង ១៤ (ដប់បួនឆ្នាំ) មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ពោលគឺ បុគ្គលដែលមានអាយុ (តិចជាង១៤ឆ្នាំ) ស្ថិតក្នុងនៅក្នុងលក្ខខណ្ឌដូចបានកំណត់ខាងលើ មិនអាចជាកម្មវត្ថុនៃការសម្រេច

ឃុំខ្លួនបណ្តោះអាសន្ននោះទេ។ ចៅក្រមស៊ើបសួរ អាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយ អ្នកអាណាព្យាបាលឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំ កែប្រែរក្សាបណ្តោះអាសន្ន ដើម្បីរង់ចាំសេចក្តីសម្រេចរបស់តុលាការ។

**១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន**

**ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចខាងក្រោម** [4]៖

-ឈ្មោះចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

-អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅឋានរបស់ជនត្រូវចោទ ប្រសិនបើមានពិរុទ្ធកម្មប្រកាស (ធ្លាប់មានទោស ឬ អត់) ។

-លេខ និង កាលបរិច្ឆេទនៃការធ្វើដីកា។

និទ្ទេសខាងលើនេះជាចំនុចសំខាន់ចាំបាច់ ដែលតម្រូវឲ្យមានចុះក្នុងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ។

**១.៤. នីតិវិធីនៃការចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន**

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចថា និងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវឱ្យ ដំណឹងដល់ជនត្រូវចោទ តាមរយៈការធ្វើកំណត់ហេតុ ស្តីពីការពិភាក្សាដេញដោលចំពោះមុខ និងត្រូវទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន[5]។ ពោលគឺក្នុងករណីនេះ ចៅក្រមស៊ើបសួរពុំចាំបាច់ ជូនដំណឹងដល់ព្រះរាជអាជ្ញាទៀតនោះទេ។ ប៉ុន្តែ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថា និងឃុំខ្លួនជនត្រូវចោទដោយគំនិតផ្តើមរបស់ខ្លួនគាត់ ត្រូវជូនដំណឹងអំពីការឃុំខ្លួននេះភ្លាមដល់ព្រះរាជអាជ្ញា និងប្រាប់ទៅជនត្រូវចោទដែលត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ។ ការជូនដំណឹងទៅព្រះរាជអាជ្ញាត្រូវធ្វើនៅក្នុងកំឡុងពេល៥ថ្ងៃយ៉ាងយូរបំផុត។ ចំពោះការជូនដំណឹង អំពីការឃុំខ្លួនជនត្រូវចោទ គឺធ្វើឡើងភ្លាម តាមរយៈកំណត់ហេតុស្តីពីការពិភាក្សដេញដោលចំពោះមុខ។ ចៅក្រមស៊ើបសួរ

[4] មាត្រា ២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ ។

[5] ការផ្តល់មធ្យាបាយការពារខ្លួនរបស់មេធាវីជនត្រូវចោទ អាចជាការបង្ហាញភស្តុតាង ឬការស្នើសុំឱ្យចៅក្រមស៊ើបសួរកុំធ្វើការឃុំខ្លួនកូនក្តីរបស់ខ្លួន និងដោយមានដាក់ប្រាក់ធានាផ្សេងៗ។

សម្រេចឃុំខ្លួនជនត្រូវចោទចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនជនត្រូវចោទ បណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុ នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ [6]។

### ១.៥. អានុភាពនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន

#### ក. អានុភាពនៃការឃុំខ្លួនចំពោះនីតិជន

##### ក.១. អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ

ចំពោះនីតិជន ដែលត្រូវចោទប្រកាន់ ពីបទឧក្រិដ្ឋការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើស ពី ៦ (ប្រាំមួយ) ខែបានទេ[7]។ ប៉ុន្តែនៅពេលផុតចិរវេលានេះចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្តោះអាសន្ន (តាមដីកាសម្រេចពន្យារ ពេលឃុំខ្លួនបណ្តោះអាសន្ន) ម្តងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាង ហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ (ពីរ) ដងគត់ ។

សូមបញ្ជាក់ផងដែរថាដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងករណី នេះមានអានុភាពក្នុងការឃុំខ្លួនជនណាម្នាក់បានត្រឹមតែរយៈពេល៦ (ប្រាំមួយ) ខែប៉ុណ្ណោះ។ ចំពោះការឃុំខ្លួនបន្ថែមដែលមានរយៈពេល១២ខែទៀត មិនមែនជាការឃុំខ្លួនដែលកើតចេញ ពីអានុភាពផ្ទាល់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទេ។ ប៉ុន្តែវាជាអានុភាពដែលកើតចេញពី ដីកាសម្រេចឱ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្នទៅវិញ។

##### ក.២.អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹម

ចំពោះ នីតិជនដែលត្រូវចោទប្រកាន់ពី បទមជ្ឈឹម ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ (បួន) ខែបានទេ។

ប៉ុន្តែនៅពេល ផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួន បណ្តោះអាសន្នបានតែ ម្តងគត់ មិនឱ្យ លើសពី ២ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចិរវេលានៃការ ឃុំខ្លួនបណ្តោះអាសន្ន ខាងលើនេះមិនត្រូវលើស ពីពាក់កណ្តាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់ឡើយ ។

ដូចគ្នាផងដែលដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីនេះមានអានុភាពក្នុងការឃុំខ្លួនជនណាម្នាក់បានត្រឹមតែរយៈពេល ៤ (បួនខែ) ប៉ុណ្ណោះ។ ចំពោះការឃុំខ្លួនបន្ថែមដែលមានរយៈពេល២ (ពីរខែ) ឬមិនត្រូវលើសពីពាក់កណ្តាល នៃអប្បបរមានៃទោសទៀតនោះ មិនមែនជាការឃុំខ្លួនដែលកើតចេញពីអានុភាពផ្ទាល់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទេ។ ប៉ុន្តែវាជាអានុភាពដែលកើតចេញ ពីដីកាសម្រេចឱ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្នវិញ។

[6] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[7] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

### ខ. អានុភាពនៃការឃុំខ្លួនក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង បទឧក្រិដ្ឋកម្មសង្គ្រាម

ក្នុងករណីដែលមានការចោទប្រកាន់ពី បទឧក្រិដ្ឋមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋសង្គ្រាមការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ១(មួយ) ឆ្នាំ បានទេចំពោះបទល្មើសនីមួយៗ[8] ។

ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវនិងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបាន តែ ២(ពីរ)ដងគត់។

ដូចករណីទាំងពីរខាងលើផងដែល ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីនេះមានក្នុងការឃុំខ្លួនជនណាម្នាក់បានត្រឹមតែរយៈពេល ១ឆ្នាំប៉ុណ្ណោះ។ ចំពោះការឃុំខ្លួនបន្ថែមដែលមានរយៈពេល ២ឆ្នាំទៀតនោះ មិនមែនជាការឃុំខ្លួនដែលកើតចេញពីអានុភាពផ្ទាល់ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែវាជាអានុភាពដែលកើតចេញដីកាសម្រេចឱ្យពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន។

### គ. អានុភាពនៃការឃុំខ្លួនចំពោះអនីតិជន

#### គ.១. អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ [9]៖

ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន)ខែ បានទេ កាលណាអនីតិជននោះមានអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ។

#### គ.២. អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ [10]៖

ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២(ពីរ)ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ)ឆ្នាំ ។

ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤(បួន)ខែបានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦(ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

---

[8] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[9] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[10] មាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី១ និង ចំណុចទី២ ខាងលើនេះមិនត្រូវលើសពីពាក់កណ្ដាលអប្បបរមានៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។

### ១.៦. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

#### ក. ភាគីដែលអាចធ្វើបណ្ដឹងឧទ្ធរណ៍

ជាទូទៅភាគីដែលធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំង នឹងដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរទៅចំពោះមុខសភាស៊ើបសួរមានជាអាទិ៍ ៖

-អគ្គព្រះរាជអាជ្ញា

-ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង

-ជនត្រូវចោទផ្ទាល់

-មេធាវីដែលទទួលសិទ្ធិតំណាងដោយអាណត្តិឲ្យជនត្រូវចោទ

#### ខ. រយៈពេលនៃការធ្វើបណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ប្រឆាំង នឹងដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ត្រូវធ្វើក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរគិតពីថ្ងៃឃុំខ្លួន។ តែសម្រាប់ការប្ដឹងឧទ្ធរណ៍របស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល ១ (មួយ) ខែយ៉ាងយូរគិតពីពេលប្រកាសដីកា។

**បណ្ដឹងនេះអាចធ្វើឡើងនៅចំពោះមុខ** [11]៖

-ក្រឡាបញ្ជីនៃតុលាការជាន់ដំបូង (សាលាដំបូងសាមី)

-ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន

ក្នុងករណីទទួលបានការប្រកាសប្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ នៅក្នុងពន្ធនាគារ ឬមណ្ឌល ឃុំខ្លួន ប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនត្រូវប្រគល់ភ្លាមនូវលិខិត ប្ដឹងឧទ្ធរណ៍មួយច្បាប់ជូនទៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ ប្រសិនបើក្រឡាបញ្ជីនៃតុលាការជាន់ ដំបូងបានទទួលបណ្ដឹងផ្ទាល់ ខ្លួនត្រូវជូនដំណឹង ភ្លាមដល់ចៅក្រមស៊ើបសួររៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរដោយមានសេចក្ដីចម្លងនៃលិខិតប្ដឹងឧទ្ធរណ៍ភ្ជាប់ជាមួយ។

សេចក្ដីចម្លងនេះត្រូវធ្វើឡើងដោយ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងក្រោយពីបានឃើញនិទ្ទេសដែលចុះបញ្ជីបណ្ដឹងឧទ្ធរណ៍។ សំណុំរឿងនេះ ត្រូវបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ នៅក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីមានបណ្ដឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈ ដែលមិនអាចជំនះបាន [12]។

---

[11] មាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[12] មាត្រា ២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ចំពោះដីកាណាមួយក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លែកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់ប្រធានសភាស៊ើបសួរ។ សេចក្តីសម្រេចនេះមិនអាចតវ៉ាបានឡើយ [13]។

**គ. ការសម្រេចសេចក្តីដោយសភាស៊ើបសួរ**

ក្នុងករណីនេះ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ត្រូវចេញសេចក្តីសម្រេច (យល់ព្រមឱ្យនៅក្រៅឃុំ ឬមិនយល់ព្រមឱ្យនៅក្រៅឃុំ) តាមរយៈសាលាដីការបស់ខ្លួន ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យ ក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនេះជនត្រូវចោទបានដោះលែងឱ្យនៅក្រៅឃុំលើកលែងតែក្នុងករណី ដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ ឬករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះបង្កជាឧបសគ្គមិនឱ្យប្រកាសសាលាដីកាបាននៅក្នុងរយៈពេលនេះ។

កាលណាសភាស៊ើបសួរបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នសភាស៊ើបសួរត្រូវសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួនដោយទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ។ ប្រធានសភាស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន។ យ៉ាងណាមិញសំណុំរឿងត្រូវបង្វិលជាបន្ទាន់ទៅចៅក្រមស៊ើបសួរវិញ ក្រោយពីបានអនុវត្តសាលដីការួច [14]។

**កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យឃុំខ្លួន**

**២.១. អត្ថន័យនៃដីកាបង្គាប់ឱ្យឃុំខ្លួន**

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន[15]។ ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនជនត្រូវចោទ[16]។ ចៅក្រមស៊ើបសួរអាច ចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែបន្ទាប់ពីចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។

**២.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យឃុំខ្លួន**

ចៅក្រមស៊ើបសួរ សម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន[17]។ បានន័យថាលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យឃុំខ្លួន គឺអាចប្រព្រឹត្តទៅបានបន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចធ្វើការឃុំខ្លួនជនណាម្នាក់តាមរយៈដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នបានទេ។

[13] មាត្រា ២៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

[14] មាត្រា ២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[15] មាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[16] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[17] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទ មុនការសម្រេចឃុំខ្លួន (ដីកាសម្រេចឃុំខ្លួនបណ្ដោះ អាសន្ន) ។

**និយាយជារួមមក ការចេញដីកាឱ្យឃុំខ្លួន ធ្វើឡើងដោយឈរលើមូលដ្ឋាន(មូលហេតុ) នៃការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន(ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន)ទាំងស្រុង ។**

### ២.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះនិទ្ទេសសំខាន់ដូចតទៅ ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទបទល្មើសដែលបានចោទប្រកាន់ និង អត្ថបទច្បាប់ដែលកំណត់ និងបង្កជាបទល្មើស
- ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវមានចុះលេខនៃការទាញដីកាត្រូវស្របតាមលំដាប់លេខរៀងនៃសៀវភៅ ចុះលេខដីកាបង្គាប់ឱ្យឃុំខ្លួន។

*ដីកានេះបង្គាប់ឱ្យឃុំខ្លួន ត្រូវមានចុះកាលបរិច្ឆេទចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងមានបោះត្រាផង។*

តាមការអនុវត្ត ជាក់ស្ដែងដីកានេះក៏ត្រូវមានចុះលេខរៀងនៃការឃុំខ្លួន តាមលំដាប់លេខរៀងនៃកាឃុំខ្លួនដូចមានក្នុងសៀវភៅចុះលេខដីកាបង្គាប់ឱ្យឃុំខ្លួន។

រាល់និទ្ទេសទាំងឡាយដែលមានចុះក្នុងដីកានេះ ត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់ជា ពិសេសសាវតាជាតិរបស់បុគ្គលដែលជាកម្មវត្ថុនៃការឃុំខ្លួន គឺជាជៀសវាងលើការឃុំខ្លួនច្រឡំ ដែលនាំឱ្យមានមោឃភាព និងបង្កើតជាបទល្មើសព្រហ្មទណ្ឌមួយឡើង [18]។

### ២.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន

ចំពោះអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន ដីកានេះត្រូវយកទៅអនុវត្តដោយ ប្រធានពន្ធនាគារមណ្ឌល ឃុំខ្លួនកន្លែងដែលបុគ្គលនោះឃុំខ្លួន។ ប៉ុន្តែក្នុងលក្ខខណ្ឌដែលបុគ្គល ដែលត្រូវឃុំខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌នៅឡើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនជនត្រូវចោទ ឬ ជាប់ពាក់ពន្ធ័នោះទៅកាន់ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដូចមានបញ្ជាក់ចង្អុលបង្ហាញតាមរយៈដីកាបង្គាប់ឱ្យឃុំខ្លួន។

---

[18] មាត្រា ២២១ និងមាត្រា ២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០៧ ។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែមានការទទួលដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ម្យ៉ាងវិញទៀតប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុក ដើម្បីការបង្គាប់អោយឃុំខ្លួន ឬ ចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់។

**២.៥. អានុភាពនៃដីកាបង្គាប់ឱ្យឃុំខ្លួន**

ដីកាបង្គាប់ឱ្យឃុំខ្លួនមានអានុភាពផ្ទាល់ក្នុងការបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។ ដីកាបង្គាប់ឱ្យឃុំខ្លួន មិនអាចជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នោះទេ។

ប្រសិនបើប្រធានពន្ធនាគារក្ដី ឬប្រធានមណ្ឌលឃុំខ្លួនក្ដី បានទទួលឃុំខ្លួនជនណាម្នាក់ដោយគ្មានដីកាបង្គាប់ឱ្យឃុំពីសំណាក់អាជ្ញាធរតុលាការ នោះប្រធានពន្ធនាគារ ឬប្រធានមណ្ឌលឃុំខ្លួនអាចប្រឈមនឹងការប្រព្រឹត្តបទល្មើស ទាក់ទងនឹងការបង្ខាំងមនុស្សដោយខុសច្បាប់។

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាលិខិតឃុំខ្លួនស្របច្បាប់របស់អាជ្ញាធរតុលាការ ដែលត្រូវបានប្រើប្រាស់បំពេញបន្ថែមលើ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ នេះមានន័យថាកម្មវត្ថុនៃដីកាបង្គាប់ឱ្យឃុំខ្លួន គឺឈរលើកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ ហេតុនេះអានុភាពសម្រាប់ដីកាបង្គាប់ឱ្យឃុំខ្លួន គឺកើតចេញផ្ទាល់ពីអានុភាពនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។

## ផ្នែកទី២៖ ការចេញដីកាក្នុងករណីមិនឃុំខ្លួនជនត្រូវចោទ

### កថាខណ្ឌ១៖ ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

**១.១. អត្ថន័យនៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន**

ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន គឺជាសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរមិនធ្វើការ ឃុំខ្លួនជនត្រូវចោទប្រសិនបើខ្លួនយល់ឃើញថា លក្ខខណ្ឌនៃការឃុំខ្លួនមិនមែនជាវិធានការចាំបាច់។

**១.២. លក្ខខណ្ឌនៃការចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន**

ចៅក្រមស៊ើបសួរអាចសម្រេចមិនធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន តាមគំនិតផ្ដើមផ្ទាល់របស់ខ្លួន ឬតាមសេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់ព្រះរាជអាជ្ញា [19]។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចចេញ ដីកានេះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ។

ជាទូទៅការចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទណាម្នាក់ មិនចាំបាច់តម្រូវឱ្យចៅក្រមស៊ើបសួរបញ្ជាក់អំពីមូលហេតុ (សំអាងហេតុ) នោះទេ។ ប៉ុន្តែតាមរយៈការអនុវត្តជាក់ស្ដែង ជាធម្មតាកាលណាចៅក្រមស៊ើបសួរចេញដីកាសម្រេច មិនធ្វើការឃុំជនណាម្នាក់ គឺដោយសារតែ មិនមានមូលហេតុចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្ន ដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុផលផ្សេង

[19] មាត្រា ២០៧ និងមាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ទៀត ការសម្រេចមិនឃុំខ្លួនជនត្រូវចោទគឺ ដោយចៅក្រមស៊ើបសួរយល់ឃើញថាវិធាននៃការឃុំខ្លួនមិនស្ថិតក្នុងលក្ខខណ្ឌ នៃជម្រើសរបស់ខ្លួន[20] ឬការឃុំខ្លួនមិនមែនជាវិធានការចាំបាច់។ ផ្ទុយទៅវិញ វិធានការនៃការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជាវិធានការគ្រប់គ្រាន់។ ការសម្រេចរបស់ចៅក្រមស៊ើបសួរ មិនឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន តែងតែត្រូវបានបំពេញបន្ថែមដោយវិធានការផ្សេងទៀត ពោលគឺការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ តាមរយៈដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាវិធានការមួយមានចរិកលក្ខណៈស្រាល ជាងការឃុំខ្លួនបណ្តោះអាសន្ន ព្រោះវាគ្រាន់តែជាការរឹតបន្តឹងនូវសេរីភាពរបស់បុគ្គលត្រូវចោទប៉ុណ្ណោះ រីឯការឃុំខ្លួនបណ្តោះអាសន្ន វាបានដកហូតនូវសេរីភាពរបស់បុគ្គលត្រូវចោទយ៉ាងច្រើនដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពយ៉ាងខ្លាំង។

### ១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នមានចុះនិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅ៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ដីកា នេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន។

ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួររួមទាំងក្រឡាបញ្ជីនិងមានបោះត្រាផង។

### ១.៤. នីតិវិធីនៃការអនុវត្តដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដីកានេះនឹងត្រូវយកទៅប្រតិបត្តិផ្ទាល់ ដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើការឃាត់ខ្លួនបុគ្គលត្រូវចោទ។ នៅពេលពេល ទទួលបានដីកានេះ មន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើការឃាត់ខ្លួនបុគ្គលត្រូវចោទឱ្យត្រលប់ទៅលំនៅឋានវិញភ្លាម

[20] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ចែងថា "ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ។

ដោយមិនអាចបន្តការឃាត់ខ្លួនជនត្រូវចោទទៀតទេ ទោះបីជាមានប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញអមសាលាឧទ្ធរណ៍ ទៅចំពោះមុខសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ក៏ដោយ។

### ១.៥. អានុភាពនៃដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន មានអានុភាពអនុវត្តភ្លាមដោយមិនចាំបាច់រង់ចាំការសម្រេចលើបណ្តឹង ឧទ្ធរណ៍ដោយស៊ើបសួររបស់ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញានោះទេ។ មានន័យថា បន្ទាប់ពីទទួលបានដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នពីសំណាក់ ចៅក្រមស៊ើបសួរមន្ត្រីនគរបាលយុត្តិធម៌ត្រូវដោះលែងជនត្រូវចោទដែលត្រូវបានឃាត់ខ្លួនភ្លាម។

### ១.៦. បណ្តឹងចំពោះដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

#### ក. ភាគីដែលអាចធ្វើបណ្តឹងឧទ្ធរណ៍

បន្ទាប់ពីចៅក្រមស៊ើបសួរ សម្រេចមិនធ្វើការឃុំខ្លួនជនត្រូវចោទ តាមរយៈដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាក្នុងនាមខ្លួនជាម្ចាស់នៃបណ្តឹងអាជ្ញា ឬអគ្គព្រះរាជអាជ្ញា អាចធ្វើពាក្យប្តឹងសភាស៊ើបសួរ ដើម្បីសម្រេចលើវិធាននៃការឃុំខ្លួន ឬមិនឃុំខ្លួន [21]។ ពោលគឺ អ្នកដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះដីកាខាងលើរួមមាន ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ យ៉ាងណាមិញ ស្របតាមស្មារតីនៃមាត្រា ២៦៨ នៃក្រមនីតិវិធី ព្រហ្មទណ្ឌដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំង ទៅនឹងដីកានេះបានទេ។

#### ខ. រយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍

ចំពោះបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជាអមសាលាឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល ១ (មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។ រីឯបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ [22]។

សូមបញ្ជាក់ផងដែរថា ការធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ធ្វើឡើងចាប់ពីថ្ងៃប្រកាសដីកា គឺមានន័យថាអគ្គព្រះរាជអាជ្ញា អាចធ្វើបណ្តឹងឧទ្ធរណ៍ចាប់ពីថ្ងៃដែលចៅក្រមស៊ើបសួរចេញដីកា រហូតដល់អំឡុងពេល ១(មួយ)ខែ។ ចំណែកឯ ការធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើឡើងចាប់ពីថ្ងៃជូនដំណឹង គឺមានន័យថា ព្រះរាជអាជ្ញាអាចធ្វើបណ្តឹងចាប់ពីថ្ងៃដែលខ្លួនបានទទួលដំណឹងអំពីដីកានេះ ពោល គឺមិនត្រូវបានចាប់រាប់ពីថ្ងៃការចេញដីកា (ប្រកាសដីកា) នោះទេ។

#### គ.សេចក្តីសម្រេចរបស់សភាស៊ើបសួរ

[21] មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[22] មាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

បន្ទាប់ពីទទួលបានសំណុំរឿងដោយមានភ្ជាប់ជាមួយនូវសេចក្ដីតវ៉ារបស់ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា នៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ សភាស៊ើបសួរត្រូវសម្រេចអំពីករណី នៃបណ្ដឹងខាងលើក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ។ ប្រសិនបើ សភាស៊ើបសួរយល់ស្របលើសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ សភាស៊ើបសួរត្រូវចេញ សាលដីកាទទួលយកការសម្រេចរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែ ប្រសិនសភាស៊ើបសួរយល់ថា ការសម្រេចក្ដីរបស់ចៅក្រមស៊ើបសួរពុំត្រឹមត្រូវ សភាស៊ើបសួរចេញសាលាដីកា ប្រានចោលការសម្រេចរបស់ចៅក្រមស៊ើបសួរ ហើយប្រធានសភាស៊ើបសួរ ត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួនទៅលើជនត្រូវចោទ ជំនួសឱ្យចៅក្រមស៊ើបសួរ។ តែក្នុងករណីដែលជនត្រូវនៅក្រៅឃុំ សភាស៊ើបសួរត្រូវចេញ ដីកាបង្គាប់ឱ្យចាប់ខ្លួនជាមុនសិន។

## កថាខណ្ឌ២៖ ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

### ២.១. អត្ថន័យនៃដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានការនៃសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ជំនួសឱ្យការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងកម្មវត្ថុរឹតបន្តឹងនូវ សេរីភាពទៅលើជនត្រូវចោទ ដែលត្រូវចោទដែលត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។

### ២.២. លក្ខខណ្ឌនៃការចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្ដើមផ្ទាល់របស់ខ្លួន ឬតាមសេចក្ដីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) នៅក្នុងសម្រេចរបស់ខ្លួន ចៅក្រមស៊ើបសួរ ត្រូវបញ្ជាក់អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ [23]។

ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ [24]។ នេះអាចបញ្ជាក់បានប្រសិនបើជនត្រូវចោទដែលជាកម្មវត្ថុនៃបណ្ដឹងអាជ្ញាមិនត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដែលត្រូវកំណត់ ផ្ដន្ទាទោសដាក់ពន្ធនាគារនោះទេ ចៅក្រមស៊ើបសួរមិនអាចជ្រើសរើសយកវិធានការនៃការដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាននោះទេ។ ពោលគឺចំពោះបទល្មើសលហុ ចៅក្រមស៊ើបសួរមិន

[23] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[24] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

អាចយកយន្តការនៃការដាក់ឱ្យស្ថិតនៅក្រោមកា រពិនិត្យតាមផ្លូវតុលាការនេះទៅអនុវត្តលើបុគ្គលត្រូវចោទឡើយ ករណីមួយផ្សេងៗទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានអនុញ្ញាតឱ្យចៅក្រមស៊ើបសួរយកវិធានការណ៍ខាងលើនេះ មកអនុវត្តចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នោះទេ [25]។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌក៏ពុំបាន ដាក់ជារបាំងក្នុងហាមឃាត់ដល់ចៅក្រមស៊ើបសួរ ដើម្បីយកវិធានការនេះទៅអនុវត្តលើអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ទៅក្រោម១៨ (ដប់ប្រាំបី)ឆ្នាំនោះដែរ។ ហេតុនេះអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ទៅក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ និងដោយរាប់បញ្ចូនទាំងនីតិជនផង ចៅក្រមស៊ើបសួរអាចសម្រេចយកវិធានការនេះទៅ អនុវត្តលើជនទាំងនោះបាន ពោលគឺ ច្បាប់មិនបានហាមឃាត់នោះទេ។

### ២.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

នៅក្នុងដីកានេះត្រូវតែមានចុះនិទ្ទេសឱ្យបានច្បាស់លាស់ និងបញ្ជាក់អំពីកាតព្វកិច្ចជាចាំបាច់ដែលត្រូវឱ្យជនត្រូវចោទយកទៅប្រតិបត្តិ។

- **ដីកានេះមានចុះនិទ្ទេសសំខាន់ៗដូចតទៅៈ**
    - ឈ្មោះចៅក្រមស៊ើបសួរ
    - ឈ្មោះក្រឡាបញ្ជី
    - លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
    - លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន
    - អត្តសញ្ញាណរបស់ជនត្រូវចោទ
    - សំអាងហេតុ [26]

**ប្រភេទនៃបទល្មើស ដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្កបទល្មើសៈ**

-ផ្នែកនៃសេចក្តីសម្រេចរបស់ដីកា ត្រូវមានបញ្ជាក់ឱ្យបានច្បាស់លាស់នូវកាតព្វកិច្ចដែលតម្រូវឱ្យជនត្រូវចោទអនុវត្ត។

- ដីកានេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាសម្រេចដាក់ជនត្រូវចោទ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

---

[25] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[26] ក្នុងសំអាងហេតុចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីហេតុផលដែលខ្លួនសម្រេចយកវិធានការនៃជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយឈរលើមូលដ្ឋានច្បាប់ និងហេតុផលផលមួយចំនួនដែលខ្លួនយល់ឃើញ។

- ត្រូវមានបញ្ជាក់អំពីចំណាត់ការបន្តលើការឃុំខ្លួនជនត្រូវចោទ ប្រសិនបើជនត្រូវចោទបានគេចវេះ មិនគោរពកាតព្វកិច្ចដែលត្រូវបានកំណត់ក្នុងផ្នែកសេចក្តីសម្រេចនៃដីកា។

ដីកានេះត្រូវមានចុះកាលបរិច្ឆេទចុះហត្ថលេខាដោយចៅក្រមស៊ើបសួររួមទាំងក្រឡាបញ្ជី និងមានបោះត្រាផង ។

ការមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់នៃនិទ្ទេសខាងលើ អាចនាំឱ្យដីកានេះពុំមានអានុភាព ឬ គ្មានតម្លៃជាកម្មវត្ថុសម្រាប់យកទៅអនុវត្តបានឡើយ។

### ២.៤. នីតិវិធីនៃការអនុវត្តដីកាសម្រេចដាក់ត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ជាធម្មតានៅពេលជនត្រូវចោទត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ធ្វើការបញ្ជូនខ្លួនមកចំពោះខ្លួន ចៅក្រមស៊ើបសួរ ហើយបន្ទាប់ពីត្រូវបានចៅក្រមស៊ើបសួរធ្វើនីតិវិធីនៃការសួរយកចម្លើយ ឬស្តាប់ចម្លើយរួចរាល់ហើយ ចៅក្រមស៊ើបសួរ អាចសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ឬ សម្រេចមិនធ្វើការឃុំខ្លួនជនត្រូវចោទ។ ក្នុងករណីមិនឃុំខ្លួនជនត្រូវចោទចៅក្រមស៊ើបសួរ ត្រូវសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការដែលជាវិធានការជំនួសឱ្យការឃុំបណ្តោះអាសន្ន។

កាលណាចៅក្រមស៊ើបសួរ ចេញដីកាសម្រេចដាក់សម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមស៊ើបសួរ បានទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាសុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅ ក្រោមការត្រួតតាមផ្លូវតុលាការ តែខ្លួនបដិសេធមិនព្រមសម្រេចតាមការសុំទេ គាត់ត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ។ ដីកាសម្រេច នេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរ មិនសម្រេចក្នុងរយៈពេល ៥ថ្ងៃ ទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ [27]។

នៅពេលចេញដីកានេះ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យជនត្រូវចោទដាក់ប្រាក់ធានា ហើយត្រូវបង្គាប់ឱ្យជនត្រូវចោទដាក់តម្កល់នូវសំណុំឯកសារមួយចំនួន (អត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ កាតបំរើការងារ....) ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ និងក៏ដូចជាត្រូវដកហូតរក្សាទុកសម្ភារៈ មួយចំនួន (អាវុធ) ផងដែរ។ ក្រឡាបញ្ជី ត្រូវសរសេរបង្កាន់ដៃទទួលសំណុំឯកសារទាំងនោះ ដែលត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ។ ចំពោះបង្កាន់ដៃប្រគល់ប្រាក់ធានា ឬ អាវុធ ត្រូវចុះហត្ថលេខា រួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ប្រាក់ធានា ត្រូវតម្កល់ទុកនៅគណនីពិសេសដែលបើកនៅធនាគារ ឬ ត្រូវរក្សាទុកនៅទីកន្លែងមួយ

[27] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ដែលមានការធានាសន្តិសុខរឹងមាំ។ ទីកន្លែងនេះ ត្រូវជ្រើសរើសតាមការឯកភាពគ្នាដោយប្រធានតុលាការ និង ព្រះរាជអាជ្ញា។ អាវុធ ត្រូវរក្សាទុកនៅទីកន្លែងដូចពោលខាងលើ [28]។

ក្នុងករណីជនត្រូវចោទគេចវេះពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរ អាច សម្រេចធ្វើការកែប្រែវិធានការខាងលើ មកជំនួសដោយវិធានការនៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នវិញ។

កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្ន ដោយមូលហេតុខាងលើនេះ ចៅក្រម ស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ ប្រសិនបើជនត្រូវចោទ មាន មេធាវីអម នោះមេធាវី ត្រូវជូនមធ្យោបាយការពារកូនក្ដីរបស់ខ្លួន។ ចៅក្រមស៊ើបសួរ សម្រេចការឃុំខ្លួន ជនត្រូវ ចោទតាមដីកា ដែលមានសំអាងហេតុ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ [29]។

ការសម្រេចរបស់ចៅក្រមស៊ើបសួរ គាត់អាចសម្រេចកែប្រែខ្លឹមសារនៃកាតព្វកិច្ចអាចលុបចោល ឬ បញ្ចូលកាតព្វកិច្ចថ្មី បានគ្រប់ពេលវេលា។ ជាងនេះទៅទៀតចៅក្រមស៊ើបសួរ ក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវ តុលាការបានផងដែរ ប្រសិនខ្លួនយល់ឃើញថាជាការគួរ។

### ២.៥. អានុភាពនៃដីកាសម្រេចដាក់ ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ

ដីកានេះមានអានុភាពក្នុងការរឹតត្បិតនូវសេរីភាពមួយចំនួនរបស់ជនត្រូវចោទ។

**ការត្រួតពិនិត្យតាមផ្លូវតុលាការ (ដីកា) មានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរព កាតព្វកិច្ចមួយឬ ច្រើនដូចតទៅ [30]៖**

១. មិនត្រូវចេញពីក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២. មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣. មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤. ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែល ចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦. ប្រគល់ជូនការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧. មិនត្រូវបើកបររថយន្ត។

[28] មាត្រា ២២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[29] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧

[30] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

៨. មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០. មិនត្រូវកាន់កាប់ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១.ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និង ជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបស់ព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ប៉ុន្តែក្នុងលក្ខខណ្ឌនៃការអនុវត្តចំពោះចំណុចទី១២ ខាងលើចៅក្រមស៊ើបសួរ មិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងលើសហជីពបានទេ។

មួយវិញទៀត ប្រសិនបើជនត្រូវចោទ គេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រម ស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារ ដែលត្រូវរងនោះមានចិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវឃុំខ្លួនបណ្ដោះអាសន្ន អស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨ មាត្រា ២១៣ និងមាត្រា ២១៤ នៃក្រមនេះក៏ដោយ។ ប៉ុន្តែរយៈពេលនៃការឃុំខ្លួនក្នុងករណីនេះ មិនអាចឱ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន [31]។

### ២.៦. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចជ្រើសយកវិធាននៃដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមរយៈដីកាសម្រេចដីកានេះ នឹងអាចក្លាយជាកម្មវត្ថុនៃការកធ្វើបណ្ដឹង ប្រសិនភាគីដែលពាក់ពន្ធ័ (អគ្គព្រះព្រះរាជអាជ្ញា ព្រះរាជអាជ្ញា ឬជនត្រូវចោទ) មិនសុខចិត្ត ទៅនឹងការសម្រេចនោះ។

#### ក. ភាគីនៃបណ្ដឹងឧទ្ធរណ៍

**ជាទូទៅភាគីដែលធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកានេះមានជាអាទិ៍ ៖**

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (មាត្រា ២៦៦)
- ព្រះរាជអាជ្ញា (មាត្រា ២២៨)
- ជនត្រូវចោទ (មាត្រា ២២៩)
- មេធាវីរបស់ជនត្រូវចោទ

[31] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

គួរកត់សម្គាល់ ផងដែរថាស្របតាមស្មារតីមាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងឃើញថាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅដីកានេះបានទេ។ អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាក្តី ទោះបីជាខ្លួនជាអ្នកដែលបានធ្វើការប្រកាន់ទៅលើជនត្រូវចោទ ក្នុងគោលដៅដើម្បីទាមទារ ឱ្យមានចំណាត់ការទណ្ឌកម្ម ទៅលើជននោះក៏ពិតមែន ប៉ុន្តែខ្លួនក៏អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាខាងលើបានផងដែរ ប្រសិនបើខ្លួនយល់ឃើញថាវិធានការទណ្ឌកម្មជាកាតព្វកិច្ច ដែលត្រូវបានដាក់ឱ្យអនុវត្តទៅលើ ជនត្រូវចោទនេះមានលក្ខណៈ ធ្ងន់ធ្ងរហួសហេតុ មិនសមស្របតាមលក្ខណៈណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពធ្ងន់ធ្ងរ។

ដូចគ្នានេះដែរ ជនត្រូវចោទដែលជាកម្មវត្ថុនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការផ្ទាល់ ក៏អាចធ្វើការប្តឹងទៅសភាស៊ើបសួរសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនេះបានគ្រប់ពេលប្រសិនបើចៅក្រមស៊ើបសួរ បដិសេធលើសំណើសុំរបស់ខ្លួន។

### ខ. រយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់នូវបុព្វសិទ្ធិដូចគ្នា ទៅដល់បុគ្គលមួយចំនួន ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាខាងលើក៏ពិតមែន។ ប៉ុន្តែការកំណត់ថិរវេលា នៃការធ្វើបណ្តឹងមានភាពខុសប្លែកគ្នាទៅតាមស្ថានភាពនៃបុគ្គលដែលធ្វើបណ្តឹង។

អនុលោមតាមមាត្រា ២៧០ អំពីការកំណត់លើវិធានថិរវេលា នៃការធ្វើបណ្តឹងឧទ្ធរណ៍បានកំណត់ដូចតទៅ៖

-បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល ១(មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។

- បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ០៥ (ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ ប្រសិនសបើការជូនដំណឹងធ្វើឡើងដោយការប្រគល់ សេចក្តីចម្លងនៃដីកា ដោយមានចំណារទទួលនោះ រយៈពេលបណ្តឹងឧទ្ធរណ៍ ផ្តើមគិតចាប់ពីកាលបរិច្ឆេទ នៃចំណារទទួលនោះ។ នេះជាលក្ខខណ្ឌដាច់ខាតនៃថិរវេលាក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំង ទៅនឹងដីកាខាងលើ ការខកខាន មិនបានធ្វើបណ្តឹងក្នុងកំឡុង ពេលនេះ នឹងនាំឱ្យបានបង់នូវសិទ្ធិនៃការប្តឹង។

### គ. ការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ដោយសភាស៊ើបសួរ

ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ ថិរវេលាជាក់លាក់ណាមួយ ក្នុងការសម្រេចលើបណ្តឹង ឧទ្ធរណ៍ប្រឆាំង ទៅនឹងដីកាខាងលើដល់សភាស៊ើបសួរនោះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី សភាស៊ើបសួរត្រូវមានចំណាត់ការក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួនឱ្យបានឆាប់រហ័សបំផុត តាមការធ្វើទៅបានបន្ទាប់ពីខ្លួនទទួលបណ្តឹង (សំណុំរឿង) ។

ជាកិច្ចនៃការសម្រេចរបស់សភាស៊ើបសួរ ប្រសិនបើខ្លួនយល់ឃើញថា បណ្តឹងដែលបានប្តឹង មកនេះមានហេតុផលត្រឹមត្រូវអាចទទួលយកបានសភាស៊ើបសួរ សម្រេចទៅតាមពាក្យសុំនោះទាំងស្រុង ឬច្រានចោលនូវផ្នែកណាមួយដែលខ្លួនយល់ឃើញថា មិនអាចទទួលយកបាន។ ផ្ទុយទៅវិញប្រសិនបើសភាស៊ើបសួរ យល់ស្របទៅនឹងសេចក្តីសម្រេច (កាតព្វកិច្ចដែលមានកំណត់ក្នុងដីកា) របស់ចៅក្រមស៊ើបសួរ សភាស៊ើបសួរសម្រេចតម្កល់ពាក្យបណ្តឹងនោះ ហើយត្រូវជូនដំណឹងដល់ភាគីអ្នកប្តឹង។ រាល់ការសម្រេចរបស់សភាស៊ើបសួរត្រូវធ្វើឡើងតាមរយៈសាលដីកា។

### កថាខណ្ឌទី៣៖ ដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ

#### ៣.១. អត្ថន័យនៃដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ

ដីកាសម្រេចកែប្រែ ឬ បញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានការនៃសេចក្តី សម្រេចរបស់ចៅក្រមស៊ើបសួរ ក្នុងកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីចៅក្រមស៊ើបសួរស្វែងរក ក្នុងកម្មវត្ថុរឹតបន្តឹងឬផ្តល់ សេរីភាពទៅលើជនត្រូវចោទ ។ ជាពិសេសចៅក្រម ស៊ើបសួរសម្រេចតាមដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទផងដែរ [32]។

#### ៣.២. លក្ខខណ្ឌនៃដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ

**បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយតុលាការដោយព្រះរាជអាជ្ញា**

ដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ អាចធ្វើឡើងតាមបណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា អាចសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ប៉ុន្តែចៅក្រមស៊ើបសួរ មានសិទ្ធិក្នុងការសម្រេចចិត្តក្នុងរយៈពេល ៥ (ប្រាំថ្ងៃ)។ ដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ នេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំ ដើម្បីបញ្ជូនទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកានេះសម្រេចមិនព្រមធ្វើតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ [33]។

**បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយតុលាការដោយជនត្រូវចោទ**

[32] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[33] មាត្រា២២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែងឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា តែចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់និងជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ក្នុងករណីនេះចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

### ៣.៣. និទ្ទេសដែលចុះក្នុងដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- សំអាងហេតុ

### ៣.៤. អានុភាពនៃការដីកាសម្រេចកែប្រែ ឬបញ្ចូលកាតព្វកិច្ចថ្មីការត្រួតពិនិត្យតាមផ្លូវតុលាការ

ដីកានេះចៅក្រមស៊ើបសួរអាចកែខ្លឹមសារនៃកាតព្វកិច្ច មានអានុភាពក្នុងការរឹតត្បិតនូវសេរីភាពមួយចំនួនរបស់ជនត្រូវចោទ។

**ការត្រួតពិនិត្យតាមផ្លូវតុលាការ( ដីកា )មានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយឬ ច្រើនដូចតទៅះ**

១. មិនត្រូវចេញពីក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២. មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦.ប្រគល់ជូនការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧.មិនត្រូវបើកបររថយន្ត។

៨.មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០.មិនត្រូវកាន់កាប់ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១.ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ប៉ុន្តែក្នុងលក្ខខណ្ឌនៃការអនុវត្តចំពោះចំណុចទី១២ ខាងលើចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការ អនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងលើសហជីពបានទេ។

មួយវិញទៀត ប្រសិនបើជនត្រូវចោទគេចវេសដោយចេតនាពី កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រម ស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានចិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវ ឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨ មាត្រា២១៣ និងមាត្រា២១៤ នៃក្រមនេះក៏ដោយ។ ប៉ុន្តែរយៈពេលនៃការឃុំខ្លួនក្នុង ករណីនេះមិនអាចឱ្យលើសពី ៤(បួន) ខែ ចំពោះនីតិជន និង ២ (ពីរ)ខែ ចំពោះអនីតិជន។

## ផ្នែកទី៣៖ ការចេញដីកាក្នុងករណីដោះលែងឱ្យនៅក្រៅឃុំ

### កថាខណ្ឌ១៖ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ

#### ១.១. និយមន័យនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន គឺជាចំណាត់មួយក្នុងនីតិវិធីដែលចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការសម្រេចក្នុងការឱ្យក្រៅឃុំបណ្តោះអាសន្ន ឬនៅក្នុងឃុំបណ្តោះអាសន្ន។ ប៉ុន្តែក្នុងករណីដែលបុគ្គលនោះបានបង្ការជាបទល្មើសព្រហ្មទណ្ឌ ដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមនោះ អាជ្ញាធរតុលាការអាចធ្វើសម្រេចអំពីការឃុំខ្លួនបានប៉ុណ្ណោះអាសន្នបាន។ ដោយឡែកនៅក្នុងចំណាត់ការនេះដោយយោងតាមគោលការណ៍នៃសិទ្ធិសេរីភាពរបស់មនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលបុគ្គលគ្រប់រូបមានសេរីភាពពេញលេញក្នុងការដើរហើរគ្រប់ទីកន្លែងបាន ក៏ដូចជាការពិនិត្យទៅគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានបើកសិទ្ធិឱ្យភាគី (ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ) មានសិទ្ធិឱ្យជនដែលបានប្រព្រឹត្តបទល្មើសនោះនៅក្រៅឃុំបណ្តោះអាសន្នបាន [34]។

[34] មាត្រា២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

### ១.២. លក្ខខណ្ឌនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

នៅក្នុងការចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នអ្នកស្នើសុំ ឬការសម្រេចអំពីករណីនេះត្រូវគោរពតាមលក្ខខណ្ឌដែលបានកំណត់ដូចខាងក្រោមនេះ ៖

- ❖ ជនត្រូវចោទបានសន្យាថាខ្លួននឹងបញ្ឈប់បទល្មើស ឬ ខ្លួនមិនទៅប្រព្រឹត្តបទល្មើសមិនឱ្យកើតឡើងជាថ្មីឡើយ។
- ❖ ជនត្រូវចោទសន្យាខ្លួននឹងមិនទៅជួប ឬ ទៅរារាំង ឬ ទៅគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ទៅជួបជនត្រូវចោទផ្សេងទៀត នាំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ❖ ជនត្រូវចោទសន្យាថា នឹងមិនទៅទីតាំងដែលជាទីកន្លែងខ្លួនប្រព្រឹត្តបទល្មើស ឬ ទៅដើម្បីបំផ្លាញចោលភស្តុតាងដែលបង្ហាញខ្លួនជាគ្មានពិរុទ្ធភាព។
- ❖ ជនត្រូវចោទបានសន្យាថា នឹងគោរពតាមការចំណាត់ការនីតិវិធីរបស់តុលាការ និងមកតាមការកោះហៅរបស់តុលាការគ្រប់ពេលវេលាទាំងអស់។
- ❖ ជនត្រូវចោទ ប្រាកដខ្លួនគ្មាននរណាតាមសម្លាប់ ឬតាមគំរាមកំហែងណាមួយពីដំណាក់ភាគីដែលកំពុងតាមស៊ើបពីសំណាក់តុលាការឡើយ។
- ❖ ជនត្រូវចោទបានសន្យាថាខ្លួន នឹងមិនទៅបង្ករគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងមិនឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើសរបស់ខ្លួនតទៅទៀតឡើយ។
- ❖ ការសម្រេចរបស់ចៅក្រមស៊ើបសួរ ត្រូវតែមានមូលហេតុក្នុងដីកាសម្រេចដោះលែងឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន។

### ១.៣. និទ្ទេសនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នមានចុះនិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅៈ

-ឈ្មោះ ចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ដីកានេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅ ចុះលេខដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន។ ដីកាសម្រេចដោះលែងឱ្យ នៅក្រៅឃុំបណ្ដោះអាសន្នត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ រួមទាំងក្រឡាបញ្ជីនិងមានបោះត្រាផង។

## ១.៤. នីតិវិធីនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំគ្រប់ពេលវេលា។ ហើយការដោះលែងក៏អាចធ្វើឡើង តាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ឬបណ្ដឹងសុំរបស់ជនត្រូវចោទផងដែរ។

### ក. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយឆន្ទានុសិទ្ធិ

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ដោយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យហើយ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនលើសពី ៥ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿងមកពិនិត្យ) ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីនេះព្រះរាជអាជ្ញាមិនបានផ្ដល់យោបល់ក្នុងអំឡុងពេល ៥ ថ្ងៃ ហើយចៅក្រមស៊ើបសួរ សម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ននោះ។ តាមដីកាសម្រេចរបស់ព្រះរាជអាជ្ញាមានសិទ្ធិប្ដឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសបាន។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាមដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន[35]។

### ខ. ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុង រយៈពេល ៥ ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ដីកាសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។

ករណីនេះខុសពីករណីដែលមានកំណត់ខាងលើ ដោយសារក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរត្រូវសម្រេចមានមូលហេតុផ្ទាល់ខ្លួនដោយការសម្រេចនេះ គឺធ្វើឡើងក្នុងនាមជាចៅក្រម ឯករាជ្យដូច្នេះមិនចាំបាច់គោរពតាមយោបល់របស់ព្រះរាជអាជ្ញានោះទេ តែព្រះរាជាជ្ញាមានសិទ្ធិដូចគ្នា ដោយកំណត់រយៈពេលឱ្យការសម្រេចរបស់ព្រះរាជអាជ្ញាធ្វើប្ដឹងបាន។ ប៉ុន្តែសម្រាប់ការ មិនសម្រេចដោះលែងឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញាត្រូវមានសំអាងនេះ ដោយករណីនេះចៅក្រមស៊ើបសួរ មានករណីយកិច្ចមិនយល់ស្របជាមួយព្រះ

[35] មាត្រា២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

រាជអាជ្ញា ដូច្នេះច្បាប់ មិនបានឱ្យចៅក្រមស៊ើបសួរធ្វើឆ្លើយដោយផ្ទាល់ជាមួយព្រះរាជអាជ្ញានោះទេ ហេតុការសម្រេចដោយមានសំអាងហេតុ គឺជាសមហេតុផល [36]។

### គ. ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះអាជ្ញា។

ជនត្រូវចោទអាចដាក់ពាក្យបណ្តឹងសុំនៅក្រៅឃុំសារជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬ ទៅសភាស៊ើបសួរក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ មានន័យថាការស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទ អាចស្នើសុំម្តងហើយម្តងទៀត ប៉ុន្តែមានរយៈពេលកំណត់ត្រឹម ១ខែ/ម្តង។

កាលណាចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេ ជនត្រូវចោទ អាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ មានន័យថា ចៅក្រមស៊ើបសួរ ត្រូវតែសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹងរបស់ជនត្រូវចោទ ដូច្នេះក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមសម្រេច ឬ មិនឆ្លើយតបទៅលើពាក្យសុំនេះ ជនត្រូវចោទមានសិទ្ធិធ្វើពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ននេះទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដើម្បីសម្រេចជំនួសពាក្យសុំលើករណីឃុំខ្លួនបណ្តោះអាសន្ននេះ។ ហើយពាក្យសុំប្តឹងនេះ កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ (ស្តីពីការមិនសម្រេចរបស់ចៅក្រមស៊ើបសួរ) ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង ដោយត្រូវចុះនិទ្ទេសដោយក្រឡាបញ្ជីទទួលបណ្តឹងនោះ។ ហើយក្រោយពីបញ្ជូនទៅដល់ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរហើយ សភាស៊ើបសួរត្រូវតែឆាប់បើកសវនាការដើម្បីសម្រេច (ករណីពាក្យសុំនៅក្រៅឃុំ) ឱ្យបានឆាប់រហ័សបំផុត (១៥ ថ្ងៃ) យ៉ាងយូរបំផុត [37]។

[36] មាត្រា២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[37] មាត្រា២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

**១.៥. អានុភាពនៃដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន**

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមនេះ អាចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។

**កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន**

**២.១.អត្ថន័យនៃដីកាបង្គាប់ដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន**

ដីកាបង្គាប់ដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន គឺជាចំណាត់ការមួយក្នុងនីតិវិធីដែលចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការបង្គាប់ក្នុងការឱ្យជនត្រូវចោទនៅ ក្រៅឃុំបណ្ដោះអាសន្ន ។

**២.២. លក្ខខណ្ឌនៃដីកាបង្គាប់ដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន**

នៅក្នុងការចេញដីកាបង្គាប់ដោះលែងឱ្យ នៅក្រៅឃុំបណ្ដោះអាសន្នហើយមានសេរីភាព អ្នកស្នើសុំ ឬ ការសម្រេចអំពីករណីនេះត្រូវគោរពតាមលក្ខខណ្ឌ ដែលបានកំណត់ដូចខាងក្រោមនេះ ៖

- ជនត្រូវចោទបានសន្យាថាខ្លួននឹងបញ្ឈប់បទល្មើស ឬ ខ្លួនមិនទៅប្រព្រឹត្តបទល្មើសមិនឱ្យកើតឡើងជាថ្មីឡើយ។
- ជនត្រូវចោទសន្យាខ្លួននឹងមិនទៅជួប ឬ ទៅរារាំង ឬ ទៅគាប់សង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ទៅជួបជនត្រូវចោទផ្សេងទៀត នាំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ជនត្រូវចោទសន្យាថា នឹងមិនទៅទីតាំងដែលជាទីកន្លែងខ្លួនប្រព្រឹត្តបទល្មើស ឬ ទៅដើម្បីបំផ្លាញចោលភស្តុតាងដែលបង្ហាញខ្លួនជាគ្មានពិរុទ្ធភាព។
- ជនត្រូវចោទបានសន្យាថា នឹងគោរពតាមការចំណាត់ការនីតិវិធីរបស់តុលាការ និងមកតាមការកោះហៅរបស់តុលាការគ្រប់ពេលវេលាទាំងអស់។
- ជនត្រូវចោទ ប្រាកដខ្លួនគ្មាននរណាតាមសម្លាប់ ឬតាមគំរាមកំហែងណាមួយពីដំណាក់ភាគីដែលកំពុងតាមស៊ើបពីសំណាក់តុលាការឡើយ។
- ជនត្រូវចោទបានសន្យាថាខ្លួន នឹងមិនទៅបង្ករគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងមិនឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើសរបស់ខ្លួនតទៅទៀតឡើយ។
- ការសម្រេចរបស់ចៅក្រមស៊ើបសួរ ត្រូវតែមានមូលហេតុក្នុងដីកាសម្រេចដោះលែងឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន។

**២.៣. នីតិវិធីនៃដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន**

ដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួននិង ត្រូវបំពេញបែបបទនៃនីតិវិធិរដ្ឋបាលទៅតាមសាលាជម្រះក្តី [38]។

**២.៤. អានុភាពនៃដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន**

ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញា អំពីដីកោះដោះលែងឱ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់នោះជនត្រូវចោទដែលជាប់ឃុំ ឬលើកលែងចោទប្រកាន់នោះជនត្រូវដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍។ សភាស៊ើបសួរត្រូវសម្រេចចេញនៅក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃបន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បើផុតរយៈពេលនោះជនត្រូវចោទត្រូវបានដោះលែង ឱ្យនៅក្រៅឃុំលើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ឬក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬមិនអាចជំនះបាននោះបង្កជាឧបសគ្គមិនឲ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនោះ។ កាលណាសភាស៊ើបសួរ បង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន សភាស៊ើបសួរត្រូវសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួនដោយយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន)នៃក្រមនេះ។ ប្រធានសភាស៊ើបសួរចេញដីកាបង្គាប់ឱ្យបណ្ដោះឃុំខ្លួន។

សំណុំរឿងត្រូវបង្វិលជាបន្ទាន់ទៅចៅក្រមស៊ើបសួរវិញ ក្រោយពីបានអនុវត្តសាលដីការួច [39]។

## ផ្នែកទី៤៖ ការចេញដីកាក្នុងករណីមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

### កថាខណ្ឌ៣៖ ការចេញដីកាក្នុងករណីមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

**១.១.អត្ថន័យនៃការចេញដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន**

ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន គឺជាសេចក្ដីសម្រេចដែលចៅក្រមស៊ើបសួរមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ជនត្រូវចោទទៅតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ដោយចៅក្រមស៊ើបសួរយល់ឃើញថាមិនមានហេតុផលចាំបាច់ក្នុងការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន។

**១.២. លក្ខខណ្ឌនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន**

នៅក្នុងការចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នអ្នកស្នើសុំ ឬការសម្រេចអំពីករណីនេះត្រូវគោរពតាមលក្ខខណ្ឌដែលបានកំណត់ដូចខាងក្រោមនេះ ៖

- ជនត្រូវចោទមិនបានសន្យាថា ខ្លួននឹងបញ្ចប់បទល្មើស

[38] មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[39] មាត្រា២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

- ជនត្រូវចោទមិនបានសន្យា និងមិនគោរព រារាំងសាក្សី ឬ ជនរងគ្រោះ ឬ ទៅជួបជនត្រូវចោទផ្សេងទៀត ដែល មានទំនាក់ទំនងជាមួយគ្នា ។
- ជនត្រូវចោទមិនបានសន្យាថា នឹងមិនទៅទីតាំងដែលជាទីកន្លែងខ្លួនប្រព្រឹត្តបទល្មើស ឬ ទៅដើម្បី បំផ្លាញចោលភស្តុតាងដែលបង្ហាញខ្លួនពិរុទ្ធភាព។
- ជនត្រូវចោទមិនបានសន្យាថា គោរពតាមការចំណាត់ការនីតិវិធីរបស់តុលាការ និងមកតាមការកោះ ហៅរបស់តុលាការគ្រប់ពេលវេលាទាំងអស់។
- ជនត្រូវចោទមិនប្រាកដខ្លួនគ្មាននរណាតាមសម្លាប់ ឬតាមគំរាមកំហែងណាមួយពីសំណាក់ភាគីដែល កំពុងតាមស៊ើបពីសំណាក់តុលាការឡើយ។
- ជនត្រូវចោទមិនបានសន្យាថាខ្លួន មិនទៅបង្ករគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ និងមិនឱ្យមាន ការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើសរបស់ខ្លួនតទៅទៀតឡើយ។
- ការសម្រេចរបស់ចៅក្រមស៊ើបសួរ ត្រូវតែមានមូលហេតុក្នុងដីកាសម្រេចដោះលែងឱ្យជនត្រូវចោទនៅ ក្រៅឃុំបណ្តោះអាសន្ន។

### ១.៣.និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចមិនព្រមដោះលែងឱ្យក្រៅឃុំបណ្តោះអាសន្ន

ដីកាសម្រេចមិនព្រមដោះលែងឱ្យក្រៅឃុំបណ្តោះអាសន្ន មានចុះនិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅ៖

-ឈ្មោះ ចៅក្រមស៊ើបសួរ

-ឈ្មោះ ក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ដីកានេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅ ចុះ លេខដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន។

ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខា ដោយចៅក្រមស៊ើបសួររួមទាំងក្រឡាបញ្ជីនិងមានបោះត្រាផង។

### ១.៤.នីតិវិធីនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន

ចៅក្រមស៊ើបសួរមានសិទ្ធិ សម្រេចឱ្យជនត្រូវស្ថិតនៅក្រៅឃុំ ឬនៅក្រៅឃុំតាមឆន្ទានុសិទ្ធិរបស់គាត់ ។ បើក្នុងករណីនេះចៅក្រមស៊ើបសួរសម្រេចមិនដោះលែងជនត្រូវឱ្យនៅក្រៅឃុំបណ្តោះ ត្រូវជូនដំណឹងដល់ ព្រះរាជអាជ្ញា និងជនត្រូវចោទ។

### ក. ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុង រយៈពេល ៥ ថ្ងៃការសម្រេចឱ្យជនត្រូវនោះ នៅក្រៅឃុំ ឬនៅក្នុងក្រៅ ។ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ លើដីកាការសម្រេចរបស់ចៅក្រមស៊ើបសួរ។ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ត្រូវមានសំអាងហេតុ។

ករណីនេះខុសពីករណីដែលមានកំណត់ខាងលើបន្តិច ដោយសារក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរត្រូវសម្រេចមានមូលហេតុផ្ទាល់ខ្លួនដោយការសម្រេចនេះ គឺធ្វើឡើង ក្នុងនាមជាចៅក្រម ឯករាជ្យដូច្នេះមិនចាំបាច់គោរពតាមយោបល់របស់ព្រះរាជអាជ្ញានោះទេ តែព្រះរាជាជ្ញាមានសិទ្ធិដូចគ្នា ដោយកំណត់រយៈពេលឱ្យការសម្រេចរបស់ព្រះរាជអាជ្ញាធ្វើប្តឹងបាន។ ប៉ុន្តែសម្រាប់ការមិនសម្រេចដោះលែងឱ្យនៅ ក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញាត្រូវមានសំអាងនេះ ដោយករណីនេះចៅក្រមស៊ើបសួរ មានករណីយកិច្ចមិនយល់ស្របជាមួយព្រះរាជអាជ្ញា ដូច្នេះច្បាប់មិនបានឱ្យចៅក្រមស៊ើបសួរធ្វើឆ្លើយដោយផ្ទាល់ជាមួយព្រះរាជអាជ្ញានោះទេ ហេតុការសម្រេចដោយមានសំអាងហេតុ គឺជាសមហេតុផល។

### ខ. ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះអាជ្ញា។

ជនត្រូវចោទអាចដាក់ពាក្យបណ្តឹងសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬ ទៅសភាស៊ើបសួរក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ មានន័យថាការស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទ អាចស្នើសុំម្តងហើយម្តងទៀត ប៉ុន្តែមានរយៈពេលកំណត់ត្រឹម ១ខែ/ម្តង។

កាលណាចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេ ជនត្រូវចោទ អាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ មានន័យថា ចៅក្រមស៊ើបសួរ ត្រូវតែសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹងរបស់ជនត្រូវចោទ ដូច្នេះក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមសម្រេច ឬ មិនឆ្លើយតបទៅលើពាក្យសុំនេះ ជនត្រូវចោទមានសិទ្ធិធ្វើពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ននេះទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដើម្បីសម្រេចជំនួសពាក្យសុំលើករណីឃុំខ្លួនបណ្តោះអាសន្ននេះ។ ហើយពាក្យសុំប្តឹងនេះ

កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ (ស្តីពីការមិនសម្រេចរបស់ចៅក្រមស៊ើបសួរ) ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងត្រូវជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមាន សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង ដោយត្រូវចុះ និទ្ទេសដោយក្រឡាបញ្ជីទទួលបណ្តឹងនោះ។ ហើយក្រោយពីបញ្ជូនទៅដល់ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរហើយ សភាស៊ើបសួរត្រូវតែឆាប់បើកសវនាការដើម្បីសម្រេច (ករណីពាក្យសុំនៅក្រៅឃុំ) ឱ្យបានឆាប់រហ័សបំផុត (១៥ ថ្ងៃ) យ៉ាងយូរបំផុត

### ១.៥. អានុភាពនៃដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន

ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះ ជាគោលការណ៍ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ជនត្រូវចោទ បានដាក់ពាក្យសុំ។ កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមនេះ អាចដាក់ជននោះ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។

#### ក. បណ្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន

ក្នុងករណីដែលព្រះរាជអាជ្ញាអ្នកស្នើសុំឱ្យជនត្រូវ ឱ្យនៅក្រៅឃុំ ប៉ុន្មានចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរលើដីកាការសម្រេចរបស់ចៅក្រមស៊ើបសួរ។ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ត្រូវមានសំអាងហេតុ។

បណ្តឹងរបស់ជនត្រូវចោទ ដូច្នេះក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមសម្រេច ឬ មិនឆ្លើយតបទៅលើពាក្យសុំនេះជនត្រូវចោទមានសិទ្ធិធ្វើពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ននេះ ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដើម្បីសម្រេចជំនួសពាក្យសុំលើករណីឃុំខ្លួបណ្តោះអាសន្ននេះ។ ហើយពាក្យសុំប្តឹងនេះ កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ (ស្តីពីការមិនសម្រេចរបស់ចៅក្រមស៊ើបសួរ) ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមាន សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង ដោយត្រូវចុះនិទ្ទេសដោយក្រឡាបញ្ជីទទួលបណ្តឹងនោះ។ ហើយក្រោយពីបញ្ជូនទៅដល់ការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរហើយ សភាស៊ើបសួរត្រូវតែឆាប់បើកសវនាការដើម្បីសម្រេច (ករណីពាក្យសុំនៅក្រៅឃុំ) ឱ្យបានឆាប់រហ័សបំផុត (១៥ ថ្ងៃ) យ៉ាងយូរបំផុត ។

# ផ្នែកទី៥៖ ការចេញដីកាក្នុងករណីមានសាវតាជាតិជនត្រូវចោទ

## កថាខណ្ឌ១៖ ដីកាបង្គាប់ឱ្យចូលខ្លួន

### ១.១. អត្ថន័យនៃដីកាបង្គាប់ឱ្យចូលខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។[40]

### ១.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួន

ស្ថិតនៅក្នុងចំណាត់ការនៃវិធាននិរន្តរាយ ដើម្បីឱ្យការស៊ើបសួរស្វែងរកពិតនៃរឿងប្រព្រឹត្តទៅបានដោយរលូន ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ទៅលើជនត្រូវចោទឬបុគ្គលណា ម្នាក់ដែលមានតម្រុយពិរុទ្ធភាព [41]។

ជាទូទៅការចេញដីកាបង្គាប់ឱ្យចូលខ្លួន គឺធ្វើឡើងនៅពេលដែលចៅក្រមស៊ើបសួរទទួលបាន សំណុំរឿងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីសំណាក់ព្រះរាជអាជ្ញា។ កម្មវត្ថុនៃការចេញដីកានេះ គឺដើម្បីបញ្ជាឱ្យ បុគ្គលត្រូវចោទ[42] ចូលមកបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសាកសួរព័ត៌មាន សួរយកចម្លើយអំពីរឿងហេតុពាក់ពន្ធ័ និងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។

ដោយឡែកដីកានេះ និងមិនត្រូវចេញភ្លាមដោយចៅក្រមស៊ើបសួរទៅលើបុគ្គលត្រូវចោទ ឡើយបើទោះបីជាមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាក៏ដោយ។ នេះដោយហេតុថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា បានធ្វើសេចក្តីសន្និដ្ឋានចោទ ប្រកាន់ទៅលើបុគ្គលដែលគ្មានសាវតាជាតិគ្រប់គ្រាន់ ឬ ជាបុគ្គលដែលមិនស្គាល់អត្តសញ្ញាណ។ ហេតុនេះជាបឋម កម្មវត្ថុនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួននឹងមិនអាចធ្វើបានឡើយ។ ជាចំណាត់ដើម្បីឆ្លើយតបនឹងករណីនេះ ចៅក្រមស៊ើបសួរជាដំបូងត្រូវធ្វើការស្រាវជ្រាវរកសាវតាជាតិ របស់បុគ្គលនោះជាមុនសិនតាមរយៈ ដីកាចាត់ឱ្យស៊ើបសួរជំនួស មុននឹងឈានទៅធ្វើការចេញដីកាបង្គាប់ឱ្យចូលខ្លួន។

យ៉ាងណាមិញ ជាករណីពិសេសដែលគួរឱ្យកត់សម្គាល់ផងដែរ។ ពេលខ្លះដីកាបង្គាប់ឱ្យចូលខ្លួនមិនត្រូវបានយក ទៅប្រើប្រាស់នៅក្នុងចំណាត់ការរបស់ចៅក្រមស៊ើបសួរឡើយ។ ករណីនេះយោងលើស្ថានភាពចាំបាច់នៃវិធានការនិរន្តរាយ [43]។ នោះគឺថា បន្ទាប់ពីសំណុំរឿង ត្រូវបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

[40] មាត្រា១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[41] មាត្រា១៨៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[42] ជនដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។

[43] វិធានការនិរន្តរាយជាវិធានដែលត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌនៃការស៊ើបសួរ ដើម្បីសំដៅធានាដល់ការស៊ើបសួរស្វែងរកការពិតនៃរឿងឱ្យប្រព្រឹត្ត ទៅបានល្អ និងមានប្រសិទ្ធិភាព។

ហើយត្រូវបានបញ្ជូន មកចំពោះមុខចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់អយ្យការ ជាការឆ្លើយតបទៅនឹង ស្ថានភាពចាំបាច់នៃការស្នើសុំរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឃាត់ខ្លួនបុគ្គលត្រូវចោទ និងដើម្បីធានានីតិវិធីនៃការស៊ើបសួរឱ្យបានល្អ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន ជាការជំនួសឱ្យការចេញដីកាបង្គាប់ឱ្យចូលខ្លួនក្នុងករណីដែលមានការស្នើសុំដោយមន្ត្រីនគរបាលយុត្តិធម៌។

**ឧទាហរណ៍៖** បន្ទាប់ពីមានករណីចោរកម្មកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន តាមរយៈការស៊ើបសួរអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌បានកំណត់មុខសញ្ញាណច្បាប់លាស់ថា ជនល្មើសជាមនុស្សដែលកំពុងរស់នៅក្នុងមូលដ្ឋាន ហើយពុំទាន់ធ្វើការគេចខ្លួននោះទេ។ យោងលើស្ថានភាពនេះ មន្ត្រីនគរបាលយុត្តិធម៌កសាងសំណុំរឿង និងធ្វើលិខិតស្នើសុំមកចំពោះមុខចៅក្រមស៊ើបសួរឱ្យមានចំណាត់ការជាចាំបាច់(ធ្វើការចាប់ខ្លួន)ចំពោះជនល្មើស។

ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួនបុគ្គលនោះ ជំនួសឱ្យការចេញដីកាបង្គាប់ឱ្យចូលខ្លួន។ នេះស្ថានភាពនៃការឆ្លើយតបដើម្បីជៀសវាងការរត់គេចខ្លួនរបស់ជនត្រូវចោទ ដែលនាំឱ្យជួបនូវការលំបាកក្នុងកិច្ចស៊ើបសួរ។

យ៉ាងណាមិញ បង្គាប់ឱ្យចូលខ្លួនអាចនឹងចេញច្រើនដងទៅលើបុគ្គលត្រូវចោទម្នាក់ ក្នុងករណីដែលបុគ្គលនោះ បានធ្វើការបដិសេធចំពោះការចូលមកបង្ហាញខ្លួន តាមរយៈដីកាបង្គាប់ឱ្យចូលខ្លួនដោយមានមូលហេតុត្រឹមត្រូវអាចឱ្យ ចៅក្រមស៊ើបសួរទទួលយកបាន។ ជាអាទិ៍មូលហេតុទាំងនេះជាករណី ជនត្រូវជាប់រវល់ក្នុងបេសកម្មការងារ កំពុងធ្វើការព្យាបាលជម្ងឺ ឬសុំពន្យាពេលចូលខ្លួនដើម្បីស្វែងរកមេធាវីការពារខ្លួនជាដើម។ ដោយយោងលើស្ថានភាពនេះចៅក្រមស៊ើបសួរ អាចអនុញ្ញាតឲ្យបុគ្គលនោះ ចូលមកបង្ហាញខ្លួននាពេលកំណត់ផ្សេងទៀត តាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន។

**ឧទាហរណ៍៖** បុរស **ក** ត្រូវបានតំណាងអយ្យការធ្វើការចោទប្រកាន់ពីបទះហិង្សាដោយចេតនាតាមរយៈដីកាសន្និបញ្ជូនរឿងឱ្យស៊ើបសួរមកចំពោះចៅក្រមស៊ើបសួរ។ បន្ទាប់ពីទទួលបានសំណុំរឿងចៅក្រមស៊ើបសួរបានផ្តើមចំណាត់ការទៅលើបុរស **ក** ដោយធ្វើការកោះហៅ (ដីកាបង្គាប់ឱ្យចូលខ្លួន) មកធ្វើការសួរចម្លើយ ឬស្តាប់ចម្លើយពាក់ពន្ធ័បទចោទប្រកាន់ខាងលើ។ ប៉ុន្តែដោយហេតុថា ខ្លួនមានជម្ងឺកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ បុរស **ក** អាចធ្វើការ ស្នើសុំមកចៅក្រមស៊ើបសួរ ឱ្យធ្វើការកោះហៅខ្លួន (បង្គាប់ឱ្យចូលខ្លួន)ជាថ្មី ដើម្បីឱ្យចូលទៅបង្ហាញខ្លួននៅពេលក្រោយ។

### ១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះនិទ្ទេសជាអាទិ៍ដូចតទៅ [44]៖

[44] មាត្រា១៨៧ និងមាត្រា ២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ពន្ធ័

-បទល្មើសដែលចោទប្រកាន់និង អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ

-ឈ្មោះ និង ឋានៈ របស់ចៅក្រមដែលចេញដីកា

-ដីកានេះ ត្រូវមានចុះលេខរៀងនៃការចេញដីកា សប្រតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឱ្យចូលខ្លួន។

-ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង

**កំណត់សម្គាល់ ៖**

ត្រូវមានចុះបញ្ជាក់អំពីចំណាត់បន្តរបស់ម្ចាស់ដីកាប្រាប់ទៅ ជនត្រូវចោទថាប្រសិនបើមិនព្រមចូលខ្លួនតាម កាលកំណត់ខាងលើដីកានេះទេ ម្ចាស់ដីកានឹងចេញ **ដីកាបង្គាប់ឱ្យនាំខ្លួន** ។

### ១.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន

បន្ទាប់ពីដីកាបង្គាប់ឱ្យចូលខ្លួនត្រូវបានដោយចៅក្រមស៊ើបសួរ រួចហើយដីកានេះនឹងត្រូវបញ្ជូនភ្លាមទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអាជ្ញាសាលា ដោយក្រឡាបញ្ជី ដើម្បីឱ្យមន្ត្រីដែលមានសមត្ថកិច្ចខាងលើនេះ យកដីកានោះទៅប្រគល់ដល់បុគ្គលដែលពាក់ពន្ធ័។ ជាទូទៅនៅពេលមន្ត្រីមានសមត្ថកិច្ចប្រគល់ដីកានេះ ដល់បុគ្គលដែលពាក់ពន្ធ័គាត់ត្រូវ បញ្ជាក់ប្រាប់ទៅបុគ្គលដែលជាកម្មវត្ថុនៃដីកានេះឱ្យទទួលយកចុងដីកាហើយត្រូវចុះ ហត្ថលេខា ឬ ផ្តិតស្រាម ដៃនៅលើដើមដីកានោះផងដែរ។ ប្រសិនបើបុគ្គលដែលជាកម្មវត្ថុនៃការចេញដីកានោះពុំព្រមទទួលយកដីកានេះ មន្ត្រីមានសមត្ថកិច្ចត្រូវចារលើដីកានោះដោយបញ្ជាក់អំពីមូលហេតុនៃការពុំព្រមទទួលយកដីកានោះ។ ជាចំណាត់ការបន្ត មន្ត្រីមានសមត្ថកិច្ចត្រូវបង្វិលភ្លាមនៅដីកានោះមកជូនចៅក្រមស៊ើបសួរវិញ តាមកាលវេលា ដ៏ឆាប់រហ័សដែលអាចធ្វើទៅបាន។ប្រសិនបើអ្នកទទួលបន្ទុក (មន្ត្រីមានសមត្ថកិច្ច) ក្នុងការជូនដំណឹង (ប្រគល់ដីកា) អំពីការបង្គាប់ឱ្យចូលខ្លួន នេះដល់បុគ្គលពាក់ពន្ធ័ ជួបនៅការលំបាកក្នុងការអនុវត្ត បេសកម្មរបស់ខ្លួន ត្រូវជូនដំណឹងអំពីការលំបាកនោះភ្លាមដល់ចៅក្រមស៊ើបសួរ [45]។

**ឧទាហរណ៍** ៖ លោក សុខ ជាមន្ត្រីអាជ្ញាសាលាដែលទទួលបន្ទុកក្នុងការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួនរបស់ចៅក្រមស៊ើបសួរ ទៅដល់វាសនា ដែលជាជនត្រូវចោទ នៅឯលំនៅឋានរបស់វាសនា ប៉ុន្តែនៅពេលយកដីកានេះ ទៅប្រគល់ឱ្យ **វាសនា** ស្រាប់តែមិនជួបអ្នកណា ម្នាក់សោះនៅក្នុងលំនៅឋានរបស់ **វាសនា** ជាច្រើន

[45] មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

លើកច្រើនសារ។ កត្តានេះជាមូលហេតុនៃការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។ ហេតុនេះគាត់ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ ឱ្យបានដឹងអំពីបញ្ហាលំបាកនេះភ្លាម។

សូមបញ្ជាក់ផងដែរថា ក្នុងក្របខណ្ឌនៃការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួនរបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចត្រឹមតែយកដីកានេះទៅប្រគល់ឱ្យជនដែលត្រូវបង្គាប់ឱ្យចូលខ្លួនប៉ុណ្ណោះ ដោយមិនមាន អំណាចចាប់បង្ខំ នាំខ្លួន ឬ ចាប់ខ្លួន បុគ្គលនោះ បញ្ជូនម្ចាស់ដីកា (ចៅក្រមស៊ើបសួរ)ឡើយ [46]។

### ១.៥. អានុភាពនៃដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួនមិនមានអានុភាពចាប់បង្ខំតាមរយៈ ការនាំខ្លួន ឬ ចាប់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ទៅលើបុគ្គលដែលជាកម្មវត្ថុនៃការចេញដីកា (ជនត្រូវចោទ) មកចំពោះមុខចៅក្រមស៊ើបសួរឡើយ។ បុគ្គលនោះ នៅពេលដែលខ្លួនទទួលបានដីកានេះរួចហើយ ខ្លួនអាចចូល ឬមិនចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដោយសេរី ពោលគឺ ដីកានេះគ្មានអានុភាពបង្ខំឡើយ។

ថ្វីត្បិតតែដីកាបង្គាប់ឱ្យចូលខ្លួនមិនមានអានុភាពដោយផ្ទាល់ ក្នុងការចាប់បង្ខំបុគ្គលនោះឱ្យត្រូវតែចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរក៏ពិតមែន តែវានឹងមានតម្លៃជាការជម្រុញទៅលើយន្តការនៃនីតិវិធីបន្ត ក្នុងករណីដែលបុគ្គលនោះបដិសេធក្នុងការចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ។ ចំណាត់ការបន្តបន្ទាប់ពីបុគ្គលត្រូវចោទបដិសេធមិនព្រមចូលខ្លួនតាមការបង្គាប់ឱ្យចូលខ្លួនជាធម្មតា នេះនាំឱ្យចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន បន្ថែមលើយន្តការចាស់នៃការចេញដីកាបង្គាប់ឱ្យចូលខ្លួន។

ប៉ុន្តែការបដិសេធពុំព្រមចូលខ្លួនរបស់បុគ្គលត្រូវចោទដោយមានមូលហេតុត្រឹមត្រូវឆ្លើយតបមកចំពោះចៅក្រមស៊ើបសួរវិញ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យពន្យារពេលនៃការចូលខ្លួនដល់បុគ្គលនោះបានផងដែរ។ ដីកាបង្គាប់ឱ្យចូលខ្លួន មិនមានអានុភាពធំធេងដូចដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួននោះទេ។ គួរឱ្យកត់សម្គាល់ផងដែរ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាបង្គាប់ឱ្យចូលខ្លួននេះ មិនមានអានុភាពជាកម្មនៃការយកទៅផ្សព្វផ្សាយជាសាធារណៈដើម្បីដាក់ឱ្យអនុភាពដោយមន្ត្រីនគរបាលយុត្តិធម៌លើវិសាលភាពដែនដីជាតិ ឬអន្តរជាតិនេះទេ។ នេះដោយហេតុថា ដីកាបង្គាប់ឱ្យចូលខ្លួននេះ មិនមានអានុភាពជាការចាប់បង្ខំនោះទេ។

## កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យនាំខ្លួន

### ២.១. អត្ថន័យនៃដីកាបង្គាប់ឱ្យនាំខ្លួន

ចៅក្រមស៊ើបសួរអាចចេញ ដីកាបង្គាប់ឱ្យនាំខ្លួន (មាត្រា ១៨៩) ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់និង នាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ [47]។

[46] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធម៌ បោះពុម្ពខែកុម្ភៈ ឆ្នាំ ២០០៦ ត្រង់ទំព័រទី ១៩ ។

[47] មាត្រា ១៨៩កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

### ២.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួនអាចត្រូវ ចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណា ម្នាក់ដែលមានតម្រុយពិរុទ្ធភាព [48]។ ជាទូទៅការចេញដីកាបង្គាប់ឱ្យនាំខ្លួន គឺធ្វើឡើងបន្ទាប់ពីចំណាត់ការនៃការចេញដីកាបង្គាប់ឱ្យចូលទៅលើបុគ្គលត្រូវចោទលែងមានប្រសិទ្ធភាពតទៅទៀត ឬលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួនជាលក្ខខណ្ឌចាំបាច់ក្នុងដើរតួនាទីជំនួសឱ្យដីកាបង្គាប់ឱ្យចូលខ្លួន។ នេះមានន័យថាជាធម្មតាដីកាបង្គាប់ឱ្យនាំខ្លួនតែងតែដើរតួនាទីតាមក្រោយបន្ទាប់ពីដីកាបង្គាប់ឱ្យចូលខ្លួន។ តែវាក៏មានករណីពិសេសធ្វើឱ្យដីកាបង្គាប់ឱ្យនាំខ្លួនបានដើរតួនាទីចម្បងជំនួសឱ្យដីកាបង្គាប់ឱ្យចូលខ្លួនផងដែរ។

**ឧទាហរណ៍៖** មន្ត្រីនគរបាលយុត្តិធម៌បានកសាងសំណុំរឿងបញ្ជូនមកអយ្យការ ហើយបានធ្វើលិខិតមួយស្នើសុំមកចំពោះអាជ្ញាធរតុលាការ(ចៅក្រមស៊ើបសួរ) ដោយបញ្ជាក់ពីការស្នើសុំឱ្យមាន ចំណាត់ការជាបន្ទាន់ចំពោះជនល្មើសដែលកំពុងគេចខ្លួននៅក្នុងមូលដ្ឋាន ទាក់ទងទៅនឹងបទល្មើសដូចដែលព្រះរាជអាជ្ញាបានចោទប្រកាន់នៅក្នុងសំណុំរឿង។

ហេតុនេះដើម្បីឆ្លើយតបទៅនឹងស្ថានភាពចំបាច់ខាងលើ ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យនាំខ្លួនទៅលើបុគ្គលត្រូវចោទជំនួសឲ្យការចេញដីកាបង្គាប់ឱ្យចូលខ្លួន។ ការចេញដីកាបង្គាប់ឱ្យនាំខ្លួនអាចនឹងធ្វើឡើងជំនួសឱ្យការចេញដីកាបង្គាប់ឱ្យចូលខ្លួនបាន។

យ៉ាងណាមិញចំណុចនៃនីតិវិធីដែលគួរឱ្យកត់សម្គាល់ផងដែរថា ពេលខ្លះដីការបង្គាប់ឱ្យនាំខ្លួននឹងមិនត្រូវបានចេញដោយចៅក្រមស៊ើបសួរឡើយ។ នេះមិនគិតបញ្ជូនអំពីការចូលខ្លួនជាធម្មតាតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួនឡើយ។ ចំណុចពិសេសនេះគឺថា ប្រសិនបើចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនហើយស្រាប់តែជនត្រូវចោទបានគេចខ្លួនបាត់ពុំព្រមចូលមកបង្ហាញខ្លួននិងដោយមានចំណារពីមន្ត្រីនគរបាលយុត្តិធម៌បញ្ជាក់ថាបុគ្គលដែលជាកម្មវត្ថុនៃការបង្គាប់ឱ្យចូលខ្លួននោះបានរត់គេចខ្លួនបាត់ បន្ទាប់ពីនៅពេលដែលបុគ្គលនោះបានទទួលដំណឹងអំពីការបង្គាប់ឲ្យចូលខ្លួន។ ហេតុនេះចៅក្រមស៊ើបសួរដោយយោងលើស្ថានភាពខាងលើគាត់អាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជំនួសឱ្យការចេញដីកាបង្គាប់ឱ្យនាំខ្លួន។

**ឧទាហរណ៍៖** ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនទៅលើបុគ្គល **ក** ដែលត្រូវបានអយ្យការធ្វើការចោទប្រកាន់ពីបទ អំពើលួច។ ស្រាប់តែនៅពេលបុគ្គល **ក** បានទទួលដំណឹងអំពីការបង្គាប់ឱ្យចូលខ្លួនតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ បុគ្គលនោះបានធ្វើការគេចខ្លួនចេញពីមូលដ្ឋានខាងលើបាត់តែម្តង។

ស្ថានភាពនៃការគេចវេសខាងលើ អាចឱ្យចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួនតែម្តងជំនួសឱ្យការចេញដីកាបង្គាប់ឱ្យនាំខ្លួន។

---

[48] មាត្រា ១៨៩កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

សូមបញ្ជាក់ថាដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចចេញបានទៅ លើសាក្សីឬដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

ស្របតាមស្មារតីនៃមាត្រា ១៩០ កថាខណ្ឌទី១ និងមាត្រា ១៩៦ កថាខណ្ឌទី៣ ទាក់ទងនឹងលក្ខខណ្ឌប្រតិបត្តិ តាមរយៈ ដីកាបង្គាប់ឱ្យនាំខ្លួននិងបង្គាប់ឱ្យចាប់ខ្លួនឃើញថាលក្ខខណ្ឌប្រតិបត្តិតាម រយៈដីកាទាំងពីរនេះបានអនុញ្ញាត ឱ្យមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការនាំខ្លួន ឬចាប់ខ្លួនជនត្រូវបានត្រូវបានដូចគ្នា។ ចំណោទសួរនោះគឺថា ប្រសិនបើដីកាទាំងពីរនេះ មានលក្ខខណ្ឌប្រតិបត្តិ (អានុភាព) ដូចគ្នា តើចាំបាច់អ្វីឱ្យចៅក្រមស៊ើបសួរចេញ ដីកាបង្គាប់ឱ្យចាប់ខ្លួន បន្ថែមលើការចេញដីកាបង្គាប់ឱ្យនាំខ្លួន។

ជាសញ្ញាណនៃចម្លើយខាងលើនេះ យើងត្រឡប់មកពិចារណាទៅលើឃ្លាមួយនៅក្នុងក្របខណ្ឌប្រតិបត្តិនៃដីកាបង្គាប់ឱ្យចាប់ខ្លួនដែលកំណត់ថា"ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាបញ្ជាះដល់កម្លាំងសាធារណៈឱ្យ **ស្រាវជ្រាវ** រកចាប់និងខ្លួនបុគ្គលនោះ"។ ឃ្លានេះមិនត្រូវបានចែងបញ្ជាក់នៅ ក្នុងក្របខណ្ឌនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននោះទេ។

ដូច្នេះ យើងអាចធ្វើការវិភាគបានថា លក្ខខណ្ឌខុសគ្នារវាងដីកាទាំងពីរនេះគឺថា ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវបានយកទៅប្រើប្រាស់ក្នុងស្ថានភាពដែលយើងបានដឹងយ៉ាងច្បាស់ពីកន្លែង ដែលជនត្រូវចោទកំពុងស្នាក់នៅ ចំណែកឯដីកាបង្គាប់ឱ្យចាប់ខ្លួន គឺត្រូវបានយកទៅប្រើប្រាស់លើស្ថានភាពដែលជនត្រូវចោទកំពុងស្នាក់នៅ ចំណែកឯដីកាបង្គាប់ឱ្យចាប់ខ្លួន គឺត្រូវបានយកទៅប្រើប្រាស់លើស្ថានភាពដែលជនត្រូវចោទរត់គេចខ្លួន ឬក្នុងស្ថានភាពដែលយើងពុំដឹងច្បាស់ពីទីកន្លែងពិតប្រាកដដែលជនត្រូវចោទកំពុងស្នាក់នៅ។ មួយវិញទៀត ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺអាចជាកម្មវត្ថុនៃការយកទៅផ្សព្វផ្សាយជាអន្តរជាតិ ដើម្បីដាក់ឱ្យអនុវត្តបានផងដែរ ផ្ទុយទៅវិញ លក្ខខណ្ឌដូចគ្នានេះ មិនអាចយកទៅប្រតិបត្តិបានឡើយចំពោះការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន។

### ២.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួនមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅ [49]៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញានៃបុគ្គលដែលពាក់ពន្ធ័
- បទល្មើសដែលចោទប្រកាន់និង អត្ថបទច្បាប់ដែលកំណត់និង បង្ក្រាបបទល្មើសនេះ
- ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា

ដីកាត្រូវចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឱ្យនាំខ្លួន ។

[49] មាត្រា ១៩១ និងមាត្រា ២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទនិងចុះហត្ថលេខដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ ការមិនគោរពនូវវិធានទម្រង់ការ និងទិន្នេសដូចបានបង្ហុលបង្ហាញខាងលើ នាំឲ្យដីកានេះនឹងមិនអាចមានតម្លៃជាកម្មវត្ថុក្នុងការយកទៅអនុវត្តបានឡើយ ។

### ២.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ដល់មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកទទួល បន្ទុកក្នុងការអនុវត្ត។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយទៅដល់គ្រប់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យាយ។ នេះមានន័យដីកាបង្គាប់ឱ្យនាំខ្លួនអាចជាកម្មវត្ថុក្នុងការធ្វើកាផ្សព្វផ្សាយលើវិសាលភាពដែនដីនៃព្រះរាជណាចក្រកម្ពុជា ទាំងមូល។ ចំពោះភាពបន្ទាន់នៃការអនុវត្តដីកានេះអាចមកពីមូលហេតុ ដែលជនត្រូវចោទព្យាយាមរត់គេចខ្លួនចេញពីដែនដីនៃព្រះរាជណាចក្រកម្ពុជា។ យ៉ាងណាមិញនីតិវិធីនៃការផ្សព្វផ្សាយដីកានេះអាចធ្វើឡើងតាមគ្រប់មធ្យាបាយជាអាទិ៍តាមរយៈទំព័រមានកាសែត ទូរទស្សន៍ វិទ្យុ ប្រពន្ធ័អ៊ិនធឺណេតជាដើម។ ក្នុងការទទួលបន្ទុក អនុវត្តដីកានេះ ដើមដីកា (សន្លឹកដីកាដែលមានបោះត្រាក្រហមដែលមិនថតចម្លង) ត្រូវប្រគល់ជូនបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ តាមរយៈក្រឡាបញ្ជី។

ទោះបីជាស្ថិតនៅក្នុងលក្ខខណ្ឌបន្ទាន់ក្នុងការអនុវត្តដីកានេះយ៉ាងណាក៏ដោយសិទ្ធិនៃលំនៅឋានត្រូវតែគោរព។ នេះមានន័យថា មន្ត្រីនគរបាលយុត្តិធម៌មិនអាចមិនអាចចូល ទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ពន្ធ័មុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាចបានទេ។

មួយវិញទៀតប្រសិនបើស្ថិតនៅក្នុងបេសកកម្មនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនជួបនូវការលំបាកមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងអំពីការលំបាកនោះទៅដល់ចៅក្រមស៊ើបសួរ [50]។

បន្ទាប់ពីធ្វើការនាំ ឬចាប់ខ្លួនជនដែលពាក់ពន្ធ័បានហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ គឺដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការយកចម្លើយ ឬស្តាប់ចម្លើយពាក់ពន្ធ័នឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ដោយស្ថិតនៅក្នុងជម្រើសរបស់ខ្លួន ចៅក្រមស៊ើបសួរអាចសម្រេចធ្វើការឃុំខ្លួន ឬ មិនឃុំខ្លួន (ដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) បុគ្គលនោះ។ ជាការគួរឱ្យកត់សម្គាល់នៅក្នុងការអនុវត្តជាក់ស្តែងលក្ខខណ្ឌនៃការឃុំខ្លួនអាចជាជម្រើសច្រើនរបស់ចៅក្រមស៊ើបសួរក្នុងករណីបទល្មើសដែលចោទប្រកាន់ទៅលើបុគ្គលនោះជាប្រភេទបទល្មើសធ្ងន់ធ្ងរ (បទឧក្រិដ្ឋ) ឬអាស្រ័យលើបុគ្គលិកលក្ខណៈនៃបុគ្គលនោះផ្ទាល់តែម្តង។

[50] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

**ឧទាហរណ៍៖** បុរស **ក** ត្រូវបានចោទប្រកាន់ពីបទ **ឃាតកម្មគិតទុកជាមុន។** នៅក្នុងរង្វង់ប្រតិបត្តិការណ៍នៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន បុរសនោះបានព្យាយាមគេចវេស និងបានសម្តែងអត្តចរិកច្រឡោតដាក់មន្ត្រីនគរបាលយុត្តិធម៌ទៀតផង។

ដោយយោងលើស្ថានភាពធ្ងន់ធ្ងរនេះ ចៅក្រមស៊ើបសួរត្រូវសម្រេចធ្វើការឃុំខ្លួនជននោះ។ ជាគោលការណ៍មន្ត្រីនគបាលយុត្តិធម៌ ត្រូវតែនាំខ្លួនបុគ្គលដែលជាកម្មវត្ថុនៃការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ប៉ុន្តែប្រសិនបើមានមូលហេតុនៃកាលៈទេសៈដែលមិនអាចធ្វើការនាំខ្លួនបុគ្គលដែលពាក់ពន្ធ័ ទៅចំពោះមុខចៅក្រមស៊ើបសួរបានភ្លាម ក្រោយពេលឃាត់ខ្លួននោះទេ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការនាំ ខ្លួនបុគ្គលនោះទៅរក្សាទុកនៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួនឬទៅក្នុងពន្ធនាគារ។ បន្ទាប់មកជាដាច់ខាតមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំបុគ្គលនោះ ទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់នៅចំពោះមុខចៅក្រមស៊ើបសួរឬ ដល់អ្នកជំនួស។ ប៉ុន្តែ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែដោះលែងជននោះឱ្យមានសេរីភាពវិញ [51]។ កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវ បានឃុំខ្លួននោះចិរវេលានៃការឃុំខ្លួននោះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន [52]។

**ឧទាហរណ៍៖** បុរស ក ជាប់ចោទពីបទ៖ អំពើលួច ដែលជាបទល្មើសមជ្ឈឹម។ ចិរវេលានៃកាឃុំខ្លួនក្នុងបទល្មើសមជ្ឈឹមមិនអាចលើសពី ៤(បួន) ខែបានទេ។ ប៉ុន្តែអាចពន្យារបាន២ខែ (ពីរ)ខែទៀត។ ពោលគឺចិរវេលានៃការឃុំខ្លួនសរុបនៃបទល្មើសមជ្ឈឹមទៅលើបុរស ក មិនអាចលើសពី៦ (ប្រាំមួយ)ខែ បានឡើយ។ ហេតុនេះ ចិរវេលានៃការឃាត់ខ្លួនដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវគិតបញ្ចូលក្នុងរយៈពេល០៦ខែ នៃការឃុំខ្លួនបណ្តោះអាសន្នផងដែរ។

គួរកត់សម្គាល់ផងដែរថាពេលខ្លះលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួនមិនត្រូវបានធ្វើឡើងឡើយ។ ករណីនេះដោយមូលហេតុថា ឆ្លើយតបទៅនឹងដីកាបង្គាប់ឱ្យចូលខ្លួន ជនត្រូវបានបានរត់គេចខ្លួនបាត់ ដែលធ្វើឱ្យនីតិវិធីនៃការនាំខ្លួនជននោះជួបនៅការលំបាក។ ហេតុនេះ ជាការជំនួសឱ្យដីកាបង្គាប់ឱ្យនាំខ្លួនដែលមានលក្ខខណ្ឌអនុវត្តបានតែក្នុងដែនដីកម្ពុជា ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជននោះបានតែម្តងដោយមិនចាំបាច់ចេញដីកាបង្គាប់ឱ្យនាំខ្លួនទៀតនោះទេ។

[51] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[52] មាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

### ២.៥. អានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួនមានអានុភាពបញ្ជាដល់កម្លាំងសាធារណៈឱ្យចាប់និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ពោលដីកានេះគឺជាប្រភេទ ដីកាដែលអានុភាពបង្ខំ។ មាត្រា១៩៣ នៃក្រមព្រហ្មទណ្ឌ ប្រសិនបើមានមូលហេតុនៃកាលៈទេសៈ បន្ទាប់ពីធ្វើការឃាត់ខ្លួនមិនអាចបញ្ជូនខ្លួនទាន់ពេលវេលា មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិរក្សាទុកជនត្រូវចោទ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំខ្លួនជនត្រូវចោទទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ក្រោយពេលឃាត់ខ្លួន។ ប្រសិនបើមិនអាចនាំខ្លួនជននោះទៅបង្ហាញខ្លួននៅចំពោះចៅក្រមស៊ើបសួរនាថ្ងៃបន្ទាប់នោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវដោះលែងជននោះឱ្យមានសេរីភាពវិញ។ នេះមានន័យថា ថិរវេលានៃការឃាត់ខ្លួនតាមរយៈអានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួនដោយមន្ត្រីនគរបាលយុត្តិធមនិងមិនអាចធ្វើការឃាត់ខ្លួន (ឃុំខ្លួន) ជនណាម្នាក់លើសពីរយៈពេល៤៨ម៉ោងនោះទេ។

ក្នុងកិច្ចអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដីកានេះអាចមានអានុភាពជាកម្មវត្ថុក្នុងការយកទៅផ្សព្វផ្សាយតាមគ្រប់មធ្យោបាយលើដែនដីវិសាលភាពនៃព្រះរាជណាចក្រកម្ពុជាទាំងមូល។ ប៉ុន្តែដីកានេះមិនអាចមានអានុភាពទូលំទូលាយជាកម្មវត្ថុក្នុងការផ្សព្វផ្សាយ ជាអន្តរជាតិដូចដីកាបង្គាប់ឱ្យចាប់នោះទេ។

## កថាខណ្ឌ៣៖ ដីកាបង្គាប់ឱ្យចាប់ខ្លួន

### ៣.១. អត្ថន័យនៃដីកាបង្គាប់ឱ្យចាប់ខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន (មាត្រា ១៩៥) ដីកាបង្គាប់ឱ្យចាប់ខ្លួនជាបញ្ជារបស់ចៅក្រមស៊ើបសួរបង្គាប់ឱ្យកម្លាំងសាធារណៈទាំងអស់ស្រាវជ្រាវរកចាប់ខ្លួនជនត្រូវចោទ ឬ បុគ្គលណាម្នាក់ ដែលមានតម្រុយពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសួរយកចម្លើយ ពាក់ពន្ធ័ទៅនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា [53]។

### ៣.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន

*មាត្រា ១៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់សិទ្ធិឲ្យ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។*

លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរ នឹងអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលុះត្រាតែ៖

១. បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈឹម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

២. បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

---

[53] មាត្រា ១៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

លក្ខខណ្ឌពីរយ៉ាងដែលបានកំណត់នៅក្នុងមាត្រា ១៩៦ ខាងលើនេះជាលក្ខខណ្ឌចាំបាច់ដែលត្រូវតែគោរព។ ការមិនគោរពនូវវិធានខាងលើអាចនាំឱ្យមានមោឃភាពនៃនីតិវិធី។

ទោះបីជាបានបំពេញតាមលក្ខខណ្ឌខាងលើហើយក៏ដោយ ដីកានេះមិនអាចធ្វើការចេញភ្លាមដោយចៅក្រមស៊ើបសួរដោយមិនបានជូនដំណឹង (សុំយោបល់) ព្រោះដោយយោងលើហេតុផល ក្នុងនាមព្រះរាជអាជ្ញាជាម្ចាស់នៃបណ្ដឹងអាជ្ញាហើយគាត់ជាអ្នកទទួលបន្ទុកអនុវត្តនិងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួនផ្ទាល់តែម្ដង[54] ការជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការស្នើសុំចាប់ខ្លួន របស់ចៅក្រមស៊ើបសួរត្រូវធ្វើឡើងតាមរយៈដីកាបញ្ជូនឱ្យឆ្លើយ។ ចំពោះយោបល់នៃការឆ្លើយតបលើការចាប់ខ្លួនរបស់ព្រះរាជអាជ្ញាមិនចងកាតព្វកិច្ចដល់ចៅក្រមស៊ើបសួរត្រូវតែធ្វើតាមនោះទេ។ ចៅក្រមស៊ើបសួរអាចចេញ ដីកាបង្គាប់ឱ្យចាប់ខ្លួនទៅលើជនត្រូវចោទបានដោយមូលហេតុ (សំអាងហេតុ និង សំអាងច្បាប់) ត្រឹមត្រូវ។

### ៣.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួន

**ដីកាបង្គាប់ឱ្យចាប់ខ្លួនមានទិន្នេសសំខាន់ៗ ជាអាទិ៍ដូចតទៅ** [55]**៖**

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ពន្ធ័

-បទល្មើសដែលចោទប្រកាន់ និង អត្ថបទច្បាប់ដែលសកំណត់បង្កជាបទល្មើសនេះ

-ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។

-ដីកានេះត្រូវមានចុះលេខរៀលនៃការចេញដីកាស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឱ្យចាប់ខ្លួន។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង។ ការមិនបានបញ្ជាក់ឲ្យបានច្បាស់នៃនិទ្ទេសសំខាន់ខាងលើនៅក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួននោះដីកានេះ នឹងពុំមានអានុភាព ឬតម្លៃគតិយុត្តដែលមានអាចឱ្យទទួលយកបានទៅអនុវត្តនោះទេ។

### ៣.៤. នីតិវិធីនៃការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន

ការមិនអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់អស់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនរគបាល ឬកងរាជអាវុធហត្ថ តាមគ្រប់មធ្យាបាយ (ការសែតទូរទស្សន៍ វិទ្យុ ឬ ប្រពន្ធ័អ៊ិនធឺណេត) ជាដើម។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រី

[54] មាត្រា កថាខណ្ឌចុងក្រោយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[55] មាត្រា ១៩៨ និងមាត្រា ២៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

នគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ ទោះបីជាដីកានេះមានអានុភាពយ៉ាងណាក៏ដោយ ប៉ុន្តែអភ័យឯកសិទ្ធិនៃលំនៅឋានត្រូវតែគោរព។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានត្រូវតែគោរព។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ពន្ធ័មុនម៉ោង៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងចៅក្រមស៊ើបសួរ អំពីការលំបាកទាំងអស់ ក្នុងពេលអនុវត្តបេសកម្មរបស់ខ្លួន [56]។

ដីកាបង្គាប់ឱ្យចាប់ខ្លួនមិនត្រឹមតែអាចជា កម្មវត្ថុនៃការផ្សព្វផ្សាយជាសាធាណៈ ក្នុង ដែនដីនៃព្រះរាជណាចក្រកម្ពុជានោះទេ។ ប៉ុន្តែក្នុងករណីចាំបាច់ ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព [57]។ នេះសបញ្ជាក់បានថា ការអនុវត្តដីកាបង្គាប់ឱ្យចាប់ ខ្លួនអាចធ្វើឡើងលើដែនវិសាលភាពជាអន្តរជាតិបាន។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនជាអន្តរជាតិ គឺតម្រូវឱ្យមន្ត្រីនគរបាលយុត្តិធម៌ នៃព្រះរាជណាចក្រម្ពុជា ចូលរួមសហការជាមួយប៉ូលីសអន្តរជាតិ (Police Interpol) ដែលមានសមត្ថកិច្ច ដើម្បីស្រាវជ្រាវស្វែងចាប់ខ្លួនជនត្រូវចោទដែលបានរត់គេចខ្លួនឆ្លងប្រទេស។

ក្នុងករណីដែលបុគ្គលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំខ្លួនជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ [58]។ យ៉ាងណាមិញ ដីកាបង្គាប់ឱ្យចាប់ខ្លួន ក៏ជាលិខិត បញ្ជាក់ឱ្យឃុំខ្លួនស្របច្បាប់របស់អាជ្ញាធរតុលាការផងដែរ [59]។ ហេតុនេះប្រសិនបើជនដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន មិនត្រូវបានបញ្ជូនខ្លួនភ្លាមតាមការកំណត់នោះទេ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នសិន។

ប្រសិនបើបុគ្គលពាក់ពន្ធ័មិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន ព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនត្រូវទទួលភារកិច្ច ស្តាប់ចម្លើយឬសួរយកចម្លើយបុគ្គលនោះ។ ព្រះរាជអាជ្ញានោះ ត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយបញ្ជូនទៅចៅក្រមស៊ើបសួរដែលទទួលបន្ទុកស៊ើបសួរលើសំណុំរឿងនោះ [60]។ ជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញា ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះតម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ពន្ធ័ទៅពន្ធនាគារឬមណ្ឌលឃុំខ្លួនមួយផ្សេងទៀតការផ្ទេរនេះត្រូវចាត់ចែងដោយព្រះរាជអាជ្ញា ។

[56] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[57] មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[58] មាត្រា ២០១ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[59] មាត្រា ១៩៦ កថាខណ្ឌចុងក្រោយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[60] មាត្រា ២០១ កថាខណ្ឌចុងក្រោយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ជានីតិវិធីដែលត្រូវកត់សម្គាល់ផងដែរថា ពេលខ្លះជនត្រូវចោទដែលជាកម្មវត្ថុនៃការដីកាបង្គាប់ឱ្យចាប់ខ្លួននោះ នឹងមិនត្រូវបានបញ្ជូនទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនោះទេ។ នេះដោយហេតុថា នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួនហើយ គាត់បានសម្រេចបិទបញ្ចប់ការស៊ើបសួររបស់គាត់ដោយបញ្ជូនសំណុំរឿងនោះមកជំនុំជម្រះ ដែលស្ថិតនៅក្រោយសមត្ថកិច្ចរបស់យុត្តាធិកាជំនុំជម្រះ (ចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះ)។ ក្នុងករណីនេះ បុគ្គលនោះត្រូវតែបញ្ជូនខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះ ដើម្បីបើកសវនាមុខអង្គសេចក្តីជំនុំជម្រះសម្រេចអំពី ឬមិនឃុំខ្លួ ជននោះ ប្រសិនបើទាន់ដល់កាលកំណត់នៃសវនាអង្គសេចក្តី។

### ៣.៥. អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរមានអានុភាពបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់និងឲ្យនាំខ្លួនបុគ្គលត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព មកចំពោះមុខចៅក្រមស៊ើបសួរ។ យ៉ាងណាមិញ ដីកានេះក៏មានអានុភាពជាលិខិតបញ្ជា (លិខិតឃុំខ្លួនស្របច្បាប់)ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួលនិងឃុំខ្លួនបុគ្គលនោះបានផងដែរ។

ជាទូទៅ ដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរអាចចេញបានតែទៅលើត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។ ជនទាំងនោះ គឺសំដៅលើបុគ្គលទាំងឡាយណាដែលត្រូវបានព្រះរាជអាជ្ញាផ្ដើមចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកចំពោះមុខចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ នេះមានន័យថា ដីកានេះមិនមានអានុភាពក្នុងការចេញទៅលើបុគ្គលផ្សេងទៀត (សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ) ក្រៅពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាដូចមានឈ្មោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ ជាអានុភាពនៃការអនុវត្តដីកានេះអាចជាកម្មវត្ថុនៃការផ្សព្វផ្សាយជាសាធារណៈលើដែនដីជាត(ក្នុងប្រទេស) និងជាអន្តរជាតិផងដែរ។ ទោះបីជាបន្ទាប់ពីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនហើយ ចៅក្រមស៊ើបសួរបានសម្រេចបិទបញ្ចប់ការស៊ើបសួររបស់ខ្លួនដោយដីកាដំណោះស្រាយ ដែលដីកាដំណោះស្រាយនេះមានអានុភាពបិទបញ្ចប់កិច្ចស៊ើបសួរយ៉ាងណាក៏ដោយ ក៏ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាពដដែល ដរាបណាបណ្ដឹងអាជ្ញាមិនទាន់រលត់។ ដីកាដំណោះស្រាយ មិនអាចលុបលាងអានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួននោះទេ។

## ផ្នែកទី៦៖ ការចេញដីកាក្នុងករណីមិនមានសាងតាជាតិរបស់ជនត្រូវចោទ

### កថាខណ្ឌ១៖ ដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស

### ១.១. អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរ ដែលកំពុងតែបំពេញការស្រាវជ្រាវសំណុំរឿងក្តីដែលមាននៅក្នុងដៃខ្លួនហើយ យល់ឃើញថាមានភាពចាំបាច់សំរាប់ធ្វើកិច្ចអ្វីមួយ ដើម្បីបំភ្លឺដល់អង្គហេតុ ឬភាពសង្ស័យរបស់ខ្លួនដែលខ្លួនមិនអាច

ចុះទៅបំពេញ កិច្ចនោះបានទេដោយសារតែស្ថានភាព និងកាលៈទេសៈពិសេសដែលធ្វើឱ្យចៅក្រមស៊ើបសួរពិបាកក្នុងការធ្វើដំណើរនិង ត្រូវចំណាយច្រើនក្នុងការចុះទៅកន្លែងឆ្ងាយៗ ពីទីកន្លែងប្រព្រឹត្តបទល្មើស ឬមានឧបសគ្គចំពោះការធ្វើដំណើរទៅមកនោះ ចៅក្រមចៅក្រមស៊ើបសួរអាចពឹងពាក់បុគ្គល ដែលច្បាប់បានផ្តល់នូវសម្បទាក្នុងការធ្វើកិច្ចការនេះ មកជំនួសខ្លួនដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលអាចជាចៅក្រមសាលាដំបូង ឬ មន្ត្រីនគរបាលយុត្តិធម៌ [61]។

**ដូចក្នុងករណី៖** បទល្មើសចរាចរណ៍កើតឡើងនៅ **ខេត្តរតនៈគីរី** តែក្រោយមកជនត្រូវចោទបានរត់មករស់នៅ ខេត្តកណ្តាល ចៅក្រមស៊ើបសួរនៅ**ខេត្តរតនៈគីរី** អាចធ្វើការចាត់តាំងចៅក្រមសាលាដំបូងខេត្តកណ្តាល ឱ្យស៊ើបសួរ ជំនួស និង**បញ្ជូនកំណត់ហេតុទៅសាលាដំបូងខេត្តរតនៈគីរីវិញតែម្តង**។

### ១.២. លក្ខខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

ចំពោះការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចដែលមានចែងក្នុងដីកាចាត់ចែងស៊ើបឱ្យជំនួស នៅក្នុងដែនសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែមានបញ្ញាត្តិនៃមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ [62]។ ការបំពេញកិច្ចនេះមន្ត្រីនគរបាលយុត្តិធម៌គឺស្ថិតនៅក្រោមអំណាច របស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូន ចៅក្រមស៊ើបសួរអំពីការស្រាវជ្រាវនិងការពិនិត្យរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្ដីអំពីការស្រាវជ្រាវ និងការពិនិត្យនោះ [63] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស

**ដីកាចាត់ឱ្យស៊ើបសួរជំនួសមានទិន្នេសសំខាន់ៗ ជាអាទិ៍ដូចតទៅ៖**

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ពន្ធ័

-បទល្មើសដែលចោទប្រកាន់ និង អត្ថបទច្បាប់ដែលសកំណត់ជាបទល្មើសនេះ

-ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។

-ដីកានេះត្រូវមានចុះលេខរៀលនៃការចេញដីកាស្របតាមលំដាប់លេខរៀងនៃសៀវភៅ

ដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវមានចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង។

---

[61] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[62] មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[63] មាត្រា ១៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

### ១.៤. អានុភាពនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

#### ក. ការចាត់តាំងចៅក្រមផ្សេងៗឱ្យស្រាវជ្រាវជំនួស

ចៅក្រមស៊ើបសួរក្រោយពីសិក្សាពីសំណុំរឿង និង បានស្រាវជ្រាវតាមស្វែងរកតម្រុយដំណើររឿងក្ដីកន្លងមក ហើយមានចំណុចណាមួយដែលគិតថាសង្ស័យថា និងអាចនាំទៅរកនូវការពិតរឿងហេតុបានក្រោយពីមានបទល្មើសព្រហ្មទណ្ឌបានកើតឡើង។ ចៅក្រមស៊ើបសួរ អាចចាត់ចៅក្រមសាលាដំបូងណាម្នាក់ឱ្យបំពេញកិច្ចការណាមួយជំនួស ខ្លួនក្នុងលក្ខខណ្ឌៈ ជាការសម្ងាត់ ដើម្បីអាចបង្ហាញនូវភាពត្រឹមត្រូវដែលកើតចេញពីបទល្មើសនោះ។ ក្នុងករណីពិសេសដែលចៅក្រមស៊ើបសួរយល់ឃើញថាមានភាពបន្ទាន់ អាចធ្វើការចាត់តាំងចៅក្រមស៊ើបសួរជំនួសដែលមាន សមត្ថកិច្ចកំពុងស្ថិតនៅទីតាំង ឬទីកន្លែងដែលត្រូវចុះទៅបំពេញនោះ ឱ្យធ្វើកិច្ចការស្រាវជ្រាវនោះតាមរយៈ ដីកាសម្រេចចាត់តាំងឱ្យស៊ើបសួរជំនួសត្រូវចេញឲ្យចៅក្រមស៊ើបសួរជំនួស ដោយប្រើប្រាស់វិធានគ្រប់បែបយ៉ាងដែលមានចែងក្នុងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរជំនួស ដោយប្រើប្រាស់វិធានគ្រប់បែបយ៉ាងដែលមានចែងក្នុងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដើម្បីសម្រេចនូវគោលបំណងដែលចៅក្រមស៊ើបសួរចង់បានក្រោយពីការប្រតិបត្តិការណ៍ក្នុងដស្រាវជ្រាវជំនួស ប៉ុន្តែលើកលែងចំពោះករណីពិសេសដែលចៅក្រមស៊ើបសួរជំនួសមិនអាចធ្វើបានឡើយ(ចេញដីកាសម្រេចផ្សេងៗ ដែលទាក់ទង និង សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ) ដោយសារតែការស៊ើបសួរជំនួស មានគោលបំណងផ្ដល់អំណាចនៃការស្រាវជ្រាវបទល្មើសតាមការណែនាំដោយ ចៅក្រមស៊ើបសួរ។ ដូចជាករណី ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល បានចេញដីកាចាត់តាំងចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ឱ្យស៊ើបសួរជំនួសក្នុងបទល្មើស "ហិង្សាដោយចេតនា" ប្រព្រឹត្តដោយជនត្រូវចោទ ត ដែលកំពុងរស់នៅខេត្តខាងលើ ដោយណែនាំឲ្យចៅក្រមសាលាដំបូងចេញដីកាបង្គាប់ឱ្យចូលខ្លួនធ្វើកំណត់ហេតុសួរចម្លើយ និង បញ្ជូនសំណុំឯកសាររបស់ជនត្រូវចោទមកសាលាដំបូងខេត្តកណ្ដាលយ៉ាងឆាប់តាមការដែលអាចធ្វើបាន។

#### ខ. ចៅក្រមសាលាដំបូងក្នុងសមត្ថកិច្ច

គេអាចចាត់តាំងចៅក្រមសាលាដំបូង ដែលខ្លួនកំពុងស្ថិតតែនៅជាមួយគ្នា អាចធ្វើទៅបានដោយសារតែមានភាពចាំបាច់ ក្នុងករណីដែលខ្លួនមិនអាចបំពេញកិច្ចការស្រាវជ្រាវទីនោះច្រើនដែលមិនអាចចាត់តាំងដោយមានការចង្អុលឈ្មោះ ចៅក្រមដោយផ្ទាល់នោះឡើយ ច្រើនតែបញ្ជូនទៅប្រធានសាលាដំបូងតាមបែបបទរដ្ឋបាលដោយប្រធានអាចធ្វើការចាត់តាំងបន្ត ចូលមកដល់ចៅក្រមណាមួយដែលទទួលបន្ទុកក្នុងការចំណាត់ការទៅលើដីកាសម្រេចតាំងឱ្យស៊ើបសួរជំនួសនោះតែម្ដង។

#### គ. ចៅក្រមសាលាដំបូងផ្សេងទៀត

ដោយសារតែ កាលៈទេសៈដែលតម្រូវក្នុងការស្រាវជ្រាវនូវតម្រុយ ឬស្វែងរកនូវចំណុចសំខាន់ណាមួយ ដែលចាំបាច់ធ្វើការស្រាវជ្រាវជំនួសដោយចៅក្រមស៊ើបផ្សេងទៀត ក្រៅសមត្ថកិច្ចដែនដីផ្សេងគ្នាឲ្យបំពេញកិច្ចស្រាវជ្រាវជំនួសខ្លួនប្រសិនជាយល់ឃើញថាមានភាពចាំបាច់សំរាប់បង្ហាញនូវពិរុទ្ធភាពនៃជនត្រូវចោទនោះ អាចធ្វើការចាត់តាំងបានទៅកាន់ចៅក្រមសាលាដំបូងដែលខ្លួនចង់ឱ្យបំពេញកិច្ចស្រាវជ្រាវនោះក្នុងនាមខ្លួនបាន។

**ឃ. ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវជំនួស**

តាមត្រូវការជាក់ស្តែង ដើម្បីភាពងាយស្រួលក្នុងការស្រាវជ្រាវបទល្មើសមួយផ្នែកនោះចៅក្រមស៊ើបសួរច្រើនតែចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ ឱ្យបំពេញកិច្ចស្រាវជ្រាវណាមួយដែលមានលក្ខណៈ មិនសូវមានភាពស្មុគស្មាញ និងបច្ចេកទេសខ្លាំងក្នុងការស្វែងរកតម្រុយមានសមត្ថភាពល្មមដែលមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើបានហើយមិនមានភាពចាំបាច់ណាស់ណាទេត្រូវតែធ្វើនោះឡើយនិងត្រូវបានកម្រិតភារកិច្ចឲ្យបំពេញកិច្ចស្រាវជ្រាវទៅលើផ្នែកណាមួយដោយកំណត់ច្បាស់លាស់ ក្នុងខ្លឹមសារ នៃដីកាសម្រេច ចាត់តាំងឱ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលមិនអនុវត្តផ្ទុយពីខ្លឹមសារទេ [64]។

**ខ.មន្ត្រីរាជការសាធារណៈដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌**

មន្ត្រីដែលមិនមែនជានគរបាលជាតិ ឬកងរាជអាវុធហត្ថដែលច្បាប់ដោយឡែកបានផ្តល់នីតិសម្បទាឱ្យក្លាយជា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើអាចធ្វើការបំពេញកិច្ចស្រាវជ្រាវនោះ ណាមួយដែលមាន លក្ខខណ្ឌៈ បច្ចេកទេសពិសេសទៅលើបទល្មើសនោះ [65]។ ចៅក្រមស៊ើបសួរដែលយល់ឃើញថាមានភាពចាំបាច់ ដើម្បីបំពេញកិច្ចស្រាវជ្រាវអាចធ្វើការចាត់តាំងមន្ត្រីដែលមានសមត្ថកិច្ចខាងបទល្មើសនោះឱ្យជួញស្រាវជ្រាវ និងតាមដានទៅលើផ្នែកណាមួយមានប្រយោជន៍បង្ហាញនូវការពិត ឬស្វែងរកភស្តុតាងមកបញ្ជាក់អំពីរបស់ជនត្រូវចោទដែលមបានប្រព្រឹត្តបទល្មើសនោះ។

**ដូចករណី៖** បទល្មើសនេសាទបទល្មើសពុករលួយ បទល្មើសគេចពន្ធបទល្មើសព្រៃឈើ.ល.។

[64] មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[65] មាត្រា ៥៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

# ជំពូកទី ២

# ការចេញដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ ចំពោះកិច្ចនៃនីតិវិធីដោយឡែក

# ជំពូកទី២

# ការចេញដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរ ចំពោះកិច្ចនៃនីតិវិធីដោយឡែក

## ផ្នែកទី១៖ ការចេញដីកាក្នុងកិច្ចស៊ើបសួរស្រាវជ្រាវស្វែងរកការពិត

### កថាខណ្ឌ១. ដីកាបង្គាប់ឱ្យឆែកឆេរ

#### ១.១. អត្ថន័យនៃដីកាបង្គាប់ឱ្យឆែកឆេរ

ដីកាបង្គាប់ឱ្យឆែកឆេរ មានន័យថាជាដីកាដែលធ្វើការឆែកឆេរ ដើម្បីស្វែងរកភស្តុតាង ដែលចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន។

#### ១.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យឆែកឆេរ

ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខ អ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី២(ពីរ)នាក់ ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថដែលជាកងកំលាំងរួមប្រតិបត្តិការឆែកឆេរនោះបានឡើយ។ ចៅក្រមស៊ើបសួរ មិនអាចចាប់ផ្តើមឆែកឆេរមុនម៉ោង៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី) ល្ងាចបានទេលើកលែងតែ [66]៖

-ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរចែកចាយ ឬប្រើប្រាស់គ្រឿងញៀន

#### ១.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យឆែកឆេរ

ដីកានេះមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅ ៖

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញានៃបុគ្គលដែលពាក់ពន្ធ័

-បទល្មើសដែលចោទប្រកាន់និង អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា

-ដីកាត្រូវចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឱ្យនាំខ្លួន ។

#### ១.៤. អានុភាពនៃដីកាបង្គាប់ឱ្យឆែកឆេរ

##### ក. ការឆែកឆេរ លំនៅឋាន ឬទីសំណាក់

ចៅក្រមស៊ើបសួរ អាចធ្វើការឆែកឆេរនៅគ្រប់ទីកន្លែងនៅគ្រប់ទីកន្លែងដែលមានការពាក់ព័ន្ធនឹងបទល្មើសដែលបានកើតឡើង និងទីកន្លែងដែលមានការសង្ស័យថា អាចមានវត្ថុតាងលាក់បាំងមើលមិនឃើញ

[66] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

តែជាករណីលើកលែង ចំពោះទីកន្លែងពិសេសមួយចំនួនដូចជា (ស្ថានទូត ឬស្ថានអគ្គកុងស៊ុល) ចៅក្រមស៊ើបសួរមិនអាចចូលទៅធ្វើការឆែកឆេរបានឡើយ។ ចៅក្រមស៊ើបសួរ អាចចូលទៅធ្វើការឆែកឆេរនៅទីតាំងដែលបិទជិតគួរអោយសង្ស័យថាមានអ្វីមួយដែលមិនអាចមើលឃើញថា ប្រសិនជា មិនចូលទៅរុករកនៅក្នុងទីកន្លែងនោះ ដោយមានអមជាមួយកម្លាំងសាធារណៈ [67]។ វិធានការអនុវត្តចំពោះការឆែកឆេរនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ជាគោលការណ៍ ចៅក្រមស៊ើបសួរត្រូវតែធ្វើការឆែកឆេរនៅតែចំពោះមុខអ្នកកាន់កាប់ទីកន្លែង (ទាំងកម្មសិទ្ធិ និងអ្នកកាន់កាប់ផ្ទាល់) ប៉ុន្តែចំពោះទីកន្លែង ឬទីសំណាក់គ្មានអ្នកកាន់កាប់ ចៅក្រមស៊ើបសួរត្រូវតែធ្វើការចាត់តាំងដោយដីកាសម្រេចចំពោះពីររូប ដែលមិនមែនជាអ្នករួមប្រតិបត្តិការណ៍ជាមួយខ្លួនទេ។ សាក្សីអាចជាប្រជាពលរដ្ឋដែលរស់នៅជិតខាង ឬជ្រើសរើសដូចជា មេភូមិ និងមេឃុំ / ចៅសង្កាត់ តែម្តងដើម្បីធ្វើជាសាក្សីដឹងឮ និងធានានូវភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ដោយមិនអោយមានការបាត់បង់នូវទ្រព្យសម្បត្តិឯកជន។ ជាគោលការណ៍ម៉ោងពេលវេលានៃការឆែកឆេរជារឿងចាំបាច់ ដែលច្បាប់កំណត់អំពីសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងពេលប្រតិបត្តិការណ៍ឆែកឆេរ មិនអាចធ្វើឡើង មុនម៉ោង ៦ព្រឹក និងក្រោយម៉ោង១៨ល្ងាចបានឡើយ។ ធានានូវការមិនរំខានការសម្រាករបស់ប្រជាពលរដ្ឋ និងសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញក្នុងការរក្សានូវសិទ្ធិមិនឱ្យមានការរំលោភលំនៅឋាន និងការឆែកឆេរលំនៅឋានសម្ភារៈវត្ថុទៅលើរូបបុគ្គលត្រូវធ្វើដោយស្របតាមបញ្ញត្តិច្បាប់។ មាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដូចជាករណីដែលចៅក្រមស៊ើបសួរ បានចូលធ្វើការឆែកឆេរផ្ទះរបស់ **ក** និង **ខ** ត្រូវជាឪពុកម្តាយរបស់ជនត្រូវចោទ គ នៅពេលវេលាម៉ោង ១៨ និង ៤០នាទី ល្ងាច ដើម្បីស្វែងរកវត្ថុតាងដែល គ បានលាក់ទុក ក្រោយពីការប្រព្រឹត្តបទល្មើស ***"ហិង្សា ដោយប្រើអាវុធ"*** នៅទីកន្លែងរោងការមិត្តភក្តិ។ ប៉ុន្តែចំពោះការឆែកឆេរ គឺគោរពតែពេលវេលានៃការចូលឆែកឆេរប៉ុណ្ណោះ មិនបានកំណត់នូវរយៈពេលនៃកិច្ចឆែកឆេរត្រូវបញ្ចប់ពេលណាមួយឡើយ។ យើងអាចបកស្រាយថា ទោះបីជាការឆែកឆេរនេះ បានហួសម៉ោងដែលច្បាប់កំណត់ក៏អាចបន្តនូវកិច្ចការរបស់ខ្លួនបានដដែលគឺ នៅតែអាចបន្តការស្រាវជ្រាវ និងស្វែងរកភស្តុតាង។ លើកលែងតែមានករណីផ្ទុយពីនេះ ចៅក្រមស៊ើបសួរអាចបញ្ជាឱ្យកងកម្លាំងសាធារណៈធ្វើការហ៊ុំព័ទ្ធទីកន្លែងនោះ រហូតដល់ពេលដែលច្បាប់ ត្រូវបានអនុញ្ញាតឲ្យធ្វើការឆែកឆេរបាន។ ដូចជាករណីម៉ោង ១៧ ល្ងាច ចៅក្រមស៊ើបសួរបាននាំកម្លាំង ចូលឆែកឆេរក្នុងលំនៅឋានរបស់ជនត្រូវចោទ ក្រោយមួយម៉ោងគឺដល់ម៉ោង ១៨ ល្ងាច នោះកិច្ចនៅតែបន្តរហូតដល់ចប់កិច្ចនៃការឆែកឆេររបស់ខ្លួន ដែលបានសង្ស័យនូវវត្ថុតាងណាមួយ និងអាចដកហូតបាន។

[67] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

**ជាអញ្ញត្រកម្មចំពោះករណីដែលចៅក្រមស៊ើបសួរ មិនចាំបាច់គោរពថេរវេលាមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាច បានក្នុងករណីដែលមាន៖**

- ទីកន្លែងដែលបើកចំហរដល់សាធារណៈជន គឺជាកន្លែងដែលអាចបើកទាំងយប់ទាំងថ្ងៃ ឬបើកតែពេលយប់ ចៅក្រមស៊ើបសួរ គឺអាចចូលឆែកឆេរដោយមិនចាំបាច់គោរពនូវពេលវេលាដែលច្បាប់បានហាមឃាត់ឡើយដោយសារតែទីកន្លែងឯកជន និងសាធារណៈជនចេញចូលបាន។ ដែលមានករណីដូចជា កាស៊ីណូ ភោជនីយដ្ឋាន ក្លឹបកំសាន្ត .ល.។
- ទីកន្លែងមានការផលិត រក្សាទុក ជួញដូរ ចែកចាយ និងការប្រើប្រាស់គ្រឿងញៀន គឺជាករណីពិសេស ដែលមិនអាចគោរពថេរវេលាដោយសារតែវត្ថុតាងងាយនឹងត្រូវបំផ្លាញ និងងាយស្រួលក្នុងការលាក់បាំងដែលមិនអាចរងចាំរយៈពេលត្រឹមត្រូវក្នុងការឆែកឆេរទេ គឺកិច្ចនេះត្រូវតែធ្វើជាការប្រញាប់បំផុត និងមិនអោយជនត្រូវចោទ ឬជនពាក់ព័ន្ធដឹងខ្លួនជាមុនទេ។

ដូចជាករណី ៖ ធ្វើការឆែកឆេរនៅទីតាំងផលិតគ្រឿងញៀន ក្នុងផ្ទះរបស់ជនត្រូវចោទ រួមទាំងលើខ្លួនជនត្រូវចោទដែលរត់គេចខ្លួនទើបចាប់បានរថយន្តរបស់ជនត្រូវចោទ រួមទាំងលើខ្លួនជនត្រូវចោទដែលជនត្រូវចោទលាក់ទុក ឬបន្ទប់សម្ងាត់ក្រោមដីរបស់ជនត្រូវចោទ។

### ខ. ការឆែកឆេរការិយាល័យ ឬក្រុមហ៊ុនមេធាវី

ចៅក្រមស៊ើបសួរ អាចចូលទៅឆែកឆេរក្នុងការិយាល័យមេធាវី ឬ ក្រុមហ៊ុនមេធាវី ក្រោយពីមានបទល្មើស បានកើតឡើងរួចមកហើយ ចៅក្រមស៊ើបសួរធ្វើការពិនិត្យនូវស្នាកស្នាមបន្ថែម ដើម្បីជាក់លាក់ និងស្វែងរកតម្រុយនៃពិរុទ្ធភាពរបស់ជនត្រូវចោទ។ ការឆែកឆេរក្នុងការិយាល័យមេធាវី ឬ ក្រុមហ៊ុនមេធាវី មិនអាចធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ឡើយ។ មានតែចៅក្រមស៊ើបសួរ និងក្រលាបញ្ជី ទើបអាច ចូលទៅឆែកឆេរបាន និងរុករកនូវភស្តុតាងដែលបានបន្សល់ទុកក្រោយពីបទល្មើស កើតឡើងនៅក្នុងការិយាល័យមេធាវី ឬ ក្រុមហ៊ុនមេធាវី ដោយមានការចូលរួមពីប្រធាន គណៈមេធាវី ឬប្រតិភូរបស់ ប្រធានគណៈមេធាវីតាមការចាត់តាំងជំនួស។ ដោយសារតែក្នុងការិយាល័យមេធាវី ឬ ក្រុមហ៊ុនមេធាវី ជាកន្លែងទុកនូវឯកសារនានារវាងអតិថិជន និងមេធាវីដែលត្រូវបានច្បាប់ការពារមិនឱ្យមានការយល់ឯកសាររបស់មេធាវីមកធ្វើជាភស្តុតាងឡើយ [68]។

ចៅក្រមស៊ើបសួរ មិនអាចយកឯកសារណាមួយដែលមិនមានការពាក់ព័ន្ធនឹងកិច្ចស្រាវជ្រាវរបស់ខ្លួនមកប្តឹងបរិហារបានឡើយ។ ដោយសារតែមេធាវីជាវិជ្ជាជីវៈសេរី និងរក្សាការសម្ងាត់ជូនអតិថិជនដូចមាននៅក្នុងក្រមសីលធម៌វិជ្ជាជីវៈមេធាវី ទើបមិនអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ចូលទៅធ្វើការឆែកឆេរខ្លាច បារម្ភមានការ

[68] មាត្រា១៥៩ កថាខណ្ឌ ទី ៤ ការឆែកឆេរ និងការចាប់យកវត្ថុតាងនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

លេចឡើងនូវឯកសារ ណាមួយ ដែលជាបទល្មើសក្នុងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌ និងបារម្ភអំពីការផ្សព្វផ្សាយជាសាធារណៈនូវរាល់ពត៌មានរបស់អតិថិជន។ មិនតែប៉ុណ្ណោះច្បាប់ ក៏បានទាមទារជាដាច់ខាតចំពោះចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន លុះត្រាតែមានការចូលរួមពីប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី (យោងតាមសៀវភៅមេរៀនព្រហ្មទណ្ឌ រ.ប.រ.ត, ចំណុច ខ កថាខណ្ឌទី៣ ការឆែកឆេរ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

**ដូចជាករណី** ក ជាមេធាវីដែលការពារក្តីឱ្យជនត្រូវចោទ ខ និងកូនក្តីរបស់ខ្លួនបានមកពិភាក្សាផ្លូវច្បាប់ក្នុងការិយាល័យមេធាវីរបស់ ក ស្រាប់តែពេលនោះ មានការទាស់សម្តីគ្នាយ៉ាងខ្លាំង ឈានដល់មេធាវី ក បានដកកាំភ្លើងរបស់ខ្លួនបាញ់សម្លាប់ ខ តែម្តង។

*- ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងផ្ទាល់៖*

មិនសូវមានចៅក្រមស៊ើបសួរ រូបណាដែលបានចុះទៅធ្វើការស្រាវជ្រាវ និងឆែកឆេរផ្ទាល់នោះទេ លុះត្រាតែជារឿងសំខាន់ នឹងមានភាពចាំបាច់ខ្លាំងដែលមិនអាចរំលងបានទើបចុះទៅផ្ទាល់។ ប្រសិនជាមិនសូវមានភាពចាំបាច់ទេ ចៅក្រមស៊ើបសួរច្រើនតែធ្វើការចាត់តាំងឱ្យស៊ើបសួរជំនួសដែលអាចប្រគល់ទៅឱ្យសមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌។ ក្រមស៊ើបសួរ ក្រោយពីបានធ្វើការស៊ើបសួរសិក្សាទៅលើសំណុំរឿង និងចំណាត់ការកន្លងមកដោយយល់ឃើញថាមានភាពសង្ស័យនៅត្រង់ចំណុចណាមួយ ឬវត្ថុតាង និងស្លាកស្នាមដែលជារបស់ជនត្រូវចោទបានបន្សល់ទុកឬជនត្រូវចោទបានឆ្លើយចង្អុលបង្ហាញ ឬដើមបណ្តឹងបានឆ្លើយប្រាប់នូវវត្ថុតាងសំខាន់ៗ ដែលអាចបង្ហាញពីពិរុទ្ធភាពរបស់ជនត្រូវចោទ ចៅក្រមស៊ើបសួរ អាចចុះទៅធ្វើការឆែកឆេរនៅទីកន្លែងនោះតែម្តង ដើម្បីស្វែងរកភស្តុតាងឱ្យប្រាកដថាពិតមែន ដូចជាជនត្រូវចោទបានឆ្លើយប្រាប់សម្រាប់ដោះបន្ទុក ឬដើមបណ្តឹងសម្រាប់ភស្តុតាងដាក់បន្ទុក ក្នុងការបង្ហាញនូវភាពត្រឹមត្រូវនៃអង្គហេតុដែលបាន កើតឡើងថា តើវាយ៉ាងណាឲ្យពិតប្រាកដចំពោះអង្គហេតុដែលខ្លួនបានស្រាវជ្រាវ ។

### គ. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ចៅក្រមស៊ើបសួរ ត្រូវកំណត់ទីតាំងត្រូវឆែកឆេរ និងម៉ោងត្រូវចាប់ផ្តើម និងទីកន្លែងចាប់ផ្តើមមកជួបជុំសមាសភាពដែលត្រូវចូលរួមក្នុងការឆែកឆេរ មានករណីកិច្ចមកបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលចៅក្រមស៊ើបសួរ បានបញ្ជាក់នៅក្នុងលិខិតដែលបានធ្វើចេញទៅបុគ្គលពាក់ព័ន្ធ។

ពេលចូលដល់ទីកន្លែងដែលត្រូវឆែកឆេរ ចៅក្រមស៊ើបសួរត្រូវបង្ហាញប្រាប់កម្មសិទ្ធិករ ឬអ្នកកាន់កាប់ទីកន្លែងអំពីការបំពេញកិច្ចឆែកឆេរ ដើម្បីធ្វើការឆែកឆេរក្នុងករណីកម្មសិទ្ធិករ ឬអ្នកកាន់កាប់ទីកន្លែង មិនយល់ព្រម ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចពេញលេញក្នុងការបញ្ជាឲ្យកងកម្លាំងសាធារណៈ បង្ខំឲ្យធ្វើការឆែកឆេរចំពោះមុខកម្មសិទ្ធិករ ឬអ្នកកាន់កាប់ទីកន្លែងនោះតែម្តង។ ចំពោះករណីដែលគ្មានកម្មសិទ្ធិករ ឬអ្នកកាន់កាប់

ទីកន្លែង ចៅក្រមស៊ើបសួរអាចធ្វើការចាត់តាំងសាក្សីចំនួនពីររូប ដែលមានសមត្ថភាពផ្លូវច្បាប់ (អាចជាអ្នកជិតខាង ឬមេភូមិ មេឃុំ ឬចៅសង្កាត់) និងអាចបញ្ជាដោយផ្ទាល់ឱ្យកងកម្លាំងធ្វើការរុសរើសម្ភារៈដែលបិទបាំង ឬមិនអាចបើកបានក្នុងកម្រិតនៃការខូចខាតអប្បរមាដោយមានការសង្ស័យថា មានការលាក់ទុកនូវវត្ថុតាង។ ចៅក្រមស៊ើបសួរអាចធ្វើការដកហូតនូវវត្ថុតាងណាមួយត្រូវតែមានការធ្វើកំណត់ហេតុដោយក្រឡាបញ្ជី ដោយមានការបញ្ជាក់នូវអត្តសញ្ញាណនឹងបញ្ជីសារពើភ័ណ្ឌ នៃវត្ថុដែលចាប់យក។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីចំនួនពីរនាក់។ ម្យ៉ាងទៀតកំណត់ហេតុនេះត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរ មានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញ នូវវត្ថុដែលចាប់បាន កាលណា កម្មសិទ្ធគ្មានជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេច ត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ តែមិនត្រូវប្រគល់សងទៅឱ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសម្តែងឲ្យឃើញការពិត។ ចំពោះវត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬ ជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ ហើយវត្ថុទាំងអស់នេះ ត្រូវធ្វើការរឹបអូសដើម្បីជាកម្មសិទ្ធិរបស់រដ្ឋ។

### កថាខណ្ឌ២៖ ដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ

#### ២.១. និយមន័យនៃដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ

ដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ គឺជាដីកាដែលនៅក្នុងករណី ដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។

#### ២.២. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ

បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ត្រូវបានបង្កើតឱ្យមាន។ បញ្ជីនេះត្រូវរៀបចំឡើងដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បែបបទនៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជីដែលត្រូវបានកំណត់ដោយប្រកាស។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ត្រូវស្បថនៅមុខនៅសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងផ្តល់ជំនួយដោយស្មោះត្រង់ ដល់ការស្វែងរកយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ស្បថសាជាថ្មីទៀតទេ នៅពេលណាខ្លួនត្រូវបានគេចាត់តាំងឱ្យធ្វើកោសលវិច័យ(មាត្រា ១៦៣)។

#### ២.៣. អានុភាពនៃដីកាបង្គាប់ឱ្យធ្វើកោសលវិច័យ

##### ក. ការអនុញ្ញាតឱ្យអ្នកជំនាញធ្វើការពន្យារពេលធ្វើកោសលវិច័យ

អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។ ដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ។ បេសកកម្មអាចទាក់ទងទៅ នឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសប៉ុណ្ណោះ។ ប្រសិនបើ ជាការចៅក្រមស៊ើបសួរ ប្រគល់វត្ថុដែលចាប់បាន។ អ្នកជំនាញអាចបំបែកស្លាកដែលបិទ ដើម្បីធ្វើកោសលវិច័យបាន។ ប្រសិនបើកោសលវិច័យនេះ អាចធ្វើឱ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននឹងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន [69] ។

អ្នកជំនាញបំពេញបេសកកម្ម របស់ខ្លួនក្រោមការពិនិត្យរបស់ ចៅក្រមស៊ើបសួរ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តិទៅនៃបេសកកម្មរបស់ខ្លួន ការលំបាកដែលខ្លួនអាចជួបប្រទះ។ ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់តាំងអ្នកជំនាញនោះ។ ប៉ុន្តែប្រសិនបើកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឱ្យធ្វើការពន្យារពេលបាន [70]។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ។ ចម្លើយដែលអ្នកជំនាញត្រូវទទួលនោះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ បុគ្គលដែលអ្នកជំនាញស្តាប់ចម្លើយនោះ មិនចាំបាច់ស្បថទេ។ ប្រសិនបើ ខ្លួនឯងយល់ថា ចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឱ្យ អ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី។ ប៉ុន្តែ កាលណាចៅក្រមស៊ើបសួរ ចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រ ដើម្បីពិនិត្យជនត្រូវចោទនោះ ការពិនិត្យវេជ្ជសាស្ត្រ ត្រូវធ្វើឡើងដោយគ្មានមេធាវី[71]

## ខ. ការសម្រេចបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ

កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង១ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់ [72]។

[69] មាត្រា ១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។
[70] មាត្រា ១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[71] មាត្រា ១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។
[72] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

## កថាខណ្ឌ៣៖ ដីកាបង្គាប់ឱ្យចាប់ និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍

### ៣.១. អត្ថន័យនៃដីកាបង្គាប់ឱ្យចាប់ និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍

តាមតម្រូវការចាំបាច់ដើម្បីសំដែងឲ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ការស្តាប់ទូរសព្ទ័ គឺជាវិធានការមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបុគ្គលឯកជនដែលធានាដោយ រដ្ឋធម្មនុញ្ញ ទាក់ទិននឹងការសម្ងាត់នៃការឆ្លើយឆ្លងគ្នា។ហេតុនេះហើយ ទើបក្រមនីតិវិធី ព្រហ្មទណ្ឌ អនុញ្ញាតឱ្យតែចៅក្រមស៊ើបសួរប៉ុណ្ណោះ ចៅក្រមស៊ើដែលមានសិទ្ធិអំណាច បង្គាប់ឱ្យស្តាប់ទូរសព្ទ័។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យាបាយ ទូរគមនាគមន៍ផងដែរ ដូចជាសារតាមទូរសារ ឬសារតាមអិនធើណេត[73]។

### ៣.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យចាត់ និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍

ចៅក្រមស៊ើបសួរ អាចសុំឱ្យអង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍ បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនដែលត្រូវចាប់ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម។ ក្រោយពេលបំពេញបេសកកម្មនេះរួចហើយ អង្គភាពសាធារណ ឬ មន្ត្រីរាជការ ត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លងដែលថតបាន ហើយប្រគល់ឯកសារនេះ និងសម្លេងថតបានឱ្យទៅចៅក្រមស៊ើបសួរ។

### ៣.៣. នីតិវិធីនៃដីកាបង្គាប់ឱ្យចាប់ និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍

ចៅក្រមស៊ើបសួរអាចសុំអាចសុំឱ្យ គ្រប់អង្គភាពសាធាណៈទាំងអស់ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេសនិងធ្វើការថត ដើម្បីស្វែងរកភស្តុតាង បន្ថែមដើម្បីជាចំណែកមួយនៃការសម្រេចចិត្តរបស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរ បញ្ជាក់ពីប្រភេទនៃទំនាក់ទំនងដែលចាប់ថត និងរយៈពេលនៃបេសកម្មនេះផង។ ក្រោយពេលបំពេញបេសកម្មនេះរួចហើយ អង្គភាពសាធារណៈ ឬមន្ត្រីរាជការ ត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លងដែលថតបាន ហើយប្រគល់ឯកសារនេះ និងសម្លេងថតបានឱ្យទៅក្រមស៊ើបសួរ។

[73] មាត្រា ១៧២ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៧ ។

### ៣.៤. អានុភាពនៃដីកាបង្គាប់ឱ្យចាប់ និងថតសម្លេងការឆ្លើយឆ្លងតាមទូរគមនាគមន៍

ចៅក្រមស៊ើបសួរ អាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាល យុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។

## កថាខណ្ឌ៤៖ ដីកាសម្រេចបើកការស៊ើបសួរ

### ៤.១. អត្ថន័យនៃដីកាសម្រេចបើកការស៊ើបសួរ

ការស៊ើបសួរ គឺដើម្បីស្រាវជ្រាវរកភស្តុតាងឱ្យ បានគ្រប់គ្រាន់តាមរយៈការស៊ើបសួរ។ ជាធម្មតានៅក្នុងរឿងក្តីព្រហ្មទណ្ឌ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌និងការសាកសួរនៅក្នុងដំណាក់កាលអយ្យការពុំទាន់អាចប្រមូលបានអង្គហេតុ និងភស្តុតាងគ្រប់ជ្រុងជ្រោយដែលអាច បញ្ជូនជនសង្ស័យនោះទៅជំនុំជម្រះបានឡើយ ពីព្រោះគេចាត់ទុកថាដំណាក់កាលចោទនេះជាដំណាក់កាលបឋម។ ហេតុនេះ ទើបនីតិវិធីច្បាប់តម្រូវឱ្យមានការបើកការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីធ្វើយ៉ាងណាស្វែងរកការពិតចាំបាច់សម្រាប់ធានាដល់ការចោទប្រកាន់ និងធានានូវនិរន្តភាព សម្រាប់ដំណើរការកាត់សេចក្តី។

ជាទូទៅសំនួរជាច្រើនបានលេចឡើងក្នុងដំណាក់កាលមួយនេះ ហើយក៏ត្រូវបានយកមកស៊ើបសួរជនត្រូវចោទ និងជនដែលមានការជាប់ពាក់ពន្ធ័ដោយការចោទសួរនោះគឺដើម្បីចង់ដឹងថា តើជនសង្ស័យពិតជាបានប្រព្រឹត្តបទល្មើសមែន ឬមិនមែន។

### ៤.២. លក្ខខណ្ឌនៃដីកាសម្រេចបើកការស៊ើបសួរ

ក្នុងរឿងក្តីព្រហ្មទណ្ឌ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការសាកសួរនៅក្នុងដំណាក់កាលអយ្យការពុំទាន់អាចប្រមូលបានអង្គហេតុ និងភស្តុតាងគ្រប់ជ្រុងជ្រោយដែលអាចបញ្ជូនជនសង្ស័យ នោះទៅជំនុំជម្រះបានឡើយ ពីព្រោះគេចាត់ទុកថាដំណាក់កាលចោទនេះជាដំណាក់កាលបឋម។ ហេតុដូចនេះ ទើបនីតិវិធីច្បាប់តម្រូវមានការបើកការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីធ្វើយ៉ាងណា ស្វែងរកការពិតចាំបាច់សម្រាប់ធានាដល់ការចោទប្រកាន់ និងធានានូវនិរន្តភាពសម្រាប់ដំណើរការកាត់សេចក្តី។ ជាទូទៅសំណួរជាច្រើន បានលេចឡើងនៅក្នុងដំណាក់កាលមួយនេះ ហើយក៏ត្រូវបានយកមកស៊ើបសួរជនត្រូវចោទ និងជនដែលមានការ ជាប់ពាក់ព័ន្ធដោយការចោទសួរនោះគឺដើម្បីចង់ដឹងថា តើជនសង្ស័យពិតជាបានប្រព្រឹត្តបទល្មើសមែន ឬមិនមែន។

### ក. ការស្រាវជ្រាវចំពោះបុគ្គលិក លក្ខណៈរបស់ជនត្រូវចោទ

ក្នុងកិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ គឺមិនត្រឹមតែស៊ើបសួរឱ្យដាក់ច្បាស់នូវអង្គហេតុ ក៏ដូចជាការប្រមូល ភស្តុតាងតែប៉ុណ្ណោះទេ គឺចៅក្រមស៊ើបសួរ ក៏អាចស្រាវជ្រាវអំពីបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ។ ការស្រាវជ្រាវ នេះ គឺមានសារៈប្រយោជន៍ដើម្បីបង្ហាញឲ្យឃើញការពិតនៃសកម្មភាពប្រព្រឹត្ត និងចារិតរបស់ជន

ត្រូវចោទ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ដូចជាសតិអារម្មណ៍របស់ជនត្រូវចោទពេលប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** ជនត្រូវចោទប្រព្រឹត្តបទល្មើសក្នុងពេលប្រើប្រាស់ជាតស្រវឹង បានប្រើប្រាស់គ្រឿងញៀន ពេលមានសតិវិប្លាសស្មារតី ឬស្ថានភាពផ្សេងៗ ។ ការស្រាវជ្រាវនេះ គឺបង្ហាញពីភាពចេតនា ឬអចេតនានៃការប្រព្រឹត្តបទល្មើសដោយជនត្រូវចោទ។

លើសពីនេះទៅទៀតការស្រាវជ្រាវ អំពីបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ គឺដើម្បីទទួលបាននូវព័ត៌មាន ផ្សេងៗ ដែលទាក់ទងទៅនឹងអត្តចារិករបស់ជនត្រូវចោទ ក៏ដូចជាឲ្យបានដឹងនូវរាល់សកម្មភាពរស់នៅប្រចាំថ្ងៃរបស់ ជនត្រូវចោទដើម្បីរកមូលហេតុផ្សេងៗ ដែលបណ្តាលឲ្យមានការប្រព្រឹត្តបទល្មើស។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវនេះក៏អាចបញ្ជាក់បានផងដែរអំពីភាពសុចរិតរបស់ជនត្រូវចោទពីព្រោះថាការចោទប្រកាន់មួយចំនួនអាច មានការភណ្ឌច្រឡំទៅលើបុគ្គលណាមួយ ឬដោយមានការទម្លាក់កំហុស។

### ខ. សមត្ថកិច្ចដែនដី របស់ចៅក្រមស៊ើបសួរ

ក្នុងនីតិវិធីនៃការស៊ើបសួរ ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចដែនដីដើម្បីបំពេញតួនាទីរបស់ ខ្លួនជាទូទៅ គេកំណត់តាមវិធីដូចខាងក្រោម៖

- សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនាទីកន្លែងប្រព្រឹត្តបទល្មើស
- សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនា ទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យ ថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនា ទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយប្រធានសភាស៊ើបសួរដើម្បីសម្រេច។

វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូលដោយការសម្រេចនេះបិទផ្លូវតវ៉ា។

### ៤.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចបើកការស៊ើបសួរ

ដីកាសម្រេចបើកការស៊ើបសួរមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅ ៖

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញានៃបុគ្គលដែលពាក់ពន្ធ័

-បទល្មើសដែលចោទប្រកាន់និង អត្ថបទច្បាប់ដែលកំណត់និង បង្ក្រាបបទល្មើសនេះ

-ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា សម្រេចបើកការស៊ើបសួរ

-ដីកាត្រូវចុះលេខរៀងនៃការចេញ ដីកាស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខ ដីកាចាត់តាំងអ្នកជំនាញ

### ៤.៤. នីតិវិធីនៃដីកាសម្រេចបើកការស៊ើបសួរ

#### ក. សមត្ថកិច្ចដែនដី

ចៅក្រមស៊ើបសួរស្ថិតនៅជាមួយសាលាដំបូង ដូច្នេះគាត់មានសមត្ថកិច្ចក្នុងដែនសមត្ថកិច្ចរបស់តុលាការនេះ នូវចំពោះគ្រប់បទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចនោះ និងចំពោះបទល្មើសដែលកើតឡើងនៅក្រៅដែនសមត្ថកិច្ច ប្រសិនបើជនសង្ស័យម្នាក់ថាបានចូលរួមប្រព្រឹត្តបទល្មើសទាំងអស់ រស់នៅ ឬត្រូវបានចាប់ក្នុងដែនសមត្ថកិច្ចរបស់គាត់ទោះជាត្រូវចាប់មូលហេតុផ្សេងក៏ដោយ។

**សមត្ថភាពរបស់ចៅក្រមស៊ើបសួរមាន ៖**

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនៅទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្ត បទល្មើស ។
- ចៅក្រមស៊ើបសួរនៅទីកន្លែងចាប់ខ្លួន បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ប្រសិនមានទំនាស់សមត្ថកិច្ចរវាងកិច្ចរវាងចៅក្រមស៊ើបសួរនៃសាលាដំបូងខុសគ្នា ដែលទទួលបណ្តឹងទាំងអស់ គ្មាអំពើរឿងព្រហ្មទណ្ឌតែមួយដូចគ្នា។ ដូចនេះប្រធានសភាស៊ើបសួរ ជាអ្នកធ្វើការសម្រេចបិទផ្លូវតវ៉ា។

#### ខ.សមត្ថកិច្ចសាច់រឿង

ចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរទៅបានក៏ត្រូវតែមានដែនកំណត់ក៏ដូចជាទៅ តាមប្រភេទនៃរឿងផងដែរ។ ករណីមានបណ្តឹងពីព្រះរាជអាជ្ញា ឬដោយជនរងគ្រោះតាមរយៈបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី ទៅចៅក្រមស៊ើបសួរ ឬចំពោះបទឧក្រិដ្ឋ ចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរ ជាដាច់ខាតទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងចំពោះការស៊ើបសួរក្នុងបទមជ្ឈិមវិញអាចត្រូវធ្វើ ឬមិនត្រូវធ្វើក៏បាន [74]។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណា មួយបាន ដោយគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានទេ។ កាលណាចៅក្រមស៊ើបសួរ ទទួលពាក្យប្តឹងដោយមានការតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវីធីដូចដែលមានចែងនៅមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ កាលណាទទួលពាក្យបណ្តឹងសាមញ្ញចៅក្រមស៊ើបសួរ ត្រូវតែបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា។

### ៤.៥. អានុភាពនៃដីកាសម្រេចបើកការស៊ើបសួរ

[74] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ចៅក្រមស៊ើបសួរ ត្រូវធ្វើការបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងការទទួលពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែធ្វើការកត់សំគាល់នូវដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរ ត្រូវតែធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើម្បីបណ្តឹងរដ្ឋប្បវេណីតាមដីកា។

**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ** គឺជាបើកការស៊ើបសួរដោយព្រះរាជអាជ្ញា ការស៊ើបសួរនេះផងដែរអាចបើកប្រឆាំងទៅនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនិង អញ្ញាតជន (ជនដែលមិនមានឈ្មោះ ឬភិនភាគ)។ ក្រោយពេលដែលចៅក្រមស៊ើបសួរទទួល បានបណ្តឹងរបស់ព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមក ចៅក្រមស៊ើបសួរត្រូវធ្វើការស៊ើបសួរ ទៅតាមការចង្អុលបង្ហាញរបស់ព្រះរាជអាជ្ញានៅក្នុងដីកា។ ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាបានឡើយ [75]។

**ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ៖** បណ្តឹងរបស់ជនរងគ្រោះ គឺជាបណ្តឹងដែលជនរងគ្រោះធ្វើឡើង

ដើម្បីទទួលបានការជួសជុលព្យសនកម្មផ្ទាល់ខ្លួននៅនាពេលបច្ចុប្បន្ន។ ព្យសនកម្ម អាចជាព្យសនកម្មខាងសំភារៈរូបរាងកាយ និងផ្លូវចិត្ត។ ចៅក្រមស៊ើបសួរ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយខ្លួនឯង ផ្ទាល់ ឬក៏មានអ្នកតំណាង។ ទោះបីជាចៅក្រមស៊ើបសួរទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាបណ្តឹងរដ្ឋប្បវេណីក៏ ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពី អយ្យការជាមុខសិន ទើបអាចធ្វើការស៊ើបសួរបាន។ ក្នុងន័យនេះដែរក្រោយពីបានទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់ការដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាម ដីកាហើយបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ មាត្រា១៣៩ ពេលដែលទទួលបានការបញ្ជូននេះ ព្រះរាជអាជ្ញា ត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានរឿងក្តីឱ្យស៊ើបសួរ ប៉ុន្តែព្រះរាជអាជ្ញា ក៏សុំដល់ចៅក្រមស៊ើបសួរកុំឱ្យ ស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញា ត្រូវផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ គួរកត់សម្គាល់ដែរថា បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាដើមបណ្តឹងមួយថ្មី ដែលទើបតែ បញ្ចូលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះឯង ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់នូវប្រាក់តម្កល់ទុក តាមការកំណត់ របស់ចៅក្រមស៊ើបសួរតាម ដីកាសម្រេចដោយផ្អែកលើធនធាននៃដើម

[75] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

បណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាក នៃរឿងក្តីដែលអាចមើលឃើញជាមុន តែចៅក្រមស៊ើបសួរក៏អាចលើកលែងមិនឱ្យបង់។

## ផ្នែកទី២៖ ការចេញដីកាក្នុងការបំពេញកិច្ចស៊ើបសួរ

### កថាខណ្ឌ១៖ ដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ

#### ១.១. អត្ថន័យនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ

ការប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញ គឺជាការប្រគល់វត្ថុដែលចៅក្រមស៊ើបសួរបានចាប់យក និងដកហូតវត្ថុដែលពាក់ពន្ធ័នឹង បទល្មើសហើយយកមកដើម្បីទុកជាភស្តុតាងក្នុង ការស្វែងរកតម្រុយបន្ថែមពីមន្ត្រីនគរបាលយុត្តិធម៌។ ចំពោះវត្ថុដែលចាប់យកនេះចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការប្រគល់ឱ្យ ឬបដិសេធមិនប្រគល់ទៅម្ចាស់វិញ ។

#### ១.២. លក្ខខណ្ឌនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ

នៅពេលដែលមិនទាន់ចេញដីការដំណោះស្រាយនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅឱ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរ សម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេច ត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនជាមាន។ ប៉ុន្តែ ចៅក្រមស៊ើបសួរ នឹងមិនប្រគល់សងទៅឱ្យអ្នកប្តឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសំដែងឲ្យឃើញការពិត។ ចំពោះវត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬ ជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់មិនអាចត្រូវប្រគល់សងទៅឲ្យសាមីខ្លួនបានទេ។ វត្ថុទាំងអស់នេះត្រូវធ្វើការរឹបអូសដើម្បីជាកម្មសិទ្ធិរបស់រដ្ឋ [76]។

#### ១.៣. និទ្ទេសដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ

ដីកានេះមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅ ៖

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញានៃបុគ្គលដែលពាក់ពន្ធ័ (កម្មសិទ្ធិករ)

-ប្រភេទនៃវត្ថុ ដែលយក

-ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា

-ដីកាត្រូវចុះលេខរៀងនៃការចេញដីកាស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់ដើមវិញ ។

[76]មាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

**១.៤. នីតិវិធីការសម្រេចប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញ**

ចំពោះនីតិវិធីនេះ ចៅក្រមស៊ើបសួរ មានអំណាចក្នុងការប្រគល់វត្ថុចាប់យកឱ្យម្ចាស់វិញតាម ឆន្ទានុសិទ្ធិរបស់គាត់ដោយចេញដីកាសម្រេចដែលមានសំអាងហេតុ បន្ទាប់ពីមានយោបល់ពីព្រះរាជអាជ្ញា ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដោយមានការស្នើសុំពីគូភាគី ឬពីគ្រប់បុគ្គលទាំងអស់ដែលមានប្រយោជន៍លើវត្ថុដែលចាប់យក។

**១.៥. អានុភាពនៃដីកាសម្រេចប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញ**

ចៅក្រមស៊ើបសួរ បន្ទាប់ពីការប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញ ទោះប្រគល់ រឺ មិនប្រគល់ក៏ដោយ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេច និងជូនដំណឹង អំពីការសម្រេចនេះ តាមពាក្យសុំរបស់អ្នកប្តឹងសុំ។ ក្នុងករណីអ្នកប្តឹងសុំមិនសុខចិត្តនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរគឺអាចប្តឹងទៅសភាស៊ើបសួរដើម្បីឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរ។

**១.៦. សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍**

កាលណាបើចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាសម្រេចបដិសេធមិនប្រគល់វត្ថុចាប់យកឱ្យម្ចាស់វិញនោះ ក្នុងករណីនេះតាមក្រមនីតិវិធីព្រហ្មទណ្ឌបានបើកសិទ្ធិឱ្យម្ចាស់ និងគ្រប់បុគ្គលដែលមានប្រយោជន៍ អាចមានសិទ្ធិប្តឹងទៅឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។ ដូច្នេះម្ចាស់វត្ថុ ឬគ្រប់បុគ្គលដែលមានប្រយោជន៍លើវត្ថុចាប់យក អាចប្តឹងទៅឧទ្ធរណ៍បានចំពោះដីកាសម្រេចបដិសេធមិនប្រគល់វត្ថុចាប់យករបស់ចៅក្រមស៊ើបសួរ។ ចំពោះរយៈពេលនៃការប្តឹងទៅឧទ្ធរណ៍មានរយៈពេល៥(ប្រាំ)ថ្ងៃ គិតចាប់ពីការជូនដំណឹងពីដីកា [77]។

**កថាខណ្ឌ២៖ ដីកាដំណោះស្រាយ**

**២.១. និយមន័យដីកាដំណោះស្រាយ**

ដីកាដំណោះស្រាយ គឺជាដីកាដែលចៅក្រមស៊ើបសួរ ត្រូវធ្វើតែក្រោយពីទទួលបានដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ហើយដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ ដីកាដំណោះស្រាយជាមូលដ្ឋានក្នុងការពិចារណាសេចក្តីសម្រេចជាចុងក្រោយនៃការ បញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ។

**២.២. លក្ខខណ្ឌនៃដីកាដំណោះស្រាយ**

ជាគោលការណ៍ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ (ការយល់ឃើញ) ដោយចៅក្រមស៊ើបសួរមុននឹងឈានទៅដល់ការវិនិច្ឆ័យក្នុងសេចក្តីសម្រេចក្នុងដីការបស់ខ្លួនដោយទៅលើកំណត់ ហេតុផ្សេង តាំងពី

[77] មាត្រា ២៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ដំណាក់កាលនគរបាល និងដំណាក់កាលរបស់អយ្យការរួមទាំងយោងតាមកំណត់ហេតុធ្វើតេស្ដ៏កោសលវិច័យ ក្នុងសេចក្ដីសម្រេចក្នុងដីការបស់ខ្លួនដោយទៅលើពិនិត្យទៅលើកំណត់ហេតុផ្សេងតាំងពីដំណាក់កាលនគរបាល និងដំណាក់កាលរបស់អយ្យការរួមទាំងយោងតាមកំណត់ហេតុធ្វើតេស្ដ៏កោសលវិច័យនិង ភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿងដែលខ្លួនបានធ្វើ ការស្រាវជ្រាវកន្លងមក រួមទាំងពិចារណាទៅលើអំពើដែលជនត្រូវចោទបានប្រព្រឹត្តឬមិនបានប្រព្រឹត្ត ដោយផ្អែកទៅភស្តុតាងចៅក្រមស៊ើបសួរអាចវិនិច្ឆ័យសម្រេច ។

**២.៣. និទ្ទេសនៃដីកាដំណោះស្រាយ**

ដីកាដំណោះស្រាយ មានចុះនិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចតទៅះ

-ឈ្មោះ ចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណរបស់ជនត្រូវចោទ

- សំអាងហេតុ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ដីកា នេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃ សៀវភៅនៃដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយ ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួររួមទាំងក្រឡាបញ្ជីនិងមានបោះត្រាផង។

**២.៤. អានុភាពនៃដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរក្រោយពីទទួលបាននូវ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ហើយដីកានោះវាមានអានុភាពបញ្ចប់នូវះ

**បិទបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ**

ការបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន ៖ គឺមានន័យថាជនត្រូវចោទ ត្រូវបានដោះលែងអោយ មានសេរីភាពវិញក៏ប៉ុន្តែចៅក្រមស៊ើបសួរក៏អាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការបាន តាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌ នៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ សេចក្ដីសម្រេចរក្សាទុកជនត្រូវក្នុងការឃុំជា បណ្ដោះអាសន្ន នឹងលែងមានអានុភាពក្នុងរយៈពេល ៤ (បួន)ខែ ប្រសិនបើជនត្រូវចោទ មិនបានចូលទៅបង្ហាញ ខ្លួននៅមុខតុលាការ នោះមានន័យថាជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ដោយឯកឯង។

**ក. ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ**

ការអនុវត្តជាក់ស្តែង ក្រោយពីទទួលសំណុំរឿងដោយភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរពីព្រះរាជអាជ្ញាវិញ ចៅក្រមស៊ើបសួរពិនិត្យលើយោបល់របស់ព្រះរាជអាជ្ញា ថាតើព្រះរាជអាជ្ញាប្តឹងសុំអ្វីខ្លះ រួចធ្វើការសម្រេចដោយឆន្ទានុសិទ្ធថាតើ ឯកភាពតាមយោបល់របស់ព្រះរាជអាជ្ញា ឬសម្រេចផ្សេងពីនេះ ក្រឡាបញ្ជី និងជំនួយការត្រូវព្រាងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះទៅ ព្រះរាជអាជ្ញា ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទ មេធាវី ដើម្បីដាក់ជូនចៅក្រមពិនិត្យ និងហត្ថលេខា។ បន្ទាប់ពីចៅក្រមស៊ើបសួរចុះហត្ថលេខារួច ក្រឡាបញ្ជី ឬជំនួយការ យកលិខិតនោះទៅបោះត្រា និងយកលេខរដ្ឋបាល ដើម្បីបញ្ជូនចេញ។ ការអនុវត្តជាក់ស្តែងការជូនដំណឹងអំពីដីកាដំណោះស្រាយ ពេលខ្លះក្រឡាបញ្ជីធ្វើការបញ្ជូនតាមនីតិវិធី បើជននោះត្រូវចោទនៅក្នុងឃុំ។ ចំពោះសំណុំរឿងដែលមានជនត្រូវចោទនៅក្នុងឃុំបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវព្រាងដីកាបន្ថែមលើដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ គឺជាដីកាសម្រេចរក្សាទុកត្រូវចោទនៅក្នុងឃុំបណ្តោះអាសន្ន។ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះត្រូវធ្វើជា ៤ច្បាប់ ហើយ១ច្បាប់រក្សាទុកក្នុងលេខាធិការដ្ឋានរដ្ឋបាល និង១ច្បាប់រក្សាទុកក្នុងក្រូណូក្រឡាបញ្ជីអយ្យការ និង១ច្បាប់រក្សាទុកក្នុងក្រូណូក្រឡាបញ្ជីចៅក្រម១ ច្បាប់រក្សាទុកក្នុងសំណុំរឿង។

**ខ. ដីកាលើកលែងការចោទប្រកាន់**

កាលណាចៅក្រមស៊ើបសួរ សម្រេចឱ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីការដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងការចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតដល់ទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍ [78] ។

**គ. ដីកាសម្រេចលើកលែងការចោទប្រកាន់**

នៅពេលដែលចៅក្រមស៊ើបសួរចេញសេចក្តីសម្រេច ចៅក្រមស៊ើបសួរត្រូវផ្អែកទៅលើមូលហេតុមួយចំនួនដូចជា៖

- អំពើប្រព្រឹត្តមិនមែនជាបទល្មើសឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់

[78] មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ [79]។

ការលើកលែងការចោទប្រកាន់ អាចទាំងស្រុង ឬមួយផ្នែក គឺទាក់ទងទៅនឹងអំពើទាំងអស់ដែលដាក់ឱ្យពិនិត្យទៅលើបុគ្គល ឬទាក់ទងត្រឹមតែមួយផ្នែកនៃអំពើនេះ។ ដីកាលើកលែងការចោទប្រកាន់ ដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរខ្លួនឯងពីសំណុំរឿង និងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំបណ្តោះអាសន្ន។ កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះត្រូវរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទភ្លាមៗ។

ប្រសិនបើ ព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ពីដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរនោះ ជនត្រូវចោទដែលជាប់ឃុំត្រូវរក្សាទុកនៅពន្ធនាគាររហូតដល់ពេលដែលសភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។ កាលណា សភាស៊ើបសួរសម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯង សភាស៊ើបសួរប្រគល់គ្រប់ភារកិច្ចទៅសមាជិករបស់ខ្លួនម្នាក់ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ។

កាលណា ការស៊ើបសួរហាក់ដូចជាត្រូវបានបញ្ចប់ សំណុំរឿងនៃនីតិវិធីត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធាននៃសភាស៊ើបសួរ កំណត់កាលបរិច្ឆេទនៃសវនាការ។ សភាស៊ើបសួរ បិទការស៊ើបសួរ តាមសាលដីកាដំណោះស្រាយ។ ក្នុងករណីដែលសភាស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនេះត្រូវមានអានុភាពអនុវត្តភ្លាមៗ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ពីដីកាលើកលែងការចោទប្រកាន់ និងដីកានានាមួយចំនួនទៀតរបស់ចៅក្រមស៊ើបសួរ។ ចំណែកឯភាគីតំណាងអយ្យការ (ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា) មានអំណាចធ្វើបណ្តឹងឧទ្ធរណ៍ពីគ្រប់ដីការបស់ចៅក្រមស៊ើបសួរ។ ក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនបើលេចចេញនូវបន្ទុកថ្មីឡើង ការស៊ើបសួរអាចបើកឡើងវិញតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ។

### កថាខណ្ឌ៣៖ ដីកាបញ្ជូនលិខិត

#### ៣.១. អត្ថន័យនៃដីកាបញ្ជូនលិខិត

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអោយព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនលិខិតនោះ។ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវ

[79] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ចេញដីកាបញ្ជូនសំណុំរឿងនោះ។ ចំពោះដីកាបញ្ជូនលិខិតនេះ ត្រូវមាននិទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចលើដីកាបញ្ជូន [80]។

### ៣.២. លក្ខខណ្ឌនៃដីកាបញ្ជូនលិខិត

#### ក. ដីកាបញ្ជូនព័ត៌មានទៅអយ្យការ

កាលណាដែលចៅក្រមស៊ើបសួរ សម្រេចចិត្តក្នុងបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស ដែលបើក ការស្រាវជ្រាវដោយព្រះរាជអាជ្ញាដែលជាម្ចាស់បណ្ដឹងអាជ្ញា មកខ្លួនជាចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងអំពីកិច្ចដែលខ្លួនបម្រុង នឹងបញ្ចប់តាមរយៈដីកាបញ្ជូនពត៌មានទៅព្រះរាជអាជ្ញា។ ដើម្បីទទួលយោបល់ពីគេវិញថាតើការសម្រេចចិត្តរបស់ខ្លួននោះមានលក្ខណៈគ្រប់គ្រាន់ហើយ ឬនៅសំរាប់បញ្ចប់កិច្ចស្រាវជ្រាវនោះ ឬព្រះរាជអាជ្ញាដែលធ្វើការចោទប្រកាន់នោះអាចយល់ឃើញថាសំណុំរឿងមិនទាន់ ពេញលេញហើយមាន ការបញ្ចេញយោបល់មិនឯកភាពនិងអាចស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ច ស្រាវជ្រាវ បន្ថែម។ ក្នុងករណីព្រះរាជអាជ្ញាដែលបានចោទប្រកាន់ បានឯកភាពនឹងការសម្រេចរបស់ចៅក្រមស៊ើបសួរនោះមានន័យថាចៅក្រមស៊ើបសួរនិងបន្តនីតិវិធិដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស ព្រហ្មទណ្ឌរបស់ខ្លួនបានហើយ។

#### ខ. លិខិតជូនដំណឹងទៅភាគី

ភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌ អាចជាដើមបណ្ដឹងរដ្ឋប្បវេណី ឬជាជនរងគ្រោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីនិងជនត្រូវចោទជាដើម [81]។ កាលណានីតិវិធីនៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌបានដល់ទីបញ្ចប់ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងទៅភាគីពាក់ពន្ធ័ ដើម្បីទទួលដំណឹងអំពីការបញ្ចប់ការស៊ើបសួររបស់ខ្លួនក្នុងគោលបំណងឱ្យភាគីអាចស្នើសុំ ឬធ្វើកិច្ចអ្វីមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍មុនពេល ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យនិងធ្វើដីកាសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរវិញ រួចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសត្រឹមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរដែលអាចជាដីកាលើកលែងការចោទប្រកាន់ ឬបញ្ជូនទៅជំនុំជម្រះ។

#### គ. គ្រប់ព័ត៌មានបញ្ជូនត្រលប់មកវិញ

គ្រប់ពត៌មានដែលបានទទួល ត្រលប់មកវិញមានសារសំខាន់សំរាប់ជាភស្តុតាងមួយដែលបញ្ជាក់អំពីភាពត្រឹមត្រូវក្នុងការអនុវត្តមុខងារ របស់ខ្លួនក្នុងឋានៈជាចៅក្រមស៊ើបសួរ។ ម្យ៉ាងវិញទៀត ធ្វើឲ្យកិច្ចស្រាវជ្រាវខ្លួនបានទទួលនូវជោគជ័យតាមរយៈភាពគ្មានជំទាស់ ឬអាចឱ្យដឹងអំពីការស្នើសុំផ្សេងៗក្រោយពីបញ្ជូនពត៌មាន

[80] មាត្រា ២៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

[81] មាត្រា ២៤៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

ឡើងវិញតែបើគ្មានទេចៅក្រមស៊ើបសួរត្រូវរងចាំរយៈពេលពីរថ្ងៃក្រោយ ពីការជូនដំណឹងអំពីការបញ្ចប់កិច្ចស្រាវជ្រាវ និងបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញា។

**៣.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបញ្ជូនលិខិត**

ដីកាបញ្ជូនលិខិតមាននិទ្ទេសសំខាន់ៗ ជាអាទិ៍ដូចខាងក្រោមៈ

-ឈ្មោះចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-កាលបរិច្ឆេទនៃដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

-អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅឋានរបស់ជនត្រូវចោទ ប្រសិនបើមានពិរុទ្ធកម្មប្រកាស (ធ្លាប់មានទោស ឬអត់) ។

-លេខ និង កាលបរិច្ឆេទនៃការធ្វើដីកា។

ទំព័រនីមួយៗនៃដីកាត្រូវតែចុះហត្ថលេខាដោយ ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។ដីកាមិនត្រូវតម្រូវឲ្យមានការចន្លោះបន្ទាត់ឡើយ។ ការឆូត ឬការយោងត្រូវតែមានបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី នៅលើរឹមទំព័រ។

**៣.៤. អានុភាពនៃដីកាបញ្ជូនលិខិត**

ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនសំណុំរឿងនោះ។ ចំពោះដីកាបញ្ជូនលិខិតនេះ ត្រូវមាននិទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចលើដីកាបញ្ជូន។

## កថាខណ្ឌ៤៖ ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង

### ៤.១. អត្ថន័យនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង

***សាលាដំបូង*** មានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន តែប៉ុននោះលើកលែងរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យសាលាជម្រះក្តីផ្សេងទៀត។ក្នុងចាំបាច់ដើម្បីធានាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គមនិងដំណើរការល្អនៃយុត្តិធម៌មន្ត្រីក្រសួង យុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន [82]។

***ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង*** គឺជាសេចក្តីសម្រេចចេញដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរបញ្ជាឲ្យ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវធ្វើការកោះហៅជនត្រូវមកសាលាដំបូង។

### ៤.២. លក្ខខណ្ឌនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង

[82] មាត្រា១៩ នៃស្តីពីរៀបចំអង្គតុលាការលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ចៅក្រមស៊ើបសួរ ធ្វើការកោះហៅជនត្រូវចោទ មកសួរចម្លើយបានគ្រប់ពេលវេលានៅក្នុងរឿងក្តីព្រហ្មទណ្ឌតាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។ ក្នុងករណីជនត្រូវចោទនៅក្រៅឃុំ ត្រូវបានកោះហៅតាមផ្លូវប្រៃសណីយ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ [83]។ ក្នុងករណីចៅក្រមស៊ើបសួរធ្វើការកោះហៅ**ជនត្រូវចោទដែលជាអនីតិជន**គឺត្រូវមានមេធាវី អមជាមួយជាដាច់ខាតក្នុងការសួរចម្លើយ។ អនីតិជន មានសិទ្ធិមិនឆ្លើយនិងសំនួរ របស់ចៅក្រមស៊ើបសួរនិងមន្ត្រីនគរបាល ក្នុងករណីមេធាវីអវត្តមាន។ ប្រសិនចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយជនត្រូវចោទដែលជានីតិជន គឺមានមេធាវីក៏បាន ឬមិនមានក៏បាន ព្រោះគាត់អាចឆ្លងខ្លួនឯងបានប្រកបដោយសតិគ្រប់គ្រាន់។

### ៤.៣. និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង

ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង មាននិទ្ទេសដូចខាងក្រោម៖

-ឈ្មោះចៅក្រមស៊ើបសួរ

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត

-លេខ និង កាលបរិច្ឆេទនៃការធ្វើដីកា។

### ៤.៤. នីតិវិធីនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង

ចៅក្រមស៊ើបសួរអាចកោះហៅជនត្រូវចោទត្រូវធ្វើទៅតាមអាសយដ្ឋានចុងបង្អស់ដែលបានប្រកាសដូចដែលចែងក្នុងមាត្រា១៤៣។មួយវិញទៀតចៅក្រមស៊ើបសួរអាចកោះហៅជនត្រូវចោទ តាមរយៈប្រធានពន្ធនាគារ រឺ មណ្ឌល។ ចៅក្រមស៊ើបសួរ ត្រូវបំពេញកិច្ច ឬទម្រង់ការណាមួយនោះ ត្រូវផុតរលត់នៅចុងក្រោយវេលាម៉ោង ២៤ (ម្ភៃបួន) ។ រយៈពេលដែលផុតតាមធម្មតានៅថ្ងៃ សៅរ៍ ថ្ងៃ អាទិត្យ ឬ ថ្ងៃបុណ្យត្រូវអូសបន្លាយរហូតដល់ថ្ងៃទីមួយ ដែលបើកធ្វើការវិញ។

### ៤.៥. អានុភាពនៃដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទទៅសាលាដំបូង

កាលណាចៅក្រមស៊ើបសួរ រកស្វែងរក ភស្តុតាង និងចម្លើយការពិតរបស់ជនត្រូវចោទ ឬអ្នកដែលពាក់ពន្ធ័ ទាំងអស់ ។ ចៅក្រមស៊ើបសួរអាចធ្វើការកោះ អោយជនទាំងនោះមក សាលាជម្រះក្តី ទៅតាមវេលាដែលបានកោះហៅ ដើម្បីស្វែងរកភស្តុតាង និងចម្លើយដែលជាការពិតរបស់ជនទាំងនោះ [84]។

## កថាខណ្ឌ៥៖ ដីកាចាត់តាំងអ្នកជំនាញ

[83] មាត្រា ២៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហាឆ្នាំ ២០០៧ ។

[84] មាត្រា ២៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

### ៥.១. អត្ថន័យនៃដីកាចាត់តាំងអ្នកជំនាញ

អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។ ដីកាត្រូវបញ្ជាក់អំពីបេសកម្មរបស់អ្នកជំនាញ ព្រមទាំងរយៈពេលដែលត្រូវបំពេញ បេសកម្មនេះផងដែរ។ នៅពេលដែលវត្ថុដែលជាកម្មវត្ថុ នៃការធ្វើកោសលវិច័យដែលមាននៅក្នុងសំណុំរឿងចៅក្រមស៊ើបសួរ ត្រូវតែចេញដីកាសម្រេចចាត់តាំងអ្នកជំនាញ ដែលមាននៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ឬអ្នកជំនាញក្រៅបញ្ជីថ្នាក់ជាតិចំពោះតែលក្ខខណៈបច្ចេកទេសរបស់អ្នកជំនាញពិសេសក្នុងការធ្វើកោសលវិច័យទៅលើភស្តុតាងត្រូវតែបញ្ជូនវត្ថុតាងនោះ ភ្ជាប់ទៅជាមួយនឹងដីកាសម្រេចចាត់តាំងអ្នកជំនាញ [85]។

### ៥.២. លក្ខខណ្ឌនៃដីកាចាត់តាំងអ្នកជំនាញ

ចៅក្រមស៊ើបសួរដែលបានចាត់តាំងអ្នកជំនាញឱ្យ បំពេញនូវកិច្ចបច្ចេកទេសផ្នែកកោសវិច័យទៅលើវត្ថុតាង ឬស្លាកស្នាមអ្វីមួយ ដែលខ្លួនបានសង្ស័យថាមានការពាក់ពន្ធ័ បទល្មើស និងសំណុំរឿងដែលកំពុងមានចំណាត់ការនេះ។ ម្យ៉ាងទៀតដោយខ្លួនមិនអាចវិនិច្ឆ័យបានដោយប្រើភ្នែកទទេថា តើវត្ថុតាងនោះ ឬស្លាកស្នាមនោះមានភាពត្រូវគ្នាជាមួយ នឹងអំពើជនត្រូវចោទបានប្រព្រឹត្ត ឬមិនមែនទេ? ដើម្បីបញ្ជាក់អំពីពិរុទ្ធរបស់ជនត្រូវចោទ។ ដោយសារតែវត្ថុតាងមួយចំនួនមានតែវិទ្យាសាស្ត្រ និងឯកទេសផ្នែកនោះតែប៉ុណ្ណោះដែលអាចមានចំណេះដឹង និងបទពិសោធន៍អំពីកម្មវត្ថុដែលត្រូវធ្វើកោសលវិច័យ [86]។

